# ធនជ័យបណ្ដាំប្រុស្សា



ស្រាវជ្រាវ
និងចងក្រងដោយៈ
**ឧបាសក គៀត ចាន់ផុន**

អតីតសិស្សសាលាវិចិត្រសិល្បៈ
**គៀត ចាន់ថុន**

# <u>អារម្ភបទ</u>

ពូជជ័យជំនាន់ក្រោយទាំងឡាយជាទីគោរពរាប់អាន ដោយខ្ញុំបាទបានអាន ស្ដាប់ និង ពិចារណារឿយៗ ទៅក្នុងសាច់រឿងនិទានធនជ័យ ខ្ញុំបាទយល់ឃើញថា រឿងធនជ័យគឺជារឿង ទំនាយប្រស្នារស់របស់ដូនតា។ ដូនតានិពន្ធនិទាន លោកបាននិទានបន្តទុកឲ្យកូនជ័យគ្រប់ជំនាន់ ថែរក្សាមរតកកំណប់ទ្រព្យប្រស្នាគំនិតដ៏មានតម្លៃនេះ ទុកឲ្យពូជជ័យជំនាន់ក្រោយ បកស្រាយនូវប្រស្នាអាថ៌កំបាំងទំនាយប្រស្នានេះ។ ដោយការស្រាវជ្រាវពិចារណា មរតកកំណប់ជាតិដែលខ្ញុំបាទបានចងក្រងរួចហើយ នូវបណ្ដាំមាតាបិតាមហានគរខ្មែរទាំង៤ភាគឃើញថាមិនទាន់គ្រប់គ្រាន់នៅឡើយ។ ដូចនេះខ្ញុំបាទចាប់ផ្ដើមបើកប្រស្នាកំបាំងក្នុងរឿងធនជ័យជាថ្មីឲ្យបានពិស្ដារឡើង ទោះបីជាខ្ញុំបានបកស្រាយខ្លះៗរួចមកហើយនៅក្នុងបណ្ដាំមាតាមហានគរខ្មែរទាំង៤ភាគ ក៏ឃើញថាពុំទាន់គ្រប់គ្រាន់ដើម្បីឲ្យងាយយល់ពីគោលបណ្ដាំដូនតា។ តើពួកគាត់ឲ្យយើងជាពូជជ័យជំនាន់ខាងក្រោយមើលឃើញពីអ្វី? នូវមរតកគំនិតរបស់ពួកគាត់ ដែលបានបន្សល់ទុកមកដល់សព្វថ្ងៃនេះ។ ហើយខ្ញុំបាទសង្ឃឹមទុកជាមុនថា បណ្ឌិត អ្នកប្រាជ្ញ បញ្ញាជនទាំងឡាយពិតជាជួយជ្រោមជ្រែងនៅក្នុងការគាស់កកាយ មរតកអត្ថប្រស្នាគំនិតដូនតានេះ ឲ្យកាន់តែងាយយល់ ហើយអាចចាក់ទំលុះអត្ថប្រស្នានិពន្ធនិទាននេះ ឲ្យបានទៅដល់គោលដៅ ដែលបុព្វជនយើងគាត់ចង់បាន។ ខ្ញុំបាទក៏សូមអភ័យទោសទុកជាមុន នូវរាល់កំហុសឆ្គង នៅក្នុងការបកស្រាយអត្ថប្រស្នាកាកគំនិតដូនតានេះ ពីសម្នាក់អ្នកប្រាជ្ញ បណ្ឌិត បញ្ញាជន ក្រែងការបកស្រាយនេះពុំអាចចាក់ទំលុះទៅឲ្យដល់ទីជំរៅគំនិត របស់ពួកគាត់បាន ព្រោះបញ្ញារបស់បុថុជ្ជនមានដែនកំណត់ ពុំដូចជាបញ្ញារបស់ព្រះអរិយបុគ្គលទាំង៤ពួកឡើយ។ ខ្ញុំបាទរងចាំទទួលនូវការរិះគន់កែលម្អពីសម្នាក់ពូជជ័យជាញាតិធម៌ ដើម្បីជួយស្ថាបនាការស្រាវជ្រាវនិងចងក្រងនេះ ឲ្យកាន់តែស៊ីជំរៅទៅក្នុងអត្ថគំនិតរបស់ដូនតា កុំឲ្យពួកគាត់អស់សង្ឃឹម ចំពោះយើងជាអ្នកជំនាន់ក្រោយ ដែលបានទទួលមរតកគាត់។

គេហទំព័រ:

http://kietchanthon.blogspot.com

http://kietchanthon.info

http://nokorkmer.info

អ៊ីម៉ែល:chanthonkiet@gmail.com

info@nokorkmer.info

ឯកសារនេះស្រាវជ្រាវនិងចងក្រងដោយ

ខ្ញុំព្រះករុណាខ្ញុំបាទ**គៀត ចាន់ថុន**

អតីតសិស្សសាលាវិចិត្រសិល្បៈ

រឿងធនជ័យ គឺជាកម្រងរឿងព្រេងនិទាន ដែលនិទានបន្តគ្នាពីមាត់មួយទៅមាត់មួយ ពីជំនាន់មួយទៅជំនាន់មួយ ដោយពុំមានដាក់ឈ្មោះអ្នកនិពន្ធ នឹងកាលកំណត់ពេលវេលាបរិច្ឆេទឲ្យបានច្បាស់លាស់ឡើយ។ តែបើយើងមើលតាមចំណងជើងឈ្មោះនៃរឿង យើងអាចដឹងបានថា ធនជ័យ គឺជ័យវិធន ឬជ័យវរ្ម័នទី៧ ព្រោះឈ្មោះរបស់តួនៃរឿងគឺជាឈ្មោះរបស់អ្នកនិពន្ធ ព្រោះហេតុអ្វី? នៅក្នុងសាច់រឿងបានពន្យល់ប្រាប់យើងថា ភាគច្រើននៃគំនិតរឿង គឺបានដកចេញពីរឿងព្រះមហោសថជាតក គ្រាន់តែក្នុងការប្រើភាសានិយាយ ធនជ័យប្រើភាសាមនុស្សសាមញ្ញ(ភាសាអ្នកជនបទ) ចំណែកឯព្រះមហោសថប្រើភាសាអ្នកបានសិក្សារៀនសូត្រ(ភាសាអ្នកក្រុង)។ ដូចជានៅក្នុងការប្រើភាសាគ(ភាសាសញ្ញា) ក្នុងការស្វែងរកកិរិយា ក្នុងការដោះប្រស្នានានា.... គឺមានន័យស្រដៀងគ្នាទៅនឹងរឿងព្រះមហោសថ។ រឿងព្រះមហោសថព្រះអង្គជាពោធិសត្វ ព្រះសម្មាសម្ពុទ្ធសមណគោតមបរមគ្រូនៃយើង រីឯធនជ័យគឺជាពោធិសត្វលោកកេស្វរ ដែលជាបរមងាររបស់ព្រះបាទជ័យវរ្ម័នទី៧។ ដូច្នេះនិពន្ធនិទានរឿងធនជ័យ គឺជាព្រះបាទជ័យវរ្ម័នទី៧ ដែលលោកបាននិទានរឿងជ័យពីរទុក ទី១រឿងធនជ័យ ទី២រឿងជ័យមេរត ហេតុអ្វីបានជាខ្ញុំបាទអាចសន្និដ្ឋានថាជាស្នាគំនិតរបស់ជ័យវរ្ម័នទី៧?

១.ព្រះបាទជ័យវរ្ម័នទី៧ព្រះអង្គមានបរមងារជាពោធិសត្វលោកកេស្វរ ដូច្នេះធនជ័យគឺជានិមិត្តរូបរបស់លោក។

២.ការចូលទីវង្គត់របស់ព្រះអង្គគឺពុំមានបុគ្គលណាបានដឹងឡើយ ព្រោះព្រះអង្គបានក្លែងព្រះកាយចាកចេញពីរាជវាំង ហើយយកមរតកប្រស្នាគំនិតជាច្រើនទៅទុកនៅក្នុងមនុស្ស ដើម្បីឲ្យពូជជ័យជំនាន់ក្រោយនិយាយនិទានបន្តគ្នា នូវអាថ៌កំបាំងប្រស្នា ដែលទាក់ទងនឹងឬសកែវ សាវតាមហានគរនេះ។ ព្រោះតទៅថ្ងៃមុខប្រវត្តិសាវតាឬសកែវរបស់ជាតិ នឹងត្រូវបានបំផ្លិចបំផ្លាញពីសម្នាក់បរទេសឈ្លានពាន ដូចនេះអ្វីដែលសេសសល់ពីការបំផ្លាញ គឺមានតែរឿងរ៉ាវដែលជាប់នៅក្នុងមនុស្ស ដែលនិយាយតៗគ្នាតែប៉ុណ្ណោះ សម្រាប់ស្រាយមរតកប្រស្នាដែលមាននៅលើទឹកដីនេះ។

៣.ព្រះអង្គបានទស្សន៍ទាយព្យាករណ៍ទុក នៅដំណើរទៅថ្ងៃមុខរបស់នគរនេះ ត្រូវជួបនឹងឧបសគ្គបិទបាំងលាបពណ៌ពីសម្នាក់ពួកបរទេស ដោយក្លែងរបស់ពិតទៅជារបស់មិនពិត។

បើយើងមិនបានសិក្សាពិចារណា ស្វែងយល់ឲ្យបានស៊ីជម្រៅនោះទេ យើងស្គាល់និទានរឿងធនជ័យត្រឹមតែរឿងនិទានសើចលេងប៉ុណ្ណោះ ឬក៏យើងចាត់ទុកថាជារឿងនិទានធម្មតាសម្រាប់រឿងនិទានរបស់ក្មេរ។ មរតកទ្រព្យគំនិតចារិកទុកលើក្រដាស ស្បែក ស្លឹករឹត ឬថ្ម... មនុស្សអាចដុតដាប់

បំផ្លាញចោលបាន បើមរតកគំនិតទាំងអស់នេះទុកនៅលើមនុស្ស លុះត្រាតែសម្លាប់មនុស្សឲ្យអស់ទើបអស់រឿង នេះជាប្រស្នារឿងព្រេងនិទានបន្តគ្នា។

## I.កំណើតធនជ័យ

ការចុះចាប់បដិសន្ធិ(កំណើត) របស់សត្វលោកវាជារឿងធម្មតារបស់ធម្មជាតិ ដែលត្រូវចាប់បដិសន្ធិទៅតាមកម្លាំងកម្ម អ្នកមានបុណ្យខ្ពស់សត្វនោះតែងឲ្យនិមិត្ត(យល់សប្តិ) ឃើញខ្ពស់ បើសត្វនោះមានបុណ្យតិចក៏ឲ្យនិមិត្តទាប ទៅតាមបុណ្យខ្ពស់ទាបរបស់សត្វដែលត្រូវមកបដិសន្ធិជាមួយនឹងមាតាបិតារាល់រូប។

- ដូចជាការចុះចាប់បដិសន្ធិ របស់ព្រះបរមពោធិសត្វសមណគោតម បរមគ្រូនៃយើង ព្រះមាតាសិរិមហាមាយា ព្រះនាងបានសុបិននិមិត្តឃើញ ស្ដេចចាតុម្មហារាជទាំង៤ មកលើកព្រះនាងទាំងសរិសយនា នាំទៅកាន់ទីព្រៃហេមវន្ត ហើយតាំងទុកនៅលើមនោសិលាដ៏ធំ ទំហំប្រមាណ៦០យោជន៍ នៅខាងក្រោមដើមរាំងដ៏ធំមួយ កំពស់៧យោជន៍។ កាលនោះព្រះនាងទេវីទាំងឡាយ របស់មហារាជ បានមកអញ្ជើញព្រះនាងសិរិមហាមាយាឲ្យទៅស្រង់ទឹក នៅក្នុងអនោតត្តស្រះ ដុសជម្រះព្រះកាយថ្វាយព្រះនាងរួចហើយ ក៏បានលាបលនដោយគ្រឿង គន្ធវិលេបនជាទិព្វ។ ក្នុងទីជិតអនោតត្តស្រះនោះមានភ្នំប្រាក់មួយ មានសុវណ្ណវិមានមួយ(វិមានមាស) ដែលស្ថិតនៅលើភ្នំប្រាក់នោះ នាងទេពធិតាក៏អញ្ជើញព្រះនាងឲ្យឡើងទៅផ្ទំក្នុងសុវណ្ណវិមាន ឲ្យដាក់សិរ(ក្បាល) ទៅទិសខាងកើត។ ក្នុងទីជិតរជតបព៌ត(ភ្នំប្រាក់) មានសុវណ្ណគិរី ហើយមានសេតហត្ថី(ដំរីស) ត្រាច់ចរលីលាលើសុវណ្ណបព៌តនោះ រួចក៏ចុះចាកសុវណ្ណគិរីហើយឡើងមកលើជេតបិពត។ សេតហត្ថីនោះមានប្រមោយកាន់យកនៅសេតបទុមជាតិ(ផ្កាឈូកស) រួចបន្លឺនូវកោញ្ចនាទ ចូលមកក្នុងសុវណ្ណវិមាន រួចដើរប្រទក្សិណព្រះនាង៣ជុំ ហើយដើរចូលទៅក្នុងព្រះឧទរប្រទេសខាងស្ដាំ គឺជាពេលដែលព្រះបរមពោធិសត្វ ចុះចាប់បដិសន្ធិក្នុងកាលនោះ។

- ចំណែកការចុះចាប់បដិសន្ធិរបស់ធនជ័យ ក៏ដូចជាព្រះបរមពោធិសត្វដែរ តែប្លែកត្រង់ធនជ័យមាតារបស់លោក ជាអ្នកមានវង្សត្រកូលជាអ្នកស្រែចំការ(ទាប) គឺម្ដាយរបស់លោកបានពោលជាភាសាអ្នកជនបទថា «ម៉ែយល់សប្តិដូចជាយល់សូង យល់សប្តិឃើញដូងបេះបានទាំងផ្លែ យល់សប្តិឃើញខែៗរះពេញបូណ៌មី»។ នេះជាប្រស្នាអាថ៌កំបាំងទីមួយ ក្នុង

ការចុះចាប់កំណើតរបស់ធនជ័យ ដែលខ្ញុំបាទត្រូវស្រាយបំភ្លឺពីហេតុសុបិន្តប្រស្នាក្នុងរឿងនេះ ដែលអ្នកប្រាជ្ញជំនាន់មុនទុកឲ្យយើងបកស្រាយ។

យល់សប្ដិដូចយល់សូង ជាភាសានិយាយរបស់អ្នកជនបទ គឺបានប្រាប់យើងថា យល់សប្ដិគឺនិមិត្តឲ្យឃើញក្នុងវេលាយប់ ចំណែកឯពាក្យនិយាយថាយល់សូង គឺជានិមិត្តឲ្យឃើញក្នុងពេលថ្ងៃ។ និពន្ធនិទានបានប្រាប់ឲ្យយើងបានដឹងថា ឲ្យកូនជ័យសម័យក្រោយមើលនិមិត្តក្នុងពេលយប់ផង មើលនិមិត្តក្នុងពេលថ្ងៃផង ព្រោះលោកខ្លាចក្រែងយើងមើលរឿងរបស់លោកក្នុងពេលយប់(យល់សប្ដិ)មិនច្បាស់ ដោយពន្លឺខែពេញបូណ៌មី លោកឲ្យយើងមកមើលពេលថ្ងៃ(យល់សូង) ដោយពន្លឺព្រះអាទិត្យ។ យល់សប្ដិបេះដូងបេះបានទាំងផ្លែ ក្នុងន័យបង្កប់នូវប្រស្នានិមិត្តសុបិន្តនេះ អ្នកប្រាជ្ញបានប្រាប់យើងថា ដូងដែលបេះបានមកគឺបានទាំងផ្លែ គឺមានទាំងសាច់មានទាំងទឹក ដែលវាផ្ទុយពីដូងខែស៊ី។ ដូងខែស៊ីសាច់ក៏គ្មាន បើមានក៏នៅសល់តិចតួច ចំណែកឯទឹកគឺអស់រលីង តើព្រះខែឬព្រះច័ន្ទមានមាត់ឯណាមកស៊ីដូង? ព្រះច័ន្ទឬព្រះខែគឺជាភពមួយផ្សេងពីផែនដី ហេតុអ្វីបានមកស៊ីផ្លែដូងនៅលើផែនដី? ចម្លើយនេះខ្ញុំបាទបានបកស្រាយរួចហើយ នៅក្នុងអាថ៌កំបាំងបណ្ដាំមហានគរខ្មែរភាគ២ ក្នុងរឿងពិធីបុណ្យអុំទូក អកអំបុក សំពះព្រះខែនៅក្នុងខែកត្តិក(កត្តិកា = ផ្កាយកូនមាន់)។ ខ្ញុំបាទតែងឮចាស់ៗនិយាយតគ្នាពីរឿងចាស់ដូង ឬក៏ចាស់ត្នោត ដែលពាក្យប្រៀបធៀបរបស់ពួកគាត់ គឺសំដៅយកតាយាយដែលចាស់ៗ ប្រៀបទៅនឹងដូងឬត្នោត ហេតុអ្វីបានជាពួកគាត់យករុក្ខជាតិទាំងពីរនេះ ទៅប្រៀបធៀបនឹងមនុស្សចាស់? សូមធ្វើការពិចារណាស្វែងយល់ពីផ្លែរុក្ខជាតិទាំងពីរនេះ តើវាខុសគ្នាត្រង់ណា?

## ១.ដូង

- ពាក្យនិយាយថាបើដាំដូង គឺមានន័យថាដាក់ក្បាលសំយ៉ុងចុះក្រោម
- ដាំដូងចំពោះអ្នកស្រែចំការគឺដាំរុក្ខជាតិនេះឲ្យដុះឡើង

បើយើងចង់ហូបផ្លែដូងយើងត្រូវទៅបេះ គឺបេះដូង(ភាសានិយាយ) ន័យទីមួយគឺបេះផ្លែដូង ន័យទីពីរគឺសាច់មួយដុំដែលនៅក្នុងទ្រូងសម្រាប់ថែរក្សាចិត្ត ដែលយើងហៅថាបេះដូង នៅក្នុងសាច់បេះដូងនោះ មានទឹកមួយទុកដៃឬមួយថ្នក់ដៃ ក្នុងភាសាធម៌ហៅថាទឹកចិត្ត។ ទឹកចិត្តតែងប្រែប្រួលទៅតាមសភាវចិត្ត បើចិត្តសេពគប់នឹងអកុសលចេតសិក ទឹកចិត្តប្រែ

ពណ៌ជាស្រអាប់ឬខ្មៅ បើចិត្តសេពគប់សោភណចេតសិក ទឹកចិត្តថ្លាដូចជាប្រេងថ្លា។ ហើយទឹកក្នុងសាច់បេះដូងនេះ និងទឹកនៅក្នុងផ្លែដូងធម្មជាតិ ត្រូវលាក់ទុកក្នុងបួនស្រទាប់ដូចគ្នា គឺទឹកផ្លែដូង ១សម្បក ២ស្រកី ៣លលាដ៍ ៤សាច់ ចំណែកឯទឹកក្នុងបេះដូងក៏បានលាក់ទុកក្នុងបួនស្រទាប់ដូចគ្នាដែរ គឺ១ស្បែក ២សាច់ ៣សរសៃ ៤ឆ្អឹង។ បើប្រៀបធៀបមកក្នុងអត្ថន័យធម៌ ដូចជាព្រហ្មវិហារធម៌ សម្បកឬស្បែកទុកដូចជាមេត្តា ស្រកីឬសាច់ទុកដូចជាករុណា លលាដ៍ឬសរសៃទុកដូចជាមុទុតា សាច់ឬឆ្អឹងទុកដូចឧបេក្ខា។ ហើយធម្មជាតិដូងនេះ មិនបាច់គាបរឹតធ្វើទារុណកម្ម ក៏អាចមានទឹកមានសាច់បរិភោគបាន តាំងពីផ្លែនៅខ្ចីរហូតដល់ចាស់និងទុំ។

## ២.ត្នោត

ត្នោតជារុក្ខជាតិម្យ៉ាង ដែលគេត្រូវចងបង្អោងភ្ជាប់នឹងដើម ដើម្បីឡើងទៅគាបផ្កាញីឬឈ្មោល ចិតសម្រក់យកទឹកមកបរិភោគនឹងរម្ងាស់ធ្វើជាស្ករ។ ពាក្យត្នោតក្លាយមកពីពាក្យពីរម៉ាត់ គឺពាក្យ ត + ណោត ឬនោត មានន័យថាតត្រណោតបន្តគ្នា ឬចងបង្អោងបន្តគ្នា ទើបអាចឡើងទៅគាបរឹតយកទឹកពីវាបាន គឺពុំដូចជាដូងឡើយ។ ហើយត្នោតនេះ ផ្លែខ្ចីអាចបរិភោគបាន ចំណែកផ្លែចាស់ពុំអាចបរិភោគបានឡើយ នេះចំពោះតែត្នោតញី បើត្នោតឈ្មោលគឺពុំមានផ្លែឡើយ នេះជាភាសាប្រស្នាដែលចាស់ៗតែងពោលថា «ចាស់ដូងឬចាស់ត្នោត»? ចាស់ដូងពេលក្មេងចូលទៅអង្គុយជិត មានទឹកមានសាច់អាចបរិភោគបាន ឬបើប្រៀបមកមនុស្ស បើក្មេងទៅអង្គុយជិត គេអាចក្រេបផឹកយកចំណេះដឹង ទាំងខាងផ្លូវលោកនិងផ្លូវធម៌ ដែលចំណេះដឹងទាំង២ផ្លូវនេះ អាចធ្វើឲ្យគេបានក្រេបផឹក មានសេចក្ដីសុខក្នុងលោកនេះផង និងសេចក្ដីសុខក្នុងបរលោក ជាពិសេសអាចនាំឲ្យគេចាកចេញពីវដ្ដសង្សារទុក្ខនេះបានទៀតផង គឺទៅតាមឧបនិស្ស័យចាស់ក្លារបស់អ្នកដែលចូលទៅអង្គុយជិត។

ចំណែកឯចាស់ត្នោតវិញ ទោះបីក្មេងចូលទៅអង្គុយជិត ហើយយកមកបរិភោគ ក៏ទំពាមិនដាច់ ចង់ចម្រាញ់យកទឹកមកបរិភោគបំបាត់ការស្រេកក៏មិនបាន បើប្រៀបធៀបទៅនឹងមនុស្សចាស់វិញ ទោះបីជាក្មេងចូលទៅអង្គុយជិត ដើម្បីក្រេបយកនូវចំណេះដឹង ទាំងផ្លូវលោកនិងផ្លូវធម៌ គឺពុំអាចក្រេបយកបានឡើយ ព្រោះពួកគាត់គ្មានពូជទាំងនេះ សម្រាប់ចែកចាយឲ្យអ្នកទៅអង្គុយជិតនោះបានឡើយ។ ចាស់ដូង និងចាស់ត្នោតដែលខ្ញុំបាទបានបក

ស្រាយ ពីគំនិតដូនតាដែលខ្ញុំធ្លាប់ឮពួកគាត់និយាយ ពីចាស់ដូងឬចាស់ត្នោតនោះ ដើម្បីភ្ជាប់សុបិន្តនិមិត្តរបស់ម្ដាយធនជ័យ ដែលលោកបានឃើញនិមិត្តទាំងថ្ងៃទាំងយប់(យល់សប្ដិយល់សូង) ឲ្យយើងមើលដូង ដែលដូងនេះជារុក្ខជាតិម្យ៉ាង មានឈ្មោះដូចជាដុំសាច់ ដែលនៅក្នុងទ្រូងជាទីលំនៅរបស់ចិត្ត។ រីឯល្បែងចាក់ទឹកដូងក៏ចេញពីប្រស្នាគំនិតរបស់ធនជ័យ ដែលខ្ញុំបាទបានបកស្រាយរួចហើយ នៅក្នុងបណ្ដាំមាតាមហានគរភាគទី១ ដែលគាត់ចង់ឲ្យយើងចាក់ទឹកចេញពីក្នុងបេះដូងម្ដាយ(ចាក់ទឹកចិត្តម៉ែចេញមកក្រៅ)។ និពន្ធនិទានរឿងធនជ័យពាក្យផ្ដើមប្រស្នាក្នុងសាច់រឿង ម្ដាយធនជ័យគាត់ចង់ឲ្យកូនជ័យ ដែលជាពូជជ័យជំនាន់ក្រោយ ឈ្វេងយល់ថា រឿងតែក្នុងមួយយប់គឺយល់សប្ដិ បែរជាមានភ្ជាប់រឿងនៅងក្នុងពេលថ្ងៃគឺយល់សូង ព្រោះគាត់ពុំបានសម្រាក(ដេកលក់) ពេលថ្ងៃផង ហេតុអ្វីមានយល់សូង? យើងជាកូនជ័យជំនាន់ក្រោយ ត្រូវនាំគ្នាស្រាយប្រស្នាគំនិតទាំងនេះ បើយើងមើលនិមិត្តពេលយប់ដោយពន្លឺព្រះខែពេញបូណ៌មីមិនច្បាស់ គាត់ឲ្យយើងមកមើលនិមិត្តពេលថ្ងៃ ដែលមាននៅក្នុងកំណប់ទ្រព្យមរតកម៉ែ(កេរម៉ែ) គឺទំនៀមទំលាប់ប្រពៃណី ឈ្មោះភូមិស្រុកប្រាសាទទំនាយផ្សេងៗ.... របស់ពួកគាត់ ពេលនោះប្រស្នាទាំងឡាយនឹងត្រូវបានស្រាយបំភ្លឺ។

ដូច្នេះការចុះចាប់បដិសន្ធិរបស់ធនជ័យ គឺម្ដាយផ្ដាំឲ្យកូនជ័យមើលរឿងទាំងអស់របស់គាត់ ទាំងក្នុងពេលយប់ និងពេលថ្ងៃ មានន័យថាផ្គុំពន្លឺព្រះអាទិត្យនិងព្រះច័ន្ទឲ្យចូលគ្នា គឺផ្គុំរឿងរបស់សុរិយវង្សនិងសោមវង្ស ដែលជាម្ចាស់ពូជពង្សដើមរបស់ជាតិនេះ ទើបអាចស្រាយបើកនៅកំណប់ទ្រព្យដូនតាបាន។ ការចាប់បដិសន្ធិរបស់ធនជ័យ ថ្វីត្បិតតែគាត់បានឃើញនិមិត្តដ៏ប្រសើរហើយក៏ដោយ ក៏គាត់ពុំទុកចិត្តនូវបញ្ញារបស់ខ្លួនឯង ទើបម្ដាយធនជ័យគាត់បានទៅជួបនឹងហោរា ដើម្បីឲ្យជួយស្រាយប្រស្នានិមិត្តទាំងយប់ទាំងថ្ងៃនេះ ព្រោះហោរាជាអ្នកបានសិក្សានូវវិជ្ជាព្យាករណ៍អាថ៌កំបាំងទាំងនេះ។ ពេលដែលគាត់ទៅដល់ផ្ទះហោរ ពុំបានជួបនឹងហោរជាប្ដីឡើយ បានជួបត្រឹមហោរជាភរិយា ហោរានីជាប្រពន្ធនោះ ធានាថានឹងស្រាយប្រស្នាសុបិន្តនិមិត្ត របស់ម្ដាយធនជ័យបាន។ ពេលបានស្ដាប់ការរ៉ាយរ៉ាប់ពីសុបិន្តរបស់ស្ត្រីដែលមកពឹងពាក់គាត់នោះ ហោរានីជាភរិយារបស់ហោរបានពិចារណាក្នុងចិត្តតែម្នាក់ឯងថា ស្ត្រីនេះមានសត្វមកចាប់កំណើតហើយ សត្វដែលមកចាប់កំណើតនេះ គឺជាអ្នកមានបុណ្យបារមី ដែលបញ្ញារបស់សត្វនេះ អាចមកបំភ្លឺកំចាត់ភាពងងឹតនៅក្នុងនគរនេះ

បាន។ ពេលនោះចិត្តជាអកុសលបានកើតឡើងចំពោះហោរានី ធ្វើឲ្យសេចក្ដីច្រណែនឈ្នានិស ព្យាបាទកើតក្នុងសន្ដានរបស់គាត់ គាត់ក៏បានទាយបង្វែររឿងពិតឲ្យទៅជារឿងមិនពិត។ ព្រោះគាត់យល់ថាមិនគួរសត្វដែលមានបុណ្យនេះ មកចាប់បដិសន្ធិក្នុងស្ត្រីត្រកូលអ្នកស្រែចំការដូច្នេះឡើយ គួរតែមកចាប់បដិសន្ធិក្នុងផ្ទៃរបស់គាត់ ព្រោះគាត់ក៏ជាអ្នកចេះដឹង ប្ដីគាត់ក៏ជាអ្នកចេះដឹង ទើបគាត់បានពោលប្រាប់ទៅម្ដាយធនជ័យថា «អ្នកនឹងមានកូនប្រុសមួយកូននោះធំឡើងនឹងត្រូវធ្វើជាខ្ញុំគេ»។

ត្រង់ចំណុចនេះអ្នកនិពន្ធនិទានធនជ័យ បានប្រាប់យើងជាពូជជ័យខាងក្រោយឲ្យបានយល់ថា សូម្បីតែហោរានីជាស្ត្រីដូចម្ដាយធនជ័យដែរ ហើយមានជាតិជាខ្មែរដែលប្រសូត្រចេញពីទ្វារមាស គឺមាតុភូមិនេះ ក៏នៅតែមានកលមាយាលាក់ប្រវត្តិពិតរបស់អ្នកប្រាជ្ញម្នាក់។ ចុះទំរាំប្រវត្តិសាស្ត្រខ្មែរ(ខ្មែរ) ដែលកូនខ្មែរកំពុងសិក្សារៀនសូត្រគ្រប់ជំនាន់នោះ ហើយភាគច្រើននៃអ្នកសិក្សាស្រាវជ្រាវចងក្រងប្រវត្តិសាស្ត្រនេះ សុទ្ធតែជាជនជាតិបរទេស តើពួកគេអាចលាក់បិទបាំងប្រវត្តិពិតរបស់យើងដែរឬទេ? នេះគឺជាការដាស់ស្មារតីរបស់អ្នកប្រាជ្ញខ្មែរពីបុរាណ ដែលលោកបាននិពន្ធនិទានចងក្រង នូវរឿងប្រកបដោយហេតុផល ដោយលោកបានចងបញ្ហាផងលោកស្រាយនៅប្រស្នាផង ដោយវិធីសាស្ត្របំភ័ន្ត ហាក់បីដូចជាមានមនុស្សច្រើននៅក្នុងរឿង បើនិយាយត្រង់ៗ និទានត្រង់ៗ មរតកទាំងនេះពុំអាចស្ថិតមកដល់សព្វថ្ងៃបានឡើយ។ ការចុះចាប់បដិសន្ធិរបស់បុរសម្នាក់ដែលជាអ្នកប្រាជ្ញមកបំភ្លឺនគរ មកជួយស្រោចស្រង់នគរចេញពីភាពងងឹត ត្រូវបានជាតិខ្មែរដូចគ្នា លាក់នៅប្រវត្តិសាវតាពិត រួមទាំងបរទេសគេជួយបិទបាំងថែមទៀត ធ្វើដូចម្ដេចកូនខ្មែរអាចស្គាល់ប្រវត្តិពិតរបស់ដូនតាពូជជ័យបាន? នេះជាប្រស្នាការចុះចាប់បដិសន្ធិរបស់អ្នកប្រាជ្ញធនជ័យ ដែលជានិមិត្តរូបព្រះបរមពោធិសត្វលោកេស្វរ = ធនជ័យ = ជ័យធន ឬជ័យវិធន = ជ័យវរ្ម័នទី៧ ។

## II.<u>កំណើតប្រាជ្ញាធនជ័យ</u>

តើបញ្ញាធនជ័យកើតឡើងដោយសារហេតុអ្វី?

ក្រោយពេលកុមារធនជ័យចេះរត់លេង កុមារជ័យតែងតែទៅលេងទីធ្លាផ្ទះរបស់លោកសេដ្ឋី ព្រោះផ្ទះរបស់លោកសេដ្ឋីមានទីធ្លាធំទូលាយ ដែលជាជំរករបស់អ្នកមានទ្រព្យសម្បត្តិច្រើន។ នៅក្នុងរឿងអ្នកនិពន្ធនិទានបានពន្យល់ប្រាប់យើងថា សេដ្ឋីនីដែលជាភរិយា គាត់គឺ

ជាអ្នកមានជំនាញចំណូលចិត្តក្នុងការត្បាញសំពត់ហូល ដែលសំពត់ហូល គឺជាមរតករបស់ព្រះមាតានាគ(ព្រះនាងនាគ)។ ក្នុងរឿងដដែលបានបរិយាយប្រាប់យើងថា លោកសេដ្ឋីនីនេះពុំធ្លាប់ហុចនំចំណីចំណុកឬរបស់តិចតួចណាមួយ ដល់កុមារជ័យដែលមកលេងក្នុងទីធ្លាផ្ទះនេះឡើយ ថ្វីត្បិតតែខ្លួនជាសេដ្ឋីដែលមាននូវទ្រព្យសម្បត្តិច្រើន។ ក្នុងពេលមួយនោះសេដ្ឋីនីគាត់កំពុកត្បាញសំពត់ហូល ក៏របូតដៃធ្វើឲ្យត្រល់ជ្រុះទៅដី ដោយគាត់ខ្ជិលឱនរើសគាត់ក៏ប្រើកុមារជ័យឲ្យជួយរើស កុមារជ័យក៏សួរទៅគាត់ថា បើខ្ញុំរើសត្រល់ជូនលោកយាយលោកយាយឲ្យអ្វីខ្ញុំ? លោកយាយក៏ឆ្លើយតបថា ចាំយាយឲ្យអំបុកច្រើន។ ពេលកុមារជ័យរើសត្រល់ឲ្យសេដ្ឋីនីហើយ គេក៏នៅរង់ចាំមើលយាយឲ្យអំបុក កុមារជ័យត្រូវរង់ចាំដល់លោកសេដ្ឋីនីគាត់ឈប់ត្បាញ ទើបគាត់អាចយកអំបុកមកឲ្យខ្លួនបាន។ វេលាដល់សេដ្ឋីនីក៏ផ្អាកត្បាញ ពេលនោះកុមារជ័យក៏ទារយកឈ្នួលអំបុក ដែលយាយបានសន្យាថាឲ្យអំបុកច្រើនដល់ខ្លួន យាយក៏ចាប់យកកន្ដាំងទៅកើបអំបុកយកមកឲ្យកុមារជ័យ ពេលនោះកុមារជ័យយំឡាំប៉ាទធាក់ជើង រួចក៏ពោលឡើងថា យាយថាឲ្យអំបុកខ្ញុំច្រើន ឥឡូវឲ្យខ្ញុំតែមួយកន្ដាំងខ្ញុំមិនព្រមទេ។ ក្នុងឱកាសនោះ លោកសេដ្ឋីក៏បានមកដល់ ហើយក៏សួរទៅភរិយាគាត់ថា ហេតុអ្វីបានជាអាជ័យយំ ភរិយាក៏ប្រាប់តាមដំណើររឿងហូរហែដល់លោកសេដ្ឋី លោកសេដ្ឋីក៏ពោលឡើងថា យាយឯងពុំដឹងចិត្តអាជ័យទេ ទុកខ្ញុំឲ្យអំបុកវាវិញទើបវាសុខចិត្ត។ លោកសេដ្ឋីក៏យកចង្អេរមួយមកកើបអំបុកដាក់ រួចរៃកឲ្យពេញចង្អេរ ហើយយកមកដាក់ផ្ទឹមនឹងអំបុកមួយកន្ដាំងដែលយាយឲ្យ ហើយក៏សួរទៅអាជ័យថា តើឯងយកអំបុកក្នុងរង្វាល់ណាមួយ? កុមារជ័យក្រឡេកមើលទៅអំបុកក្នុងរង្វាល់ទាំងពីរ ឃើញថាអំបុកក្នុងចង្អេរច្រើនជាងអំបុកក្នុងកន្ដាំង ក៏ប្រាប់លោកតាសេដ្ឋីថាខ្ញុំយកក្នុងចង្អេរ។ កុមារជ័យក៏លាកន្សែងរួចចាក់អំបុកក្នុងចង្អេរដាក់ទៅក្នុងថ្នក់ ពេលនោះកុមារជ័យភ្ញាក់ស្មារតី រួចនិយាយតែក្នុងចិត្តម្នាក់ឯងថា អាត្មាអញចាញ់បញ្ឆោតលោកសេដ្ឋីហើយតើ! គាត់ពិចារណារួចសួរខ្លួនឯងថា លោកសេដ្ឋីជាអ្នកមាន ជាមនុស្សចាស់ ហើយប្រសូតចេញពីមាតុភូមិដែលជាផ្ទៃរបស់មាតាតែមួយជាមួយនឹងអញ ហេតុអ្វីក៏លោកសេដ្ឋីគ្មានចិត្តមេត្តា សូម្បីតែអាត្មាអញឋិតនៅក្នុងវ័យកុមារភាពកំពុងរត់លេង ក៏លោកសេដ្ឋីនេះគ្មានអនុគ្រោះ ហើយកេងប្រវ័ញ្ចបំភាន់ក្មេក។ អ្នកណាជាអ្នកបង្រៀនគាត់ ឲ្យចេះបំភ័ន្តនិងកេងប្រវ័ញ្ច ដោយពុំសមហេតុផល នឹងគ្មានក្ដី

មេត្តាចំពោះកុមារយ៉ាងនេះ? និពន្ធនិទានលោកបានប្រាប់ហេតុផល ការចាប់បដិសន្ធិបញ្ញារបស់ធនជ័យ កើតចេញពីត្រល់នឹងអំបុក តើត្រល់និងអំបុកមានបង្កប់ន័យប្រស្នាអ្វី?

១.ជុះត្រល់ប្រើជ័យឲ្យរើស តើនៅក្នុងត្រល់មានអ្វី? នៅក្នុងត្រល់គឺមានសរសៃសូត្រ ដែលសរសៃសូត្រគឺជានិមិត្តរូបរបស់ដង្កូវនាង ជាប់នៅក្នុងសំបុក គេយកទៅស្ងោរក្នុងទឹកក្ដៅ រួចហូតសរសៃពណ៌មាសចេញពីសំបុកដង្កូវនាង ដែលជានិមិត្តរូបព្រះនាងទិព្វសិតាច័ន្ទ ដែលជាអ្នកត្បាញសំពត់សូត្រនេះមុនគេ ក្រោយពេលដែលព្រះនាង ត្រូវទទួលទោសនៅក្នុងឋានមនុស្សលោក ដោយហេតុគាត់បានលួចបេះផ្កាតាលីមសេង។ ពេលដែលព្រះនាងទិព្វសិតាច័ន្ទបានលួចបេះផ្កាតាលីមសេងហើយ គាត់ត្រូវអស់បុណ្យជាទេពធីតា មិនអាចឲ្យគាត់ហោះត្រឡប់ទៅទេវលោកវិញបាន ជាមួយនឹងទេពធីតាបងៗ។ ដូច្នេះព្រះនាងត្រូវធ្វើជាភរិយារបស់តាលីមសេង ដែលតាលីមសេងគាត់ជាកូនបំណុល(អ្នកជំពាក់បំណុល) របស់សេដ្ឋីនៅក្នុងដែន ដែលគាត់រស់នៅ ព្រះនាងទិព្វសិតាច័ន្ទបានបង្កើតមុខរបរត្បាញសំពត់ហូលនេះឡើង ដើម្បីដោះបំណុលសេដ្ឋី។ ចំណងស្នេហ៍ព្រះនាងទិព្វសេដាច័ន្ទ និងតាលីមសេង គាត់បានបង្កើតនៅបុត្រម្នាក់ មាននាមថាពិស្ណុកា ដែលបុត្រនេះក្រោយមកបានក្លាយជាម្ចាស់សំណង់ស្ថាបត្យកម្មអង្គរ ក្នុងរជ្ជកាលព្រះកេតុមាលា(មើលប្រវត្តិព្រះពិស្ណុកា ឬប្រវត្តិការកសាងអង្គរវត្ត)។ ដូច្នេះសរសៃសូត្រ(សំពត់ហូល ផាមួង....) គឺជានិមិត្តរូបព្រះនាងទិព្វសិតាច័ន្ទ ដែលជាទេពធីតាមកពីទេវលោក ដោយហេតុសោយនូវបាបកម្ម ដែលគាត់បានសាងទុកហើយ។ យ៉ាងណាមិញព្រះនាងនាគ ដែលជាម្ចាស់នៃសរសៃសូត្រ ព្រោះហេតុតែប្រកាន់មាំក្នុងឧបាទានក្ខន្ធប្រាំ ធ្វើឲ្យដង្កូវនាងស្ម័គចិត្តជាប់ក្នុងសំបុក រួចកម្ម(អំពើ) រៀបចំត្រូវឲ្យគេយកទៅស្ងោរក្នុងទឹកក្ដៅ(និមិត្តរូបអបាយភូមិ)។ ទើបគេហូតសរសៃមាសចេញពីសំបុក មកត្បាញជាសំពត់ហូល ពេលដែលត្បាញអ្នកត្បាញសូត្រត្រូវឲ្យទឹកបាយ ដែលត្រាំទុកយកមកសិត បើមិនឲ្យទឹកបាយគឺត្បាញពុំកើតឡើយ ទឹកបាយជានិមិត្តរូបព្រះមេដដែល គឺមានន័យថាសរសៃសូត្រជានិមិត្តរូបព្រះមេ រីឯទឹកបាយក៏ជានិមិត្តរូបព្រះមេដូចគ្នា។ គោមក្បាច់ក្រឡាដែលគេត្បាញមានរូបដូចស្រកានាគ ឬពស់ ដែលជានិមិត្តរូបព្រះនាងនាគ ទុកសម្រាប់ឲ្យកូនក្មេរសម័យខាងក្រោយស្លៀកដណ្ដប់ ដើម្បីពិចារណាពីសរសៃសូត្រនេះ។ សរសៃអំបោះនេះ មានឈ្មោះថាសូត្រតែបែរជាភ្លេច ព្រោះពាក្យសូត្រគឺការទន្ទេញឲ្យចាំ

ឥឡូវនេះសូត្រនៅសល់តែឈ្មោះ តែរឿងរ៉ាវរបស់សរសៃសូត្រ បានត្រូវកាត់ផ្ដាច់(កោះដាច់ផ្ដាច់ឈ្មោះទន្លេមេគង្គ ឬកុង) រឿងដើមរបស់ខ្លួន។ កូនក្មេរមានភ័ព្វសំណាងណាស់ កូនប្រុសបើធ្វើកូននាគបានកោរសក់ រួចស្លៀកដណ្ដប់សំពត់ហូលស្រកានាគ រីឯកូនស្រីពេលដែលរៀបការតាមប្រពៃណីបានធ្វើជានិមិត្តរូបព្រះនាងនាគ ក៏ស្លៀកដណ្ដប់សំពត់នាគដូចគ្នា សំពត់ហូល ឬនាគជាសំពត់ដែលកើតចេញពីរឿងព្រះនាងទិព្វសិតាច័ន្ទ ព្រះនាងគឺជាទេពធីតា កូនព្រះឥន្ទ្រាធិរាជ ដូច្នេះកូននាគអ្នកស្លៀកសំពត់ហូល គឺជាពូជពង្សទេវតា ឬផ្កាយ។

២.អំបុកជានិមិត្តរូបអ្វីនៅក្នុងបណ្ដាំប្រស្នាធនជ័យ?

ខ្ញុំបាទបានបកស្រាយរួចហើយ នៅក្នុងបណ្ដាំព្រះម៉ែមហានគរភាគ១ ពីរឿងព្រះមេដែលជាគ្រាប់បាយ ព្រោះចាស់ៗលោកបានហាមថា ហូបបាយកុំឲ្យកំពុបត្រូវដឹងគុណព្រះមេ ព្រោះព្រះមេដែលជាគ្រាប់បាយនេះ បានចិញ្ចឹមមនុស្សឲ្យរស់មួយនគរ តើព្រះមេជាអ្វី? ជាគ្រាប់បាយឬ? បាយកើតចេញពីការយកអង្ករទៅដាំស្ងោរឲ្យឆ្អិន ចំណែកអង្ករកើតចេញពីស្រូវ រីឯស្រូវកើតចេញពីសន្ទូងសំណាប សន្ទូងសំណាបនេះគឺអ្នកស្រែគាត់យកទៅដោតស្ទូងនៅក្នុងដីស្រែ ដែលដីស្រែនេះគឺជាកេរដំណែលរបស់មេឬម៉ែ(មាតុភូមិ)។ ដូច្នេះព្រះមេពិតប្រាកដ គឺជាម្ចាស់កេរដំណែលទឹកដីព្រៃព្រឹក្សា ប្រពៃណី វប្បធម៌ ទំនៀមទំលាប់សាសនា..... ដែលយើងជាកូនក្មេរ អ្នកទទួលនូវមរតកត្រូវឈ្វេងយល់ឲ្យបានដល់ទីជំរៅរបស់ពាក្យ**ព្រះមេ** តើព្រះមេដែលយើងត្រូវដឹងគុណនោះ គឺជាគ្រាប់បាយឬ?

កាលនៅជាគ្រាប់បាយ កំពុបស្ដាយនឹកឃើញដល់ឈ្មោះព្រះមេ ពេលក្លាយខ្លួនជាអំបុក នំប៉័នចុក.... កំពុបលែងស្ដាយ តើដោយសារហេតុអ្វី? អំបុកគេត្រូវយកស្រូវទៅលីងនៅលើអំបែងក្ដៅ ឲ្យស្រែកឲ្យផ្ទុះជាលាជ ទើបយកទៅដាក់ក្នុងត្បាល់រួចបុក ពេលបុកត្រូវស្រូវដែលលីងក្ដៅនោះ ស្រូវស្រែកសម្លេងថ្ងូចថ្ងូរ គួរឲ្យស្រណោះ ដោយត្រូវទំងន់អង្រែបុកឲ្យសំប៉ែត បាត់រូបរៀងព្រះមេ។ កាលខ្លួននៅជាគ្រាប់បាយ កូនប្រុសស្រីបរិភោគជ្រុះ នឹកស្ដាយដល់គ្រាប់បាយនិមិត្តរូបព្រះមេ ពេលក្លាយខ្លួនជាអំបុក ទោះបីបុករួចខ្ចាយកំពុប ឬអំកំពុបលែងមានពាក្យនឹកស្ដាយថា ព្រះមេចិញ្ចឹមមនុស្សមួយនគរទៀតឡើយ។

សូត្រនិងអំបុកជាហេតុផ្ដើមធ្វើឲ្យប្រាជ្ញាធនជ័យកើតឡើង ចេះពិចារណារកហេតុផលរបស់កម្ម តាំងពីនៅជាកុមារភាព ទីមួយគឺធនជ័យបានឃើញទុក្ខវេទនា ព្រះមេដែលជានិមិត្តរូបព្រះមាតាមហានគរ លោកទទួលរងទុក្ខក្នុងអបាយ ដែលនិមិត្តសញ្ញាយល់សួងគឺបាននិមិត្តឃើញពេលថ្ងៃ។ ទីពីរលោកឆ្លល់ថា លោកសេដ្ឋីកើតចេញពីមាតុភូមិនេះលោកមានឈាមជ័រពូជពង្សជាតិកំណើតជាខ្មែរ ចំរើនវ័យធំធាត់ដោយអំណាចគ្រាប់បាយគឺព្រះមេ ហេតុអ្វីក៏កូនក្មេងខ្មែរម្នាក់ ដែលនៅរត់លេងដីសោះ គាត់គ្មានចិត្តអាណិតមេត្តាអនុគ្រោះដល់ក្មេង ហើយបែរជាកេងប្រវ័ញ្ចបោកបញ្ឆោត មកលើរូបកុមារដោយគ្មានក្ដីមេត្តាសោះ(ប្រស្នាគំនិតនេះ និពន្ធនិទានលោកឲ្យយើងយកមកមើល សេដ្ឋីគ្រប់ជំនាន់សង្គមដែលទង្វើរបស់ពួកគេមិនត្រូវទំនង)។ ប្រាជ្ញាជ័យត្រូវកើតឡើងហើយ កុមារជ័យត្រូវស្វែងរកម្ចាស់មេគំនិត ដែលបង្រៀនឲ្យកូនខ្មែរចេះកេងប្រវ័ញ្ចគ្នា លោភលន់ដោយខ្វះការសន្ដោសមេត្តា ករុណា.... ព្រោះពូជខ្មែរជាពូជព្រហ្ម ដែលមានប្រាសាទមុខព្រហ្មជាភ័ស្តុតាង តើគុណធម៌ខ្លឹមព្រលឹងរបស់ព្រហ្មរសាត់បាត់ទៅណាអស់ហើយ? លោកឪពុកខ្ញុំគាត់ធ្លាប់បាននិយាយលេងធម្មតាប្រាប់ខ្ញុំថា បងប្អូនសាច់ញាតិខ្មែរពីដើម មានគុណធម៌គឺចិត្តល្អណាស់ពេលទៅលេងផ្ទះញាតិមិត្តបងប្អូន អ្នកដែលទៅលេងនោះ តែងមានរបស់របរជាជំនូនភ្ជាប់ដៃ ដោយដឹកនឹងរទេះគោឬក្របី ហើយជំនូនទាំងនោះមាន ផលិតផលដែលអ្នកទៅលេងនោះ បង្កបង្កើតផលបាន។ ក្រោយមកគុណធម៌ចាប់ផ្ដើមធ្លាក់ចុះ ជំនូនដែលយកទៅផ្ញើរបងប្អូនញាតិមិត្តដែលត្រូវទៅលេង នៅសល់ត្រឹមមួយអម្រែក គុណធម៌កាន់តែធ្លាក់ចុះទៀតជំនូនដែលយកទៅផ្ញើរនៅសល់ត្រឹមមួយពុន(ពាក់កណ្ដាលអម្រែក) សេចក្ដីល្អកាន់តែធ្លាក់ចុះ ជំនូនដែលយកទៅផ្ញើរសាច់ញាតិ នៅសល់ត្រឹមមួយយួរ ចុងបញ្ចប់ទៅលេងផ្ទះញាតិបងប្អូនគឺទៅដៃទទេ ទៅដល់សុំអាហារទទួលទានរំដោះការស្រេកឃ្លានមួយគ្រា ដល់ពេលត្រឡប់មកផ្ទះសុំសោហ៊ុយមកវិញថែមទៀតផង។ ពីមុនត្រកូលខ្មែរអ្នកស្រែចំការមានចិត្តល្អណាស់ ដាំដុះរបស់អ្វីបាន តែងចែកជូនញាតិមិត្តជិតខាងបរិភោគ នៅសល់ពីបរិភោគទើបយកទៅលក់នៅក្នុងទីផ្សារ សម័យខាងក្រោយគឺពុំដូច្នេះឡើយ ចិត្តប្រកបដោយព្រហ្មវិហារនេះត្រូវបាត់បង់បន្តិចម្ដងៗ សូម្បីតែបងប្អូនសាច់ញាតិ ក៏ត្រូវលក់ដូរដែរ នេះជាទំនាយប្រស្នារបស់អ្នកប្រាជ្ញធនជ័យ លោកបានទស្សន៍ទាយប្រាប់ សារជាតិល្អរបស់ពូជព្រហ្ម ពូជ

ផ្កាយ ពូជអច្ឆរិយ.... ត្រូវវិនាសបាត់បង់គុណធម៌បន្តិចម្តងៗ(ទ្រឹស្តីពួកក្មេរក្រហមបានពោល ទុកថា សក់អ្នកណាក្បាលអ្នកហ្នឹង)។

ហេតុតែសេចក្តីលោភលន់ខុសទំនង លោកសេដ្ឋីនិងភរិយាពុំបានដឹងពីអាថ៌កំបាំង សូត្រនិងអំបុក ជានិមិត្តរូបតាងឲ្យព្រះមេព្រះម៉ែ ធ្វើឲ្យលោកមានចិត្តកេងប្រវ័ញ្ចបំភ័ន្ត សូម្បីតែកូនក្មេងក្មេរ ដែលជាទំពាំងស្នងឬស្សីរបស់ជាតិ ក៏លោកពុំមានក្តីមេត្តា។ និពន្ធនិទានបានប្រាប់យើងឲ្យមើលនៅប្រស្នានេះ ទោះបីជាខំលោភលន់យ៉ាងណា ទ្រព្យសម្បត្តិរបស់សេដ្ឋីទីបំផុតត្រូវភ្លើងដុតបំផ្លាញអស់ តើដោយហេតុអ្វី? មនុស្សសត្វក្នុងលោក អ្នកក្រ មាន ល្ងង់ ចេះ បុរស ស្ត្រី មានយស ឥតយស គ្រហស្ថ បព្វជិត ..... សុទ្ធតែត្រូវឆេះដោយភ្លើង ជរា ព្យាធិ និងមរណៈ សូម្បីតែស្តេចចក្រពត្តិត្រាធិរាជ ដែលមានមហាសមុទ្រទាំងបួនជាព្រំប្រទល់ ក៏ត្រូវឆេះដោយភ្លើងគឺជរា ព្យាធិ មរណៈដូចគ្នា ព្រោះសព្វសត្វក្នុងលោកពុំអាចយកទ្រព្យសម្បត្តិនិងរូបរាងកាយអ្វីបានពីក្នុងលោកនេះឡើយ នេះជាប្រស្នាបណ្តាំរបស់ធនជ័យ ដែលលោកជាពូជពង្សនាគ។

ក្នុងវគ្គដែលធនជ័យមកនៅបម្រើលោកសេដ្ឋី និពន្ធនិទានបានពន្យល់ប្រាប់យើងឲ្យប្រយ័ត្នក្នុងការប្រើពាក្យសម្តី បើពុំនោះទេយើងនឹងត្រូវខកចិត្ត ក្នុងពាក្យប្រើរបស់ខ្លួនឯងជាពុំខាន។ ចំពោះមនុស្សដែលយើងបានប្រើហើយ បើយើងនិយាយពាក្យមិនអស់ន័យសេចក្តី គេនឹងយកពាក្យយើងមកផ្ចាញ់យើងវិញ ដូចនៅក្នុងរឿងធនជ័យ ក្នុងវគ្គនៅបម្រើលោកសេដ្ឋី។ ឧទាហរណ៍ដូចជាលោកសេដ្ឋប្រើឲ្យចាំចំការ មើលគោ ឲ្យរត់តាមសេះ ឲ្យរើសរបស់ដែលជ្រិះ ឲ្យនិយាយតិចៗ.... ដោយការប្រើភាសាពុំអស់ន័យ ដោយមានការប្រមាថមាក់ងាយ ដោយសំអាងថាក្មេង ឬជាអ្នកបម្រើ ផលអាក្រក់នឹងតបមកអ្នកប្រើវិញ។ ហេតុអ្វីបានជាធនជ័យសុំយកមេគោធ្វើជាប្រពន្ធ? គោគឺជានិមិត្តរូបឲ្យផ្កាយមួយដួង ក្នុងដំណើរសុរិយគតិ គឺខែឧសភា(ផ្កាយរូបគោ) ក្នុងដំណើរចន្ទគតិ គឺខែផល្គុន(មាន៣០ថ្ងៃចែកជាឫក្សពីរ គឺឫក្សបុព្វផល្គុនគោឈ្មោល ឫក្សឧត្តរផល្គុនីគោញី) ដែលគាត់សុំយកមេគោធ្វើជាប្រពន្ធ និពន្ធនិទានចង់ប្រាប់ឲ្យយើងបានដឹងថា មេគោបង្កើតកូនគោ និងបំបៅដោះថែរក្សាកូន ម្យ៉ាងទៀតគោគឺជានិមិត្តរូបនៃសេចក្តីព្យាយាម(មើលកសិរព្រាហ្មកំពុងធ្វើស្រែ)។ និពន្ធនិទានចង់ប្រាប់ឲ្យយើងបានដឹងថា ពូជក្មេរគឺជាពូជទេវតា ឬផ្កាយ ដែលមាននិមិត្តរូប

គោបានបង្ហាញជាលើកទីមួយ ហើយរូបគោដដែលនេះ យើងមានរឿងដ៏ជូរចត់ដែលបាន កន្លងទៅហើយ គឺរឿងព្រះគោព្រះកែវ ដែលព្រះគោត្រូវបានបរទេសឈ្លានពានប្លន់ដណ្ដើម យកទៅធ្វើជាកម្មសិទ្ធរបស់គេ។ ហេតុអ្វីពេលភ្លើងឆេះផ្ទះ លោកសេដ្ឋីប្រើឲ្យធនជ័យជញ្ជូន របស់ស្រាលៗ ដែលមានតម្លៃចេញពីភ្លើង ធនជ័យបែរជាយកសំបុកមាន់? ហេតុអ្វីលោក សេដ្ឋីប្រើឲ្យធនជ័យរកមេអ្នកបង្កើតភ្លើង ធនជ័យបែរជាទៅចងយកចង្ក្រានទៅវិញ?

ក.និពន្ធនិទានដូនតា គាត់បានប្រាប់ឲ្យយើងមើលនិមិត្តពេលយប់និងពេលថ្ងៃ(យល់ សប្តិ យល់សូង) ពេលថ្ងៃគឺសំបុកមាន់ តើក្នុងសំបុកមាន់មានអ្វី? គឺមានពងមាន់និងកូន មាន់ បើធនជ័យមិនឱបសំបុកមាន់ចេញទេ ពងមាន់និងកូនមាន់ត្រូវឆេះស្លាប់ក្នុងភ្លើង។ បើ យើងមើលនិមិត្តពេលយប់(យល់សប្តិ) យើងនឹងឃើញផ្កាយមួយក្រញុំ ដែលមានឈ្មោះថា ផ្កាយកូនមាន់ ផ្កាយកូនមាន់នេះ មានឈ្មោះមួយទៀត គឺកត្តិកា ឬកត្តិក ដែលកត្តិកនេះ គឺ ជាឈ្មោះរបស់ខែមួយ ក្នុងដំណើរគោចររបស់ច័ន្ទគតិ។ តើមេផ្កាយកូនមាន់នៅឯណា? នៅ ខេត្តកំពង់ធំមានប្រាសាទបុរាណមួយមានឈ្មោះថា ប្រាសាទគុករកា គុករកាគឺជាគុកដាក់ឃុំ សត្វមាន់ សភាវរបស់សត្វមាន់ មេតែងចិញ្ចឹមឃុំគ្រងថែរក្សាកូន សូម្បីតែខ្លួនត្រូវឃុំជាប់នៅ ក្នុងអង្រុត មេមាន់នៅតែក្រុកៗហៅកូនឲ្យមកជុំ។ ដូច្នេះធនជ័យពុំមែនគាត់មិនដឹង នូវរតន វត្ថុដែលមានតម្លៃរបស់លោកសេដ្ឋីនោះឡើយ ក៏ប៉ុន្តែបើជីវិតកូនមាន់ និមិត្តរូបកូនខ្មែរ ជំនាន់ក្រោយត្រូវស្លាប់ក្នុងភ្លើង តើទ្រព្យសម្បត្តិមានតម្លៃអ្វីចំពោះអ្នកស្លាប់? ហេតុនេះគាត់ ត្រូវឱបសំបុកមាន់ ដើម្បីថែរក្សាជីវិតកូនមាន់ ដែលជានិមិត្តរូបពូជផ្កាយ ឲ្យបានគង់វង្សសិន មានជីវិតទើបមានមរតកទ្រព្យ នេះជាបណ្ដាំប្រស្នា ដែលគាត់ត្រូវឱបសំបុកមាន់ចេញពី ភ្លើង។ មេមាន់ត្រូវជាប់ឃុំក្នុងគុក នៅខេត្តកំពង់ធំ(គុករកា) ដូច្នេះតាមាន់ជាឈ្មោះប្រាសាទ មួយនៅក្នុងជួរភ្នំដងរែក គាត់ត្រូវរែកពូជមាន់ ដែលជាពូជផ្កាយ ពូជទេវតា ពូជព្រហ្ម ពូជ អច្ឆរា.... យកទៅដាក់លើកំពូលភ្នំព្រះវិហារធម៌វិញ។

ខ.ពេលដែលលោកសេដ្ឋីឲ្យរកមេនាំភ្លើង ធ្វើឲ្យឆេះទ្រព្យសម្បត្តិគាត់ ធនជ័យបែរជា ទៅចងចង្ក្រានអូសយកមកបង្ហាញលោកសេដ្ឋី រួចពោលថានេះជាមេនាំភ្លើង តើនិពន្ធនិទាន ចង់ឲ្យយើងមើលឃើញពីរឿងអ្វី? ពាក្យចង្ក្រាននិងសង្ក្រាន្ត គឺមានអត្ថន័យស្រដៀងគ្នា

ចង្ក្រានកើតពីភ្លើងធម្មជាតិ ចំណែកឯសង្ក្រាន្តកើតដោយភ្លើងកម្ម ព្រោះវាជាមេភ្លើងដូចគ្នា។

១.មហាសង្ក្រាន្ត គឺជាការផ្លាស់ប្ដូរឆ្នាំចាស់រួចចូលឆ្នាំថ្មី មហាសង្ក្រាន្តនេះមានរឿងទាក់ទងនឹងសិរី(ស្រី)បីប្រការ ដែលកបិលមហាព្រហ្ម យកប្រស្នាសិរីទាំងបីនេះ មកចោទឲ្យធម្មបាលកុមារដោះប្រស្នារបស់ខ្លួន ហើយដាក់ខសន្យាភ្នាល់គ្នាថា អ្នកណាចាញ់អ្នកនោះត្រូវតែកាត់ក្បាល។ ដោយសេចក្ដីអំនួតមានៈរឹងត្អឹង ធ្វើឲ្យកបិលមហាព្រហ្មបាត់ខ្លួននៅសល់តែសិរសា(ក្បាល) ក្នុងមួយឆ្នាំទើបទេពធីតាទាំងប្រាំពីរជាកូន សង្ក្រាន្តវិលចំឈ្មោះរបស់កូនណា(ឈ្មោះថ្ងៃក្នុងមួយសប្ដាហ៍) កូននោះត្រូវទៅហែរហមថែរក្សាម៉ែឳ។ សិរសាកបិលមហាព្រហ្មនេះ បើយកទៅទុកនៅលើអាកាសត្រូវរាំងភ្លៀង បើយកទៅទុកលើផែនដីផែនដីនឹងប្រេះបែកក្រហែង បើយកទៅទុកក្នុងមហាសមុទ្រ ទឹកសមុទ្រនឹងរីង ព្រោះហេតុតែភ្លើងបាបកម្មគឺកម្ដៅ ទើបទេពធីតាទាំងប្រាំពីរ យកទៅលាក់ទុកក្នុងរូងគុហារភ្នំព្រះសុមេរុ។ ក្នុងមួយឆ្នាំកូនក្មេរប្រុសស្រី នឹកឃើញពួកគាត់(ម៉ែឳ)បានត្រឹមតែបីថ្ងៃ គឺថ្ងៃសង្ក្រាន្ត ថ្ងៃវរៈវនប័ត និងថ្ងៃឡើងស័ក ផុតតែបីថ្ងៃនេះទៅ កូនក្មេរប្រុសស្រី ភ្លេចលែងនឹកឃើញដល់កបិលមហាព្រហ្ម ដែលមានតែក្បាលបាត់ខ្លួន មិនថាកបិលមហាព្រហ្មក្នុងរឿងមហាសង្ក្រាន្ត ឬក៏កបិលមហាព្រហ្មនៅលើប្រាសាទបុរាណ(ប្រាសាទមុខព្រហ្ម)។ មហាសង្ក្រាន្តកើតចេញពីរឿងស្រីបីប្រការ(សិរីបីប្រការ) រឿងសិរីពេលព្រឹកនៅលើមុខ យកទឹកលុបមុខ សិរីថ្ងៃត្រង់នៅលើទ្រូង យកទឹកលាងទ្រូង សិរីថ្ងៃល្ងាចនៅលើជើង យកទឹកលាងជើង ទឹកនិមិត្តរូបស្រីគឺម៉ែ យកទៅលាងបង្កើតសិរី គឺរឿងរបស់ស្រីដែលជានិមិត្តរូបម៉ែដដែល។

២.ទាក់ទងនឹងមេភ្លើងទី២ ធនជ័យបានទៅចងចង្ក្រាន ដែលជាមេភ្លើងកើតចេញពីធម្មជាតិ គឺអុស ធ្យូង ចង្ក្រាននេះបើមិនបានប្រយ័ត្ន ដាក់នៅក្នុងផ្ទះឆេះផ្ទះ ដាក់ក្នុងរោងឆេះរោង ដូចនេះដូនតាយើងលោកត្រូវធ្វើគុកដើម្បីដាក់ចង្ក្រានកុំឲ្យដើរ គឺគុកចង្ក្រាន។ បើយើងមិនរើកញែកពាក្យ គឺពុំបានឃើញនិមិត្តសញ្ញាដូនតាឲ្យមើលក្នុងពេលថ្ងៃឡើយ(យល់សួង) ពេលដែលយល់ប្រស្នារបស់ពួកគាត់ ទើបយើងដឹងថាដូនតាយើង គឺជាអ្នកប្រាជ្ញ ជាពូជនាគ(អ្នកប្រសើរ) ពូជអច្ឆរិយ ពូជព្រហ្ម ពូជប្រាំ ពូជទេវតា ឬផ្កាយ។ យើងពុំបានចាប់ភ្លឹកនឹកគិតពិចារណា រឿងនិពន្ធនិទានទាំងឡាយ ដែលបានពោលបន្តគ្នាលាក់ទុកក្នុងមនុស្សនោះ

សុទ្ធតែមានអាថ៌ប្រស្នាគំនិតដ៏ជ្រៅយ៉ាងនេះ។ ទោះបីយើងជាអ្នកជំនាន់ក្រោយ ខិតខំប្រមែប្រមូលយកមកចងក្រងពន្យល់ ចារិកទុកក្នុងក្រាំង ស្លឹករឹត សៀវភៅ ក៏ពុំបានគ្រប់គ្រាន់ពេញលេញក្នុងសាច់រឿងដែរ ព្រោះអ្នកដែលពោលនិទានបន្ត រមែងមានការភ្លេចភ្លាំងក្នុងសាច់រឿងខ្លះជាពុំខាន ពុំដូចជាការចងចាំរបស់ព្រះអរហន្តទាំងឡាយ ដែលលោកបានសម្រេចនៅវិជ្ជាបីនិងអភិញ្ញាប្រាំមួយ លោកបានផ្ទៀងផ្ទាត់នូវព្រះធម៌ ដែលព្រះសម្មាសម្ពុទ្ធសម្ដែងហើយ ចងក្រងជាព្រះត្រៃបិដក ក្រោយពេលដែលព្រះសម្មាសម្ពុទ្ធបរិនិព្វាន។

រឿងសូត្រនិងអំបុកជាហេតុបង្កើតឲ្យប្រាជ្ញាធនជ័យ ចេះគិតពិចារណាតាំងពីខ្លួននៅជាកុមារ ក្នុងជីវិតរស់នៅជាមួយនឹងលោកសេដ្ឋី គឺបញ្ចប់វគ្គនេះដោយត្រូវភ្លើងដុតបំផ្លាញទ្រព្យសម្បត្តិរបស់សេដ្ឋី ចុងបញ្ចប់ភ្លើងគឺជរា ព្យាធិនិងមរណៈ ក៏ត្រូវដុតរូបគាត់ឲ្យទៅជាគំនរផេះផង់ ដូចជាទ្រព្យសម្បត្តិរបស់ពួកគាត់ដែរ។ ហើយភ្លើងនេះទៀតសោត អ្នកប្រាជ្ញយើងលោកឲ្យមើលភ្លើងដែលទាប គឺភ្លើងដែលកើតចេញពីចង្រ្កាន វាដុតត្រឹមតែផ្ទះបុគ្គល ដែលជាគ្រួសារមួយដូចជាគ្រួសារលោកសេដ្ឋីក្នុងរឿង រីឯភ្លើងកម្មគឺមហាសង្ក្រាន្តបីថ្ងៃ គឺដុតនគរទាំងមូល ដោយអំណាចភ្លើងបាបកម្មចាស់ របស់កបិលមហាព្រហ្ម ដែលសល់នៅនិមិត្តសញ្ញាកបិលមហាព្រហ្ម គឺប្រាសាទមុខព្រហ្មទាំងអស់ ដែលស្ថិតនៅលើទឹកដីមាតុភូមិនេះ ជាស្នាព្រះហស្ដរបស់ព្រះបាទជ័យវរ្ម័នទីប្រាំពីរ។ ព្រហ្មថ្មមានតែក្បាល កបិលមហាព្រហ្មមានតែក្បាល នាគក្រៃរមានតែក្បាល ត្រូវសត្វម្ករ(យក្ស)លេប មាតាមហានគរមានតែក្បាល ត្រូវទូលយោនីខ្លួនឯង គឺនិមិត្តរូបមាតុភូមិនេះ ដូនតាប្រាប់ឲ្យយើងស្វះស្វែងដោះប្រស្នាគាត់រកតួខ្លួន។ ក្បាលកបិលមហាព្រហ្ម យកទៅទុកលើអាកាសរាំងភ្លៀង យកទៅទុកលើផែនដីៗប្រេះក្រហែង យកទៅទុកក្នុងសមុទ្ររីងទឹកមហាសមុទ្រ ដូចនេះមានតែយកទៅលាក់ឃុំទុកក្នុងរូងថ្មកែវ ដែលមានទឹកហូរចេញតាមមាត់រូបចម្លាក់ នៅក្នុងរូងភ្នំព្រះសុមេរុ ប្រស្នាសង្ក្រាន្ត និងចង្ក្រាននេះ ដូនតាឲ្យមើលនិមិត្តពេលយប់និងពេលថ្ងៃ សម្រាប់ស្រាយនៅប្រស្នាអាថ៌កំបាំងមរតកទ្រព្យរបស់ដូនតា ដើម្បីមើលឲ្យឃើញនៅវិបាកកម្មចាស់ ដែលពួកគាត់បានប្រព្រឹត្តិសាងទុកមក បង្កើតបានជាភ្លើងចង្ក្រានផង និងភ្លើងនៅក្នុងមហាសង្ក្រាន្តផង។

## III.ធនជ័យចូលដល់រាជវាំងដែលជាក្បាលព្រហ្ម

ពេលដែលលោកសេដ្ឋីគ្រប់គ្រងធនជ័យលែងបាន លោកសេដ្ឋីក៏យកកុមារជ័យទៅថ្វាយឲ្យទៅធ្វើជាខ្ញុំបម្រើស្ដេចម្ដង ដោយទូលប្រាប់ស្ដេចថាក្មេងនេះមានប្រាជ្ញា ពុំអាចចាប់ទោសកំហុសបាន។ ពេលនោះស្ដេចក៏មានគំនិតចង់ផ្ចាញ់ប្រាជ្ញារបស់ក្មេងនេះ ដើម្បីចាប់ទោស ដោយពុំបានគិតពិចារណា បើក្មេងនេះមានប្រាជ្ញាយ៉ាងនេះ អាត្មាអញគួរតែបណ្ដុះបណ្ដាលក្មេងនេះ ឲ្យបានរៀនសូត្រដើម្បីជួយដល់រាជកិច្ចទៅថ្ងៃក្រោយ ក្នុងការដឹកនាំនគរឲ្យបានរុងរឿង ព្រោះដូនតាយើងក្នុងសម័យភ្នំជីសូរ លោកបានពោលសុភាសិតជាកំណាព្យទុកថា៖

- ស្ដេចខ្លៅនាម៉ឺនខ្លៅដូចពស់ឆាងត្រាវពេននៅមាត់ជណ្ដើរ
- ស្ដេចប្រាជ្ញនាម៉ឺនមហិទ្ធាយក្សដូចពស់ពញ្លាក់ពេននៅមាត់ជណ្ដើរ
- ស្ដេចប្រាជ្ញនាម៉ឺនប្រាជ្ញដូចពស់នាគរាជពាំកែវមនោរាចូលនគរ

ដោយការភ្លេចស្មារតី ព្រោះជឿពាក្យញុះញង់របស់សេដ្ឋី ធ្វើឲ្យស្ដេចពុំឲ្យកុមារជ័យទៅសិក្សាបណ្ដុះបណ្ដាលចំណេះវិជ្ជាឡើយ គឺមានចិត្តស្វែងរកទោសកុមារជ័យតែម្យ៉ាង ទោះបីជាដឹងថាកុមារនេះមានប្រាជ្ញាក៏ដោយ។

ក.ការផ្ចាញ់កុមារជ័យជាលើទីមួយ គឺឲ្យអាមាត្យទៅយកក្បួនកុហក ទោះបីកុមារជ័យបានកុហកទៅហើយ ក៏នៅតែចាញ់បញ្ឆោតកុមារជ័យដដែល ភ្លើងកំហឹងនៃការបរាជ័យនេះ ធ្វើឲ្យស្ដេចដែលជាព្រហ្មរបស់ប្រជារាស្ត្រ ត្រូវបាត់បង់នៅវិហារធម៌ពិតរបស់ខ្លួន ចាប់ផ្ដើមចងគំនុំកុមារជ័យជាកូនអ្នកស្រែ ដែលត្រូវជាកូនចៅប្រជារាស្ត្រខ្លួន ភ្លេចពិចារណាក្នុងនាមខ្លួនជាអ្នកដឹកនាំថែរក្សា គឺជាព្រហ្មរបស់រាស្ត្រ។

ខ.ការផ្ចាញ់ធនជ័យជាលើទីពីរ គឺប្រើធនជ័យឲ្យចុះទៅក្នុងទឹកជាមួយមីនំមីនាង ដែលជាស្រីស្នំ ពេលស្រីៗទាំងនោះចុះទៅក្នុងទឹកបានកាន់ពងមាន់ម្នាក់មួយៗ ដោយពុំឲ្យធនជ័យដឹង ពេលដែលស្រីៗទាំងនោះមុជចុះទឹករួចងើបមកវិញ ក៏ស្រែកតុកតត រួចលើកបង្ហាញពងមាន់ដែលមាននៅក្នុងដៃគ្រប់ៗគ្នា។ ចំណែកឯធនជ័យងើបពីជ្រមុជទឹកឡើង ឃើញស្រីស្នំទាំងឡាយគេមានពងមាន់ក្នុងដៃគ្រប់គ្នា ស្ដេចក៏សួររកពងមាន់ពីធនជ័យ បើធនជ័យមិនមានពងមាន់នឹងត្រូវមានទោស ពេលនោះធនជ័យក៏ស្រែករងាវឡើង ហើយទូលប្រាប់ស្ដេច

ថា ខ្ញុំព្រះករុណាជាមាន់ឈ្មោល បើមិនមានមាន់ឈ្មោលមាន់ញីពុំអាចមានពងឡើយ ស្ដេចទាល់គំនិតព្រោះចម្លើយនេះគឺសមហេតុផល។ ក្នុងប្រស្នាទីពីរនេះ និពន្ធជូនតាគាត់ចង់ឲ្យយើងពិចារណាពីអ្វី? សភាវរបស់សត្វមាន់ វាពងនៅលើទ្រនំក្នុងសំបុក ឬមួយក៏ពងក្នុងទឹក? តើសត្វអ្វីដែលពងនៅលើដី ឬក្នុងទឹក? ក្នុងវគ្គនៅជាមួយលោកសេដ្ឋីពេលដែលឆេះផ្ទះលោកសេដ្ឋី ធនជ័យបានរត់ទៅឱបសំបុកមាន់ចេញពីភ្លើង ដែលសំបុកមាន់ទាំងអស់នោះនៅលើទ្រនើរខ្ពស់ ចុះហេតុអ្វីពេលនេះ ស្រីៗទាំងនោះបែរជាចុះក្នុងទឹក ហើយនាំគ្នាស្រែកតុកតតឡើង រួចពោលថាខ្លួនពងបានមួយ តើពួកគេជាពូជផ្កាយកូនមាន់ ឬក៏ជាពូជទា? សូម្បីតែធនជ័យខ្លួនឯងក៏ត្រូវស្រែករងាវក្នុងទឹកដែរ ដើម្បីថែរក្សាជីវិត បើពុំធ្វើល្ងង់ទេ នឹងត្រូវស្ដេចចាប់ទោសជាពុំខាន ព្រោះស្ត្រីដែលជានិមិត្តរូបពូជមាន់ ដែលជាពូជផ្កាយ ក្លាយជាពូជទាពងនៅក្នុងទឹក តែនៅនឹកឃើញសាវតា តុកតត ដែលជាពូជមាន់។ ក្នុងការផ្ចាញ់លើកទីពីរនេះ និពន្ធនិទានចង់ពន្យល់ប្រាប់យើងថា ពូជមាន់ដែលធ្លាប់នៅទីខ្ពស់ ឥឡូវបែរជាចុះមករស់នៅក្នុងទីទាប តែពុំបានភ្លេចសាវតាតុកតតដែលជាពូជខ្ពស់ នឹងការរងាវរបស់ធនជ័យ ទោះបីជាលិចចុះទៅក្នុងទឹក ក៏នៅតែប្រឹងរើបំរះ ទៅរកទីខ្ពស់ ដែលខ្លួនមិនទាន់បានទៅសម្លេងបានស្រែកបង្ហាញក្នុងដំណើរទៅរកទិសផ្កាយ(តុកតត នឹងការរងាវដោះទ័លរបស់ធនជ័យ)។

គ.ការផ្ចាញ់ធនជ័យលើកទីបី ដោយការទទួលបរាជ័យ ក្នុងការដោះសាររបស់ធនជ័យ ស្ដេចបានរកវិធីដើម្បីចាប់ទោសធនជ័យជាបន្ត ដោយបានប្រើឲ្យធនជ័យរកមាន់យកទៅបញ្ចាល់ ដោយហាមប្រជារាស្ត្រដែលមានមាន់ជល់ទាំងអស់ កុំឲ្យលក់ ឬឲ្យធនជ័យខ្ចី បើមានអ្នកណាឲ្យធនជ័យខ្ចីមាន់ ត្រូវយកទោស។ នៅក្នុងសាច់រឿងនេះ បើយើងពិចារណាធនជ័យគឺជាកូនអ្នកស្រែចំការ ដូចនេះអ្នកស្រែចំការជាធម្មតា ផ្ទះណាក៏មានចិញ្ចឹមមាន់ដែរ ហេតុអ្វីបានជាធនជ័យមិនអាចយកមាន់ពីផ្ទះរបស់គាត់ ឬក៏ផ្ទះសាច់ញាតិ ដែលត្រូវជាពូមីង អ៊ុំប្រុសអ៊ុំស្រី ជាញាតិខាងម្ដាយ ឬខាងឪពុក យកទៅប្រជល់ បែរជាយកកូនមាន់ដែលទើបនឹងញាស់ ចេញពីសំបកទៅប្រជល់ទៅវិញ? នេះជាប្រស្នាដែលប្រាជ្ញជូនតា លោកចង់ឲ្យយើងមើលឃើញនឹងគិតពិចារណា ហើយរកមូលហេតុអំពីនិមិត្តសត្វមាន់ តាំងពីសំបុកមាន់ដែលគាត់បានឱបចេញពីភ្លើង ក្នុងពេលភ្លើងឆេះផ្ទះលោកសេដ្ឋី ពងមាន់ដែលស្រីស្នំ

ទាំងឡាយបានកាន់មុជចុះទៅក្នុងទឹក ហើយចុងបញ្ចប់ឲ្យរកមាន់ឈ្មោលយកទៅប្រជល់ ដែលធនជ័យបែរជាយកកូនមាន់ទើបនឹងញាស់ យកទៅបញ្ចល់ទៅវិញ។ នៅក្នុងទំនាយសុក្រសៅរ៍ លោកបានចងក្រងជាប្រស្នាទំនាយរួចពោលទុកក្នុងវគ្គរាជហង្សថា៖

**សាស្រ្តាថ្ងៃសុក្រ ឬពារសុក្រ**

រាជហង្សហើរបង់ចោលសំបុក ហើរទៅយកកុកជាសម្លាញ់
ដល់មានព្រានព្រៃមកបរបាញ់ កុកសស្រឡាញ់ហើរចោលហង្ស។
ម្ល៉ោះហើយសមនឹងអាសាសូន្យ អន្តរាយខូចខ្លួនវិនាសបង់
ព្រោះព្រើលគំនិតគិតចើកចង់ សប្បាយទើបបង់ពីសំបុក។
លង់លុះមានភ័យដូច្នេះឯង ទើបបានហើរស្វែងរកទីសុខ
រកទៅរកមកបានតែទុក្ខ ព្រោះបង់សំបុកឋានអាត្មា។
ហៃនែអស់ជនទាំងឡាយអើយ អ្នកអើយនេះហើយហៅឧបមា
ឧបមេយ្យឲ្យដឹងហេតុគ្រប់គ្នា ការរងវេទនាជាប្រាកដ។

**សាស្រ្តាថ្ងៃសៅរ៍ ឬពារសៅរ៍**

រាជហង្សហើរបង់ចោលសំបុក ហើរទៅយកកុកជាសម្លាញ់
លុះមានព្រានព្រៃមកបរបាញ់ កុកសសោតចេញហើរចោលហង្ស។
ម្ល៉េះហើយសមនឹងអាសាសូន្យ អន្តរាយខូចខ្លួនវិនាសបង់
ព្រោះដោយគំនិតគិតចើកចង់ ឲ្យបានថ្កើងអង្គក្នុងលោកិយ។
មុខគួរស្រណោះតែគោកធ្លក ពីដើមរៀងមកគ្មានព្រួយអ្វី
ឥឡូវស្មោពីរលើឃ្លាងបី អ្នកស្រុកប្រុសស្រីស្ដីដើមឯង។

លោកអ្នកប្រាជ្ញចង់ឲ្យយើងពិចារណាក្នុងទំនាយថា បើរាជហង្សហើយចោលសំបុក តើនៅក្នុងសំបុកហង្សមានអ្វី? ក្នុងសំបុកហង្ស មានកូនហង្ស មានពងហង្ស តើកូនហង្សដែលមិនទាន់ញាស់ និងញាស់មកហើយ តើសង្ឃឹមអ្វី បើមេបាហើរចោលអស់យ៉ាងនេះ? ដូចនេះកូននៅក្នុងសំបុក ត្រូវទទួលសេចក្ដីស្រេកឃ្លាន កូនដែលធ្លាក់ចេញពីសំបុកត្រូវស្លាប់ កូននៅរស់ត្រូវដើរសុំទានគេ បុលបំណុលគេសម្រាប់ជីវិត អ្នកសុំមិនបានត្រូវអត់អាហារ អត់ឃ្លានស្លាប់ តើទំនាយដូនតាឲ្យយើងមើលពីរឿងអ្វី?

ចំណែកនៅក្នុងរឿងធនជ័យ កុមារជ័យស្ទុះចូលទៅក្នុងភ្លើង ដែលកំពុងឆេះចាប់ឱប យកសំបុកមាន់ចេញពីភ្លើង ព្រោះកូនមាន់គឺជានិមិត្តរូបផ្កាយ ដែលរះនៅលើមេឃ ក្នុងខែកត្តិក ចំណែកឯមេមាន់ត្រូវជាប់ឃុំ នៅក្នុងគុករកាខេត្តកំពង់ធំ។ ដូចនេះប្រជាជនខ្មែរក្នុងរដូវសែនព្រេន ភាគច្រើនត្រូវយកមាន់ទៅស្ងោរដើម្បីសែន ពេលមុនស្ងោរគឺបត់កមាន់មកខ្ទាស់នឹងស្លាបរបស់មាន់ ដើម្បីឲ្យក្បាលមាន់ងើយមើលទៅលើ នេះជានិមិត្តរូបមាតាបិតាធ្លាក់ក្នុងអបាយភូមិហើយ ក៏នៅតែងើយមើលទៅកូនដែលរស់នៅរញ្ជង់ខាងលើ(សូមមើលបន្ថែមអាថ៌កំបាំងបណ្ដាំមាតាមហានគរ ភាគ១ ២ ៣ ៤)។ ក្នុងវគ្គជល់មាន់នេះ ធនជ័យបានឱបកូនមាន់ទើបនឹងញាស់ យកទៅដាក់ជិតមាន់ឈ្មោលរបស់ស្ដេច ដែលជាបារបស់វា ដើម្បីឲ្យបាគ្របក្រុងថែរក្សាកូន តែមិនដូច្នេះឡើយ មាន់ឈ្មោលដែលជាបាបានរត់គេចចេញដោយការរសើប ធ្វើឲ្យកូនមាន់នោះរត់ដេញតាម ដើម្បីឲ្យបាផ្សាយនៅព្រហ្មវិហារធម៌គ្របក្រុងថែរក្សាខ្លួន តើកូនមាន់ដេញបាទាន់ឬទេ? ខ្មែរមានពាក្យសុភាសិតមួយឃ្លាបានពោលទុកថា **«ស៊ូស្លាប់បា កុំឲ្យស្លាប់មេ ស៊ូលិចទូកកណ្ដាលទន្លេ កុំឲ្យភ្លើងឆេះផ្ទះ»** ពេលស្លាប់មេកូនត្រូវបែកខ្ញែករតាត់រតាយ បើភ្លើងឆេះផ្ទះសូម្បីសត្វសង្កើចមួយក៏មិននៅសល់ឡើយ។ នៅក្នុងឆ្នាំទាំង១២ដែលជាដួងកែវរបស់មនុស្សប្រុសស្រី គឺគ្មានឆ្នាំហង្សនិងឆ្នាំរាជសីហ៍ឡើយ គឺមានតែឆ្នាំរកា និមិត្តរូបសត្វហង្ស និងឆ្នាំចរនិមិត្តរូបសត្វរាជសីហ៍ តើរាជហង្សនៅក្នុងទំនាយសុក្រសៅរ៍ ដូនតាព្យាករណ៍សម្រាប់បុគ្គលណា? រឿងសត្វមាន់ដែលមានក្នុងរឿងធនជ័យ និពន្ធដូនតាយើងឲ្យមើលសត្វមាន់ក្នុងឆ្នាំទាំង១២ មើលផ្កាយកូនមាន់ មើលប្រាសាទគុករកា មើលប្រាសាទតាមាន់ មើលរុក្ខជាតិដើមសិរមាន់ មើលល្បែងខ្លែងចាប់កូនមាន់ ហើយជាពិសេសទៅទៀតនោះ ឲ្យមើលការថែគ្រងរក្សាកូន របស់សភាវៈមេមាន់និងបាមាន់ នៅក្នុងវគ្គចុងក្រោយនេះ។

ឃ.ការផ្ចាញ់ធនជ័យលើកទីបួន ដោយការផ្ចាញ់ធនជ័យជាបន្តបន្ទាប់ ពុំបានសម្រេច ស្ដេចក៏រកវិធីផ្សេងទៀតដើម្បីផ្ចាញ់ចាប់ទោស ស្ដេចបានប្រើឲ្យធនជ័យរកសេះដើម្បីជិះហែហមទៅប្រពាតព្រៃ តែស្ដេចបានហាមប្រាមអ្នកមានសេះកុំឲ្យធនជ័យខ្ចី។ ធនជ័យបានភ្ជាប់សេះកូនអុកដែលមានតែក្បាល ដង្ហែព្រះរាជាទៅប្រពាតព្រៃ ដើម្បីដោះសារឲ្យបានរួចខ្លួនពីទោស តើប្រស្នាសេះឥតមានក្បាលនេះ លោកទុកនិមិត្តរូបនៅទីណា? នៅប្រាសាទ

នាគព័ន្ធ គ្រប់គុហារកំពែងខាងក្រៅជ្រុងទាំង៤ ទិសខាងកើតរូបមាតាមហានគរមានតែក្បាល រួចទូលយោនីពីខាងលើមុខដហាមាត់បង្ហូរទឹក ទិសខាងលិចរូបសេះមានតែក្បាលហាមាត់បង្ហូរទឹក ទិសខាងត្បូងរូបដំរីមានតែក្បាលហាមាត់បង្ហូរទឹក ទិសខាងជើងរូបរាជសីហៈមានតែក្បាលហាមាត់បង្ហូរទឹក។ ហើយរូបសេះពលាហក ដែលមានទាំងខ្លួន ហើយមានមនុស្សជិះនឹងតោងជុំវិញសេះ ដែលប្រវិត្តរឿងរបស់សេះពលាហកនេះ ជាតួរអង្គព្រះពោធិសត្វសមណគោតមបរមគ្រូនៃយើង កាលនោះព្រះអង្គយោនយកកំណើតជាសេះតែងទៅបរិភោគស្មៅនៅកោះស្រីលង្កា ហើយកោះស្រីលង្កាជំនាន់នោះ ពុំមានមនុស្សរស់នៅឡើយ គឺមានតែយក្សក្ខិណីរស់នៅ (សូមស្រាវជ្រាវបន្ថែមនៅក្នុងគម្ពីរព្រះត្រៃបិដក គម្ពីរមហាវង្ស)។ តើសេះអុកដែលធនជ័យក្ដាប់នឹងដៃ និងរូបសេះដែលមានតែក្បាលនៅប្រាសាទនាគព័ន្ធ មានអត្ថន័យផ្សេងគ្នា ឬដូចគ្នា? សេះដែលមានតែក្បាលអត់មានជើងដែលខ្ចីជើងធនជ័យឲ្យជួយរត់ទៅដល់ទីណាត់របស់ស្ដេចបាន ធ្វើឲ្យធនជ័យបានរួចពីសេចក្ដីស្លាប់ តើប្រស្នានេះនិពន្ធជូនតាចង់ឲ្យយើងមើលឃើញពីរឿងអ្វី? ពួកគាត់ចង់ឲ្យយើងមើលសេះមានតែក្បាល មាតាមហានគរមានតែក្បាល រាជសីហ៍មានតែក្បាល ដំរីមានតែក្បាលនាគមានតែក្បាល ដែលរូបនាគភាគច្រើនតែងព័ទ្ធជុំវិញថែរក្សាប្រាសាទពីបុរាណ ព្រហ្មមានតែក្បាល ព្រោះហេតុតែល្បែងភ្នាល់រឿងប្រស្នាសិរីបីប្រការ។ រូបសេះកូនអុក និងរូបសេះចម្លាក់ប្រាសាទនាគព័ន្ធ គឺមិនមានជើងដូចគ្នា ហើយនិមិត្តរូបសេះនេះ គឺជានិមិត្តរូបផ្កាយ ក្នុងដំណើរចន្ទគតិ មានឈ្មោះថាខែអស្សុជ។ និពន្ធជូនតាចង់ឲ្យធនជ័យស្វែងរកតួខ្លួនឲ្យសេះ រាជសីហ៍ ដំរី ព្រហ្ម មាតាមហានគរ... ដើម្បីភ្ជាប់ក្បាលនឹងតួខ្លួន រួចធ្វើដំណើរទៅទីស្ថានផ្កាយវិញ ព្រោះពូជខ្មែរជាពូជទេវតា ឬផ្កាយ ដែលមាននិមិត្តរូបសត្វ ហើយទាក់ទងនឹងផ្កាយ មាននៅក្នុងរឿងធនជ័យជាតឹកតាងស្រាប់។

ង.ការផ្ដាញ់ធនជ័យលើកទីប្រាំ ស្ដេចទៅប្រពាតព្រៃដដែល ដោយលើកនេះ គឺទៅដោយយានជំនិះដំរី ស្ដេចបានឲ្យដំរីចាស់ជរាហើយពិការថែមទៀត ប្រគល់ឲ្យធនជ័យដឹកជញ្ជូនស្បៀង និងក្រយាស្ងោយរបស់ស្ដេច ដោយបញ្ជាបង្គាប់ទៅធនជ័យថា បើដឹកជញ្ជូនទៅមិនទាន់ និងត្រូវមានទោស។ ដើម្បីដោះសារឲ្យរួចពីទោស ព្រោះការដឹកជញ្ជូនក្រយាស្ងោយទៅពុំទាន់ ដោយហេតុដំរីចាស់នឹងមានជំងឺ ធនជ័យបានយកក្ដោងមកចងនៅលើ

រយោងដំរីផង ប្រើដងថ្នោលសម្រាប់ដោលផង។ នេះជាភស្តុតាងបង្ហាញប្រាប់ស្ដេចថា ខ្លួនខំប្រឹងប្រែងប៉ុណ្ណឹងហើយ ក៏នៅតែមិនអាចដើរឲ្យទាន់ដំរីរបស់ព្រះអង្គបានឡើយ ព្រោះដំរីដែលជាយានរបស់ធនជ័យ ជាដំរីចាស់ហើយពិកា ដូច្នេះស្ដេចពុំអាចចាប់ទោសកំហុសធនជ័យបានឡើយ តើដំរីចាស់ជរាពិកា និពន្ធដូនតាឲ្យយើងមើលឃើញពីរឿងអ្វី? យសោធបុរទីក្រុងដំរី ឬទីក្រុងអ្នកទាក់ដំរី គឺជាទីក្រុងចាស់របស់នគរខ្មែរ ក្នុងសម័យមហានគរ ទីក្រុងនេះបានក្លាយជាព្រៃរហោស្ថាន បាត់ដានអស់រយៈពេលជាងមួយសតវត្ស កូនខ្មែរជំនាន់ក្រោយការបោះបង់ចោលក្រុងអង្គរ ពុំដឹងថាខ្លួនមានទីក្រុង ដែលសំបូរទៅដោយប្រាសាទថ្មដ៏ស្កឹមស្កៃ ដល់ម្លឹងឡើយ។ ក្នុងរជ្ជកាលស្ដេចអង្គច័ន្ទរាជា ដោយការធ្វើប្រពាតព្រៃ ទើបបានប្រទះឃើញទីក្រុងចាស់ជរានេះឡើងវិញ ដែលត្រូវហ៊ុមព័ទ្ធដោយព្រៃក្លាយជាទីស្មសាន។ ដូច្នេះនិមិត្តរូបដំរីចាស់ក្នុងរឿង គឺជានិមិត្តរូបតំណាងឲ្យទីក្រុងដំរីពីអតីតកាល របស់នគរខ្មែរដែលត្រូវបែកបាក់ទ្រុឌទ្រោមគ្រាំគ្រា ត្រូវបានធនជ័យដាក់ក្ដោងដោលថ្នោល ដឹកជញ្ជូននៅកេរមរតកមេ៉គ្រប់បែបយ៉ាងឡើងមកវិញ។ ចំណែកឯក្បាលដំរីនៅប្រាសាទនាគព័ន្ធ ដែលនៅសល់តែក្បាល បាត់ខ្លួនទឹកហូរចេញតាមមាត់ ដែលទឹកនេះបានហូរចេញពីបេះដូងដំរីស្រែកដង្ហោយហៅកូនខ្មែរជំនាន់ក្រោយ ឲ្យជួយរកតួខ្លួនឲ្យផង។ ចំណែកការបកប្រែភាសាថ្មរបស់ជនជាតិបរទេស នៅប្រាសាទនាគព័ន្ធ ទឹកដែលហូរចេញពីមាត់រូបទាំងបួន គឺជាទឹកមន្តសម្រាប់ព្យាបាលរោគក្នុងធាតុទាំងបួន តើព្យាបាលរោគអ្វី? រោគដែលលំបាកព្យាបាល គឺរោគមិនដឹងគុណ កើតនិងបានរស់នៅហើយរីកចម្រើនធំធាត់ ដោយបានបរិភោគកេរតំណែលមេ៉(មាតុភូមិ) តែបែរជាមិនដឹងគុណម្ចាស់ទឹកដី ម្ចាស់កេរមរតក ទីបំផុតកូនជ័យភាគច្រើនបែរជានាំគ្នាជេរប្រមាថមេ៉ ដែលជាអ្នកមានគុណ ក្នុងអតីត បច្ចុប្បន្ន និងតទៅអនាគត តើសមជាអ្នកទទួលមរតកជ័យដែរឬទេ? ដំរីក្បាលបីដែលស្ថិតនៅលានជល់ដំរីទោះបីជាក្បាលមួយត្រូវបំបែកជាបី ក៏អង្វរឲ្យកូនខ្មែរជំនាន់ក្រោយ ជួយរកតួខ្លួនឲ្យដែរដើម្បីលើកតម្កើងមរតកពូជជ័យឡើងវិញ។

ច.ការផ្ដាញ់ធនជ័យលើកទីប្រាំមួយ ស្ដេចនៅតែរកវិធីសាស្ត្រដើម្បីបង្ក្រាបរួចចាប់ទោសធនជ័យ ដោយបានឲ្យធនជ័យរកក្របីយកទៅបញ្ចូល ស្ដេចបានដាក់អាជ្ញាហាមប្រាមអ្នកមានសត្វក្របីឈ្មោលឡើងក មិនឲ្យធនជ័យខ្ចីសត្វក្របីឡើយ។ ធនជ័យបានចាប់

យកកូនសត្វក្របីទើបនឹងកើតបានដប់ថ្ងៃ ដោយបង្អត់មិនឲ្យបៅដោះ ហើយបានយកកូនក្របីដែលពុំបានបៅដោះនោះ ទៅដាក់ក្នុងទីលានបញ្ចាល់។ កូនក្របីកំពុងស្ថិតក្នុងសេចក្ដីស្រេកឃ្លាន គ្រាន់តែឃើញក្របីធំភ្លាម វាស្ទុះរត់ទៅបៅផ្លោកពងរបស់ក្របីឈ្មោលឡើងក ច្រឡំថាជាមេរបស់វា ឯក្របីឡើងកវារសើបរួចក៏ស្ទុះរត់ចេញទៅ ធនជ័យក៏ងើបទះដៃស្រែកហ៊ោម្នាក់ឯងថា ឈ្នះហើយៗ ដោយពុំមានអ្នកណាហ៊ានគាំទ្រគាត់ឡើយ ព្រោះខ្លាចអំណាចស្ដេច។

ក្នុងកាលដែលបញ្ចាល់សត្វមាន់ ធនជ័យយកកូនសត្វមាន់ទៅបញ្ចាល់ ពេលដែលបញ្ចាល់សត្វក្របី ធនជ័យយកកូនសត្វក្របីទៅប្រជល់ទៀត តើនិពន្ធដូនតាចង់ឲ្យយើងយល់ពីបំណងអ្វីរបស់លោក? ហេតុអ្វីនិពន្ធដូនតាមិនយកសត្វគោទៅបញ្ចាល់ បែរជាយកសត្វក្របីទៅវិញ? សត្វក្របីក៏ជានិមិត្តរូបផ្កាយមួយដួងដែរ ក្នុងដំណើរគោចររបស់ច័ន្ទគតិ គឺខែពិសាខ ដែលមានផ្កាយជារូបក្របី នេះជាហេតុដែលនិពន្ធដូនតា ចង់ឲ្យយើងជាកូនខ្មែរស្គាល់ពីពូជផ្កាយមួយដួងទៀត ដែលជានិមិត្តរូបតំណាងឲ្យពូជជ័យ គឺជាពូជផ្កាយ។ ពាក្យថាក្របី វាស្មើនឹងពាក្យក្របីដង(ក្រ ក្រ ក្រ) តើក្របីដងមានន័យដូចម្ដេច? ក្រទីមួយ គឺក្ររួចពីភក់ ព្រោះទម្លាប់អធ្យាស្រ័យរបស់សត្វក្របីនេះ តែងតែដេកក្នុងភក់។ ក្រទីពីរ គឺក្របានរួចពីនឹម ព្រោះសត្វក្របីគឺជាសត្វពាហនៈ ដែលកសិករតែងចិញ្ចឹមសម្រាប់ទឹមភ្ជួររាស់ នឹងអូសរទេះ... ក្នុងកិច្ចការងារកសិកម្ម។ ក្រទីបី គឺក្ររួចពីអត្តភាពសត្វតិរច្ឆាន ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងប្រោសចំពោះនាគរាជ ដែលនាគរាជនោះ ពីជាតិមុនធ្លាប់បានបួសជាភិក្ខុពីរម៉ឺនឆ្នាំ ក្នុងសាសនាព្រះសម្មាសម្ពុទ្ធកស្សប ដែលមនុស្សក្នុងសម័យនោះមានអាយុខែពីរម៉ឺនឆ្នាំ។ ដោយភិក្ខុអង្គនោះត្រូវអាបត្តិ ហើយពុំបានសម្ដែងចេញ នៅពេលដែលរៀបនឹងចុតិចិត្ត(ស្លាប់) ធ្វើឲ្យចិត្តលោកក្ដៅក្រហាយ នៅអាបត្តិដែលពុំបានសម្ដែងនោះ នាំឲ្យគតិរបស់លោក ទៅបដិសន្ធិកើតជានាគ មានខ្លួនប៉ុនទូក។ មួយចន្លោះព្រះពុទ្ធទៅហើយ គឺពីព្រះពុទ្ធសាសនាព្រះកស្សប រហូតមកដល់ព្រះពុទ្ធសមណគោតមបរមគ្រូនៃយើង នាគរាជនៅតែជាសត្វតិរច្ឆានដដែល គឺពុំអាចក្លាយអត្តភាពជាមនុស្សឡើយ។ ទើបព្រះអង្គទ្រង់ត្រាស់សម្ដែងថា «ការបានកើតមកជាមនុស្សគឺជាការក្រ កើតជាមនុស្សហើយត្រូវចិញ្ចឹមជីវិតបានដោយការក្រហើយជីវិតសត្វនេះថែរក្សាបានដោយការក្រ ការបានស្ដាប់នៅព្រះធម៌ជាការក្រ ការ

បានត្រាស់ដឹងឡើងនៃព្រះសម្មាសម្ពុទ្ធទាំងឡាយជាការក្រក្រៃពេកណាស់ ព្រោះត្រូវសន្សំនៅបារមីឲ្យបានសម្រេចនៅអភិនិហា គឺត្រូវខិតខំប្រឹងប្រែងព្យាយាមដ៏ធំ រាប់ដោយអនេកកប្បកោដិផែនដី»។

ដូច្នេះសត្វក្របីក្នុងរឿងធនជ័យ ដែលនិពន្ធដូនតាមិនបានយកឈ្មោះសត្វគោទៅបញ្ចូល បែរជាយកសត្វក្របី ព្រោះលោកចង់ឲ្យពូជជ័យជំនាន់ក្រោយ ស្រាយអត្ថន័យពាក្យក្របី ក្រទីមួយ ទីពីរ និងទីបីនឹងឲ្យយើងមើលរឿងមាតាមហានគរ ដែលលោកជាប់នៅក្នុងភក់ ហើយភក់នោះបានរឹងក្លាយជាថ្ម(ថ្មភក់) ដោយខ្លាចក្រែងកូនជ័យជំនាន់ក្រោយពុំចាប់ភ្លឹកនឹកឃើញ លោកបានដាក់នាមប្រាសាទមួយឈ្មោះថា ប្រាសាទតាក្របី តើប្រាសាទតាក្របីមានន័យដូចម្ដេច? ន័យទីមួយគឺក្របីយ៉ាង ដែលបានពន្យល់រួចហើយ ន័យទីពីរហេតុម្ដេចក៏តាក្របីមាតាមហានគរចេញពីភក់គឺអបាយភូមិម្ល៉េះ ព្រោះប្រាសាទនេះគាត់កសាងឡើងក្នុងជួរភ្នំដងរែក(មើលការពន្យល់ពីភ្នំដងរែកក្នុងបណ្ដាំមាតាមហានគរក្មេរ)។

ឆ.ការផ្ចាញ់ធនជ័យលើកទីប្រាំពីរ ដោយការខកចិត្ត ក្នុងការចាប់ទោសកំហុសធនជ័យច្រើនដងច្រើនសារតែពុំបានសម្រេច ស្ដេចក៏ប្រើឲ្យធនជ័យទៅបោសសំរាមក្រោមរាជដំណាក់ ដើម្បីបង្អាប់កិត្តិយសអ្នកប្រាជ្ញរូបនេះ។ ស្រីស្នំមេនំមេនាងទាំងឡាយ ពេលដឹងថាធនជ័យទៅបោសសំរាមក្រោមរាជដំណាក់ ក៏បបួលគ្នាទៅទន្ទ្រាំជើងនៅពីលើក្បាលធនជ័យដើម្បីជួយបញ្ឈឺជំនួសស្ដេច។ ធនជ័យក៏រកវិធីជេរស្ដីឲ្យពួកស្រីៗទាំងនោះ ដោយពោលថាមេចោរដកទងទាំងនេះ វាបានស៊ីក៏ព្រោះគូទមិនបានស៊ីក៏ព្រោះគូទ។ ពេលដែលធនជ័យស្រែកជេរខ្លាំងៗរួចហើយ សម្លេងជេរក៏ឮដល់ពួកស្រីៗទាំងនោះ ពួកនាងខឹងនឹងធនជ័យយ៉ាងខ្លាំងហើយបានយកពាក្យនេះទៅទូលពិតស្ដេច ដើម្បីឲ្យស្ដេចចាប់ទោសធនជ័យ។ ក្រោយពីបានស្ដាប់ពាក្យប្ដឹងរបស់ស្រីៗទាំងនោះហើយ ស្ដេចក៏កោះហៅធនជ័យឲ្យឡើងមកគាល់ រួចសួរធនជ័យតាមដំណើររឿង ធនជ័យក៏បានទូលទៅស្ដេចវិញថា ខ្ញុំព្រះអង្គចូលទៅបោសក្រោមរាជដំណាក់ បានជាប់ក្បាលនឹងសំបុកពីងពាង ខ្ញុំខឹងនឹងមេពីងពាងទាំងនោះ ទើបខ្ញុំជេរពួកវា ព្រោះសត្វពីងពាងទាំងនេះ បានរស់បានស៊ីគឺដោយសារគូទ។ ស្ដេចក៏មានព្រះឱង្ការតបទៅពួកមេនំមេនាងទាំងនោះថា អាជ័យវាជេរសត្វពីងពាងទេ វាពុំមែនជេរពួកនាងឡើយស្រីៗទាំងនោះ ក៏សំណូមពរស្ដេច ឈប់ឲ្យធនជ័យទៅបោសក្រោមរាជដំណាក់ទៀត។

ក្រោយពេលដែលធនជ័យទៅបោសក្រោមរាជដំណាក់នោះ គាត់បានដឹងពីអាថ៌កំបាំងពាក្យ មេរត ពីមុនមេរតនេះ នៅខាងលើយើងហៅថាមេដំបូល ហេតុអ្វីបានជាក្លាយមកជាមេរត ត្រូវទ្រនៅខាងក្រោមរនាប រួចគេក្រាលកន្ទេលឬព្រំបន្ថែមពីលើទៀត ធ្វើដូចម្ដេចយើងអាច មើលឃើញមេរតបាន? លុះត្រាតែចូលបោសពីខាងក្រោមដំណាក់ដូចធនជ័យ ទើបឃើញ មេរតនេះបាន(សូមមើលការពន្យល់ពី ជនាង ជីនាង ជុំនាងនៅក្នុងបណ្ដាំមាតាបិតាមហា ព្រហ្មភាគ៤)។ ការដាក់ទណ្ឌកម្មឲ្យធនជ័យ ចូលទៅបោសក្រោមព្រះរាជដំណាក់នោះ ទី មួយគឺធនជ័យបានដឹងពីអាថ៌កំបាំងព្រះមេ ដែលពីមុនលោកជាព្រះកន្លោង(សសរកន្លោង) ចុងក្រោយលោកបានធ្លាក់ខ្លួន ក្លាយជាមេរត ទីពីរគាត់ត្រូវគេដើរជាន់ពីលើ គេមើលងាយ គេជេរ ជាពិសេសគឺពូជជ័យដែលជាកូន ដូច្នេះទើបយើងមានរឿងអាជ័យមេរត ឬមេត្រត (ត + រត)។

ជ.ការផ្ចាញ់ធនជ័យលើកទីប្រាំបី ការទទួលបរាជ័យជាបន្តបន្ទាប់ ធ្វើឲ្យស្ដេចកាន់តែ ស្អប់ធនជ័យខ្លាំងឡើងៗ រហូតដល់ដាក់អាជ្ញាមិនឲ្យធនជ័យចូលវាំង ដោយស្អប់មុខធន ជ័យ។ ធនជ័យបានដឹងថា រាល់ថ្ងៃឧបោសថព្រះករុណាតែងនិមន្ត ព្រះចៅអធិការទៅទទួល ចង្ហាន់ និងសម្ដែងធម៌នៅក្នុងព្រះរាជវាំង។ ធនជ័យបានទៅជួបពួកនាម៉ឺនមន្ត្រី ដែលជួបជុំគ្នា ក្នុងសាលាជំនុំហើយពោលថា ថ្ងៃនេះព្រះករុណានឹងហៅខ្ញុំចូលគាល់ ពួកមន្ត្រីទាំងនោះនាំ គ្នាចំអកឲ្យធនជ័យ ធនជ័យបានពោលថា បើមិនជឿភ្នាល់ដោយអ្នកចាញ់ត្រូវបង់ប្រាក់ ពួក នាម៉ឺនមន្ត្រីក៏ព្រមធ្វើកិច្ចសន្យាជាមួយធនជ័យ អ្នកចាញ់ត្រូវបង់ប្រាក់។ ឱកាសនោះ ព្រះ ចៅអធិការបាននិមន្តមកដល់រាជវាំង ធនជ័យបានទៅស្ទាក់ថ្វាយបង្គំព្រះអង្គ ហើយបាន ពោលពាក្យជាប្រស្នាទៅកាន់ព្រះចៅអធិការថា «មើលមកសក់ខ្ញុំប្រៀបដូចសក់ក្អោក មើល ទៅក្បាលលោកដូចត្រពោកខ្ញុំ» ។ ព្រះចៅអធិការពេលដែលបានសណ្ដាប់ពាក្យនេះហើយ សេចក្ដីខឹងក្រោធក៏កើតឡើង ហើយបាននិមន្តពាំនាំយកពាក្យមើលងាយនេះ ទៅប្ដឹងដល់ ស្ដេច ដើម្បីឲ្យស្ដេចជួយរកយុត្តិធម៌ឲ្យ។ ពេលដែលស្ដេចបានសណ្ដាប់ ពាក្យព្រះចៅអធិការ ទូលពិតហើយ ក៏កោះហៅធនជ័យឲ្យចូលវាំង ដើម្បីសួររកហេតុផល ពីការតិះដៀលនេះ។ ពេលដែលធនជ័យចូលមកគាល់ ក៏បានទូលប្រាប់តាមដំណើរថា ខ្ញុំព្រះអង្គពុំបានពោលត្មះ តិះដៀលត្រួសត្រាជឡើយ ខ្ញុំគ្រាន់តែប្រៀបធៀបក្បាលខ្ញុំមានសក់ល្អដូចជាសក់ក្អោក តែពុំ

បានចូលវាំង ចំណែកព្រះសិរសាព្រះអង្គរលោងដូចជាត្រពោក(គូទ)ខ្ញុំ ហើយលោកមានសំណាងជាងបានស្ដេចនិមន្តចូលវាំង។ ស្ដេចសណ្ដាប់ពាក្យដោះសារនេះហើយ ក៏មានព្រះរាជឱង្ការតបព្រះថៅអធិការថា លោកម្ចាស់កុំខ្ញាល់ឡើយ អាជ័យវាប្រៀបធៀបខ្លួនវាទេ។ ហេតុអ្វីបានជាធនជ័យពោលពាក្យទាំងនេះ? និពន្ធនិទានលោកចង់ប្រាប់យើងឲ្យដឹងថា សមណសក្យបុត្រ ត្រូវរក្សានូវចិត្តត្រូវតែមានខន្តីអត់ធ្មត់ ទប់ទល់នឹងសេចក្ដីក្រោធ ទោះបីជាមានគេពោលតិះដៀលជេរប្រមាថ ក៏ព្រះអង្គឲ្យអត់ទ្រាំ ដូចកាលពួកនិគ្រន្ថមួលបង្កាច់ដោយប្រើនាងសុន្ទរីឲ្យក្លែងធ្វើកិច្ច ចោទថាសាហាយស្មន់ជាមួយព្រះអង្គ ដូចនាងចិញ្ចាពោលចោទព្រះអង្គ ដូចព្រះនាងមាគន្ទិយជួលគេឲ្យទៅជេរព្រះអង្គ ព្រោះហេតុតែគុំនឹងព្រះអង្គ ពោលតិះដៀលពីរូបរាងកាយ......។ល។ និពន្ធនិទានលោកចង់ឲ្យយើងបានដឹងថា ធនជ័យពុំបានជេរលោកគ្រូសង្ឃ្រាជឡើយ គ្រាន់តែពោលដោយពាក្យប្រស្នាប្រៀបធៀបតែប៉ុណ្ណោះ ក៏សមណអង្គនេះពុំអាចអត់ធ្មត់ខន្តីអប់រំចិត្ត ទប់នៅសេចក្ដីក្រោធបាន។ ដូច្នេះសមណអង្គនេះ ពុំបានធ្វើដំណើរតាមគន្លងព្រះពុទ្ធបិតាវិវដ្ដ(ព្រះអង្គជាមាតាផង ជាបិតាផង ព្រោះព្រះអង្គប្រសូត្រព្រះសង្ឃទាំងភិក្ខុ ភិក្ខុនី សាមណេរ សាមណេរី ឧបាសក ឧបាសិកា) គឺនៅមានចិត្តស្រោលដូចជាគ្រហស្ថធម្មតានៅឡើយ។

ឈ.ការផ្ចាញ់ធនជ័យលើកទីប្រាំបួន ដោយខឹងនឹងធនជ័យ ជាច្រើនលើកច្រើនសារ ស្ដេចបានប្រើមេនំមេនាង ឲ្យទៅជុះអាចម៍ដាក់ផ្ទះធនជ័យ បើធនជ័យហ៊ានហាមឃាត់ស្ដេចនឹងចាប់យកទោស។ ពេលដែលស្រីៗទាំងនោះទៅដល់ផ្ទះធនជ័យ ពួកនាងបានប្រាប់ធនជ័យថា ស្ដេចប្រើឲ្យមកជុះអាចម៍ដាក់ផ្ទះជ័យឯង ធនជ័យក៏សួបញ្ជាក់ថា ស្ដេចប្រើមកតែជុះអាចម៍ទេឬ? នាងៗឆ្លើយព្រមគ្នាថាចាំះ ធនជ័យពោលថាជុះអាចម៍ជុះបាន តែកុំជុះនោម បើឃើញជុះនោមនឹងដឹងគ្នាហើយ។ ធម្មតាការបន្ទោរបង់លាមក វាត្រូវតែមានការបន្ទោរបង់នៅទឹកមូត្រមកជាមួយ ព្រោះវាជាធម្មជាតិត្រូវបញ្ចេញមកព្រមគ្នា គឺពុំអាចបង្អាក់វាបានឡើយ តែដោយស្រីៗទាំងនោះ អាងអំណាចស្ដេចដែលប្រើខ្លួនឲ្យមកជុះ ក៏ឡើងមានះរឹងត្អឹងកើតសេចក្ដីប្រមាថធ្វើឲ្យភ្លេចខ្លួន ត្រូវជុះលេចទាំងនោម និងផោមមកជាមួយផង។ ធនជ័យបានឱកាស ក៏ទាញយករំពាត់ដេញវាយស្រីៗទាំងនោះ ដោយពោលពាក្យបន្ទោសថា ស្ដេចប្រើពួកនាងៗឲ្យមកជុះតែអាចម៍ទេតើ ហេតុអ្វីពួកនាងៗហ៊ានជុះនោមថែមទៀត ដូច្នេះត្រូវ

ល្មើសនឹងរាជអាជ្ញាហើយ ត្រូវទទួលទណ្ឌកម្ម។ ស្រីៗទាំងនោះត្រូវរំពាត់ ធនជ័យ នាំគ្នារត់ទៅរាជវាំងវិញទាំងសេចក្ដីឈឺចាប់និងក្ដៅក្រហាយ ហើយទៅប្ដឹងពិតទូលស្ដេច ព្រះករុណាស្ដាប់ពាក្យទូលពិតហើយ ក៏ប្រើរាជអាមាត្យឲ្យទៅចាប់ធនជ័យយកមកដាក់ទោស។ ពេលធនជ័យមកដល់រាជវាំង ថ្វាយបង្គំរួចក៏ទូលពន្យល់ប្រាប់ស្ដេចថា ពួកនាងៗទាំងនេះល្មើសនឹងរាជបញ្ជាព្រះអង្គ ព្រះអង្គបានដាក់រាជបញ្ជាឲ្យពួកនាងៗទាំងនេះទៅជុះអាចម៍ គេល្មើសដោយហ៊ានជុះនោម ហើយថែមទាំងមានផោមទៀត ដូច្នេះខ្ញុំព្រះអង្គត្រូវតែដាក់ទណ្ឌកម្មពួកនាងៗទាំងនេះជំនួសព្រះអង្គ ស្ដេចសណ្ដាប់ហើយក៏នៅស្ងៀម ព្រោះពុំអាចចាប់ទោសធនជ័យបាន ហើយបន្ទោសនាងៗថែមទៀត។ ក្នុងការផ្ចាញ់នេះអ្នកនិពន្ធនិទាន បានពន្យល់ប្រាប់ឲ្យយើងដឹងនឹងពិចារណាថា លាមកមូត្រមិនថារបស់សត្វ ឬមនុស្ស សូម្បីតែជារបស់ខ្លួនឯង ក៏យើងគង់ខ្ពើមរអើមដែរ ហេតុអ្វីក្នុងនាមខ្លួនជាព្រហ្ម ជាអ្នកដឹកនាំនគរមួយទាំងមូល បែរជាមានមារយាទទាបយ៉ាងនេះ? គ្រាន់តែកំហឹងតិចតួច ព្រោះស្វែងរកចាប់កំហុសពុំបាន បែរជាប្រើមនុស្សឲ្យទៅជុះអាចម៍ដាក់ផ្ទះអ្នកប្រាជ្ញម្នាក់ ផ្ទះពុំមែនជាបង្គន់ឡើយ អ្នកដែលជុះមូត្រលាមកខុសបង្គន់ ទីមួយគឺកូនក្មេងដែលមិនទាន់ដឹងក្ដី ទីពីរគឺអ្នកជំងឺដែលក្រោកពុំរួច ទីបីអ្នកស្រវឹងដែលបាត់បង់នូវសតិស្មារតី....។ ក្នុងនាមគាត់ជាអ្នកមានបញ្ញាម្នាក់ ទោះបីពុំបានទៅរៀនសូត្រនៅក្នុងសាលាក៏ដោយ ក៏គាត់មានឈ្មោះថាជាអ្នកប្រាជ្ញ ដែលបានសិក្សាពីសង្គមមនុស្ស និងសង្គមធម្មជាតិ។ អ្នកប្រាជ្ញពួកនេះ យើងឃើញភាគច្រើននៅប្រទេសលោកខាងលិច ដូចជាប្រទេសក្រិច ពីបុរាណប្រទេសនេះសំបូរទៅដោយទស្សនវិទូធម្មជាតិ អ្នកដែលមានទស្សនដែលកើតចេញពីឧបនិស្ស័យ ដែលខ្លួនបានសន្សំពីអតីតជាតិ បូកផ្សំនឹងការសិក្សាពីសង្គមនិងធម្មជាតិក្នុបច្ចុប្បន្ន។ មនុស្សមានធម៌មនុស្ស តែបើមនុស្សបាត់បង់នូវធម៌របស់មនុស្ស គឺដូចជាសត្វតិរិច្ឆានយ៉ាងដូច្នោះ ព្រោះសត្វនឹងមនុស្សខុសគ្នាត្រង់ សត្វមិនមានមនសិការ គឺឧបាយធ្វើទុកក្នុងចិត្តដោយត្រូវទំនង។ សត្វមានសេចក្ដីស្រេកឃ្លាន មនុស្សក៏មានសេចក្ដីស្រេកឃ្លាន សត្វមានការត្រេកត្រអាលក្នុងកាម(សេពកាម) មនុស្សក៏មានការត្រេកត្រអាលក្នុងកាម សត្វមានការភិតភ័យពីមរណៈ មនុស្សក៏មានការភិតភ័យពីមរណៈ សត្វមានការស្វះស្វែងរកនូវអាហារ មនុស្សក៏មានការស្វះស្វែងរកនូវអាហារ តែមនុស្សខុសពីសត្វ ព្រោះមនុស្សមានធម្មសញ្ញា ការដឹងខុសដឹងត្រូវ

ដឹងគុណដឹងទោស ដឹងល្អអាក្រក់... ។ល។ មនុស្សយើងពេលដែលបាត់នូវធម្មសញ្ញា តើមានអ្វីខុសពីសត្វ? ពេលខ្លះសត្វអាចប្រសើរជាងដោយសភាវៈ ឧទាហរណ៍សត្វខ្លះមានការស្រឡាញ់កូនថែទាំកូន សូម្បីតែជីវិតក៏ហ៊ានលះបង់ដើម្បីថែរក្សាកូន ដូចជាមេមាន់ ទោះបីជាត្រូវគេក្រុងក្នុងអង្រុត ក៏ខ្លួននៅតែហៅកូនមកនៅជុំវិញអង្រុត ប្រៀបបីដូចជាមាតាមហានគរ ខ្លួនបដិសន្ធិជាបិសាច ឬប្រេតទៅហើយ ក៏នៅតែហួងហែងថែរក្សាមរតកទឹកដី វប្បធម៌សាសនា... ទុកឲ្យកូនខ្មែរជំនាន់ក្រោយ សោយនៅមរតករបស់គាត់។ ក្នុងវគ្គប្រើឲ្យមេនំមេនាង ទៅជុះអាចម៍ដាក់ផ្ទះធនជ័យនេះ ជាសញ្ញាមួយដែលនិពន្ធនិទាន លោកបានពន្យល់ប្រាប់យើងថា ជាដំណាក់កាលស្ដេចខ្លៅនាម៉ឺនខ្លៅ ដូចពស់ធាងត្រាវពេនមាត់ជណ្ដើរ ដែលពាក្យសុភាសិតនេះ ដូនតាសម័យកសាងប្រាសាទភ្នំជីសូរ លោកបានពោលរឿងនិទានប្រចាំភ្នំនិងប្រាសាទ ដោយពោលសុភាសិតទាំងបីនេះទុក សម្រាប់អភិសេកស្ដេចឡើងសោយរាជ្យដែលខ្ញុំបាទបានចាំមកគឺ «សូមឲ្យព្រះអង្គមានឫទ្ធិដូចខ្មោច មានកម្លាំងដូចស្រមោច មានចិត្តមុតដូចស្រី» និងសុភាសិតមួយទៀត «ស្ដេចខ្លៅនាម៉ឺនខ្លៅ ដូចពស់ធាងត្រាវពេនមាត់ជណ្ដើរ ស្ដេចប្រាជ្ញនាម៉ឺនមហិទ្ធាយក្ស ដូចពស់ពភ្លាក់ពេនមាត់ជណ្ដើរ ស្ដេចប្រាជ្ញនាម៉ឺនប្រាជ្ញដូចពស់នាគរាជពាំកែវមនោរា»។

## IV.អ្នកប្រាជ្ញចិនមកចោទប្រស្នាយកនគរលើកទី១

ការផ្ចាញ់ផ្ចាលធនជ័យជាបន្តបន្ទាប់ ដើម្បីចាប់ទោសធនជ័យ តែពុំបានសម្រេច ដំណឹងនេះបានឮខ្ចរខ្ចាយ ផ្សាយទៅដល់នគរចិន ធ្វើឲ្យស្ដេចក្រុងចិនមានបំណងចង់យកនគរខ្មែរដាក់ជាចំណុះរបស់ខ្លួន ព្រោះហេតុតែមានអ្នកប្រាជ្ញកើតឡើង។ ដូចនេះស្ដេចចិនបានប្រជុំអ្នកប្រាជ្ញខ្លួន ដាក់នូវចំណោទប្រស្នា ហើយឲ្យអ្នកប្រាជ្ញខ្លួនទាំងនោះ ចុះសំពៅធ្វើដំណើរមកស្រុកខ្មែរ ដោយយកចំណោទប្រស្នាទាំងនោះ ឲ្យស្ដេចខ្មែរដោះ បើដោះពុំរួចនឹងយកនគរធ្វើជាចំណុះ។ ពេលអ្នកប្រាជ្ញចិនមកដល់នគរខ្មែរ ក៏បានឡើងគាល់ស្ដេច ហើយក៏បានប្រាប់ពីរាជបំណងរបស់ស្ដេចខ្លួន ក្នុងការដាក់ចំណោទប្រស្នាភ្នាល់ បើដោះមិនរួចនឹងយកនគរខ្មែរដាក់ជាចំណុះរបស់ខ្លួន។ ស្ដេចសណ្ដាប់រួចហើយ មានសេចក្ដីភិតភ័យយ៉ាងខ្លាំង ក៏កោះហៅពួកនាម៉ឺនមន្ត្រី រាជបណ្ឌិត ដែលមាននៅក្នុងរាជវាំងទាំងអស់ ដើម្បីប្រជុំគ្នារកអ្នកមានសមត្ថភាព ដោះប្រស្នាអ្នកប្រាជ្ញចិន។ ក្នុងពេលនោះពុំមាននាម៉ឺន មន្ត្រី រាជ

បណ្ឌិត បុរោហិតណាមួយ មានសមត្ថភាពហ៊ានទប់ទល់ នឹងអ្នកប្រាជ្ញចិនបានឡើយ ទើបស្ដេចពិចារណាឃើញថាមានតែអាជ័យទេ ហើយវាជាអ្នកនាំភ្លើងឲ្យគេយកប្រស្នាមកចោទ បើវាដោះប្រស្នាអ្នកប្រាជ្ញចិនពុំរួច យើងនឹងចាប់ទោសវាយកទៅសម្លាប់ចោល ក៏ប៉ុន្តែបើវាដោះប្រស្នារបស់អ្នកប្រាជ្ញចិនរួច នឹងបានរួចខ្លួន រួចក៏ប្រើរាជអាមាត្រនាំរាជបញ្ជាប្រគល់ឲ្យធនជ័យ ដើម្បីទៅដោះប្រស្នាចំណោទរបស់អ្នកប្រាជ្ញចិន។ បរទេសជាច្រើន ដែលធ្លាប់ធ្វើទំនាក់ទំនងមកលើនគរក្មែរ ហេតុអ្វីនិពន្ធនិទាន ជ្រើសរើសយកនគរចិន មកដាក់ជាចំណោទក្នុងរឿងរបស់លោក? ប្រស្នានេះគឺជាចំណោទដ៏ជ្រៅមួយ ដែលនិពន្ធដូនតាទុកឲ្យយើងឆ្ងល់ រួចពិចារណាស្វែងរកនៅចម្លើយ ដែលលោកបានដោះប្រស្នាជាបន្តបន្ទាប់ នៅក្នុងសាច់រឿងរបស់លោក គឺដូនតាយើងលោកចងជាប្រស្នាផង លោកស្រាយនៅប្រស្នាផង លោកចងជាពាក្យទំនាយផង លោកស្រាយទំនាយផង នៅពេលដែលយើងយល់ពីបំណងប្រាថ្នានៅក្នុងចិត្តគំនិតរបស់លោក។

ក្នុងសាច់រឿងនិពន្ធនិទានបានពន្យល់ប្រាប់យើងថា តួអង្គធនជ័យពុំមែនជាគ្រូទាយឡើយ គាត់គ្រាន់តែជាមនុស្សសាមញ្ញម្នាក់ តាំងតែពីតូចរហូតមកទល់នឹងពេលដោះប្រស្នាចិននេះ គាត់ពុំដែលធ្លាប់បានចូលសិក្សារៀនសូត្រម្ដងណាឡើយ។ ប្រស្នាដែលចិនយកមកឲ្យគាត់ដោះនេះ គឺឲ្យគាត់ទស្សន៍ទាយគ្រាប់ក្នុងផ្លែឪឡឹកទាំងបី ហេតុនេះគាត់ពិចារណាថាគាត់ពុំអាចដឹងបានឡើយ បើគាត់ទាយខុសគាត់ចាញ់ នគរនឹងបាត់បង់ក្លាយជាចំណុះរបស់គេ តែបើគាត់ស្លាប់កិច្ចនេះអាចធូរស្រាល ហើយបើគាត់ដោះប្រស្នាពុំរួច ក៏គង់តែទទួលទោសស្លាប់ពីស្ដេចដែរ។ ពេលយប់មកដល់ ធនជ័យក៏សម្រេចចិត្តទៅលោតទឹកសម្លាប់ខ្លួនដើម្បីបញ្ចប់នូវបញ្ហា ដែលគាត់បានគិតទុកជាមុន គាត់សុខចិត្តស្លាប់ដោយពុំឲ្យនគរក្លាយជាចំណុះរបស់គេ តើទឹកជានិមិត្តរូបអ្វី? ប្រស្នាផ្លែឪឡឹកទាំងបីជានិមិត្តរូបអ្វី?

ក.ទឹកជានិមិត្តរូបតាងឲ្យម៉ែ ព្រោះម៉ែមានធាតុទឹក១២ ឪពុកមាននិមិត្តរូបធាតុដី២១ ដែលនិមិត្តរូបនេះ អាចារ្យមួយចំនួនសព្វថ្ងៃ បានយកមកធ្វើជាគុណម្ដាយ១២ គុណឪពុក២១ តើគុណម្ដាយត្រឹម១២ រួចគុណឪពុកត្រឹម២១ឬ? សូមមើលការពន្យល់ក្នុងអច្ឆរបណ្ដាំមាតាមហានគរក្មែរភាគ២ ត្រង់ប្រាសាទភ្នំបូក។ ក្នុងវគ្គគាត់លោតទឹកសម្លាប់ខ្លួនលើកទីមួយនេះ គាត់ត្រូវបានជួបនិមិត្តរូបម៉ែ ដែលជាមេនាគទីមួយផង(ព្រះម៉ែមហានគរ) និងមេ

នាគទីពីរ(ម៉ែបង្កើតរបស់គាត់)ផង ដែលនិមិត្តរូបព្រះម៉ែនេះ ជួយគាត់ឲ្យរួចផុតពីមរណភ័យ ដោយឲ្យរូបគាត់ទៅទើរនឹងសំពៅរបស់អ្នកប្រាជ្ញចិន ធ្វើឲ្យគាត់បានស្ដាប់ការចរចាបក ស្រាយពីចម្លើយប្រស្នាទាំងនោះ។ ត្រង់វគ្គរឿងធនជ័យនេះ និងរឿងកបិលមហាព្រហ្មគឺដូច គ្នា ធម្មបាលកុមារ ពេលដែលដោះប្រស្នាសិរីបីប្រការរបស់មហាព្រហ្មពុំរួច កុមារធម្មបាលក៏ ទៅអង្គុយក្រោមដើមឈើធំមួយដោយអស់សង្ឃឹម ខណៈនោះមេឥន្ទ្រីនិងកូនឥន្ទ្រី បាន និយាយគ្នាពីរឿងថ្ងៃស្អែកបានស៊ីសាច់ធម្មបាល នឹងបានស្រាយប្រស្នាមហាព្រហ្មប្រាប់កូន ឥន្ទ្រីដែលសួរ។

ធម្មតាផ្លែឪឡឹកជាទូទៅ ពុំដែលមានផ្លែឪឡឹកណា ផ្លែទីមួយមានគ្រាប់មួយ ផ្លែទីពីរ មានគ្រាប់ពីរ ផ្លែទីបីមានគ្រាប់បីនោះឡើយ គឺផ្លែឪឡឹកភាគច្រើន មានគ្រាប់ច្រើន ហេតុអ្វី ផ្លែឪឡឹកចិននៅក្នុងរឿងធនជ័យមានតែគ្រាប់១ ២ ៣ ? ប្រស្នានេះនិពន្ធនិទាន លោកចង់ឲ្យ យើងស្ដាប់រួចឆ្ងល់ដើម្បីគិត ហើយដោះប្រស្នារបស់លោក តើឪឡឹកជាអ្វី? គ្រាប់ឪឡឹកជាអ្វី? ពាក្យថាឪឡឹក គឺមានពាក្យ **ឪ + ឡឹក** ឪគឺពាក្យឪពុក អ្នកជនបទស្រែចំការភាគច្រើនហៅ ឪពុកថាឪៗ គឺមិនប្រើពាក្យទាំងពីរម៉ាតជាប់គ្នាឡើយ អ្នកខ្លះហៅឪពុកថាពុកៗ នេះជាភាសា និយាយសម្រាប់អ្នកជនបទ។ ចំណែកពាក្យឡឹក ទំនងកម្លាយពីពាក្យថាសឹក គឺលាចាកសិក្ខា បទ(២២៧) ព្រោះភាគច្រើននៃកុលបុត្រពីជំនាន់មុន ចង់ចេះចង់ដឹងត្រូវទៅបួសរៀននៅក្នុង វត្តអារាម អ្នកខ្លះបួសរៀនរហូតដល់ជ្រុះសក់ ទំពែករួមទាំងកោរសក់ផងក្បាលឡើងរលោង ដូចជាផ្លែឪឡឹកនៅក្នុងចំការ។ ដូចនេះអ្នកទើបនឹងសឹក ឬលាចាកសិក្ខាបទ គឺមានក្បាល រលោងដូចជាក្បាលឪបួសរួចទើបនឹងសឹក មានន័យថាក្បាលឪដែលបួសរៀនហើយ សឹកមក ថ្មី គឺឡើងរលោងដូចផ្លែឪឡឹក(ក្បាលរលោងដូចក្បាលឪទើបនឹងសឹក ⇨ ឪឡឹក)។

សាច់ឪឡឹកភាគច្រើនមានពណ៌ក្រហមព្រឿង គ្រាប់ឪឡឹកដូចជាទារកដែលជាប់នៅ ក្នុងគភ៌ ឬស្បូន បើមើលតាមអេកូទូរទស្សន៍ ឆ្លុះមើលទារកសព្វថ្ងៃ យើងឃើញទារកដេក ត្រាំនៅក្នុងទឹកពណ៌ក្រហមព្រឿង ដូចជាសាច់ឪឡឹក។ ទារកនោះអង្គុយលើអាហារចាស់ (លាមក) ទូលអាហារថ្មី ដៃកាន់ទងផ្ចិត(ទងសុក)ជញ្ជាក់ក្នុងមាត់ អង្គុញជង្គង់ ត្រាំក្នុងឈាម ប្រៀបដូចគ្រាប់ឪឡឹកត្រាំនៅក្នុងផ្លែឪឡឹក។ ប្រស្នាផ្លែឪឡឹកទាំងបីផ្លែរបស់ចិននេះ ផ្លែទីមួយ មានគ្រាប់មួយ (ពូជមួយ) ផ្លែទីពីរមានគ្រាប់ពីរ(ពូជពីរ) ផ្លែទីបីមានគ្រាប់បី(ពូជបី) គ្រាប់ផ្លែទី

មួយនិងគ្រាប់ផ្លែទីពីរបូកចូលគ្នាបានបី ចំណែកផ្លែទីបីមានគ្រាប់ចំនួនបី គឺស្មើចំនួនគ្រាប់ផ្លែទីមួយ និងទីពីរបូកបញ្ចូលគ្នា។ ចំនួនបូកបញ្ចូលគ្នានេះ បើតម្រៀបលេខជាប់គ្នា បានលេខ ៣៣ ដែលជាតួព្យញ្ជនៈក្មែរទាំង៣៣តួ ហើយតួព្យញ្ជនៈទាំង៣៣នេះស្មើនឹងធាតុទឹកនិមិត្តរូបម៉ែ១២ ⇨ ១ + ២ = ៣ ធាតុដី២១និមិត្តរូបឪពុក២១ ⇨ ២ + ១ = ៣។ លេខ៣និមិត្តរូបម៉ែ និងលេខ៣និមិត្តរូបឪពុក បង្កើតបានលេខ៣៣ តំណាងឲ្យព្យញ្ជនៈ និងប្រស្នាគ្រាប់ឪឡឹក ដែលគ្រាប់ឪឡឹកក្នុងផ្លែទាំងបី ជានិមិត្តរូបម៉ែឪជាប់ឃុំ ក្នុងសាច់សំបកផ្លែឪឡឹកឬជាប់ក្នុងគភ៌ រងចាំឲ្យកូនជ័យបំបែកប្រស្នាផ្លែឪឡឹក ដែលអ្នកប្រាជ្ញចិនយកមកចោទជាបញ្ហាសម្រាប់ភ្នាល់យកនគរ ដែលអ្នកកាន់ផ្លែឪឡឹកមក ពុំមែនជាជនជាតិឥណ្ឌា ជ្វា សៀម យួន ...... តែគឺជាចិន។ ម្យ៉ាងទៀតផ្លែឪឡឹកទាំងបី គឺជានិមិត្តរូប តាងឲ្យឪពុក ម្ដាយ កូន សូមមើលការបកស្រាយ នៅក្នុងអាថ៌កំបាំងបណ្ដាំមាតាមហានគរក្មែរទាំងបួនភាគ ដែលបានរៀបរាប់ពីអ្នកទាំងបី គឺជាបឋមក្សត្រម្ចាស់ដែនដីអច្ឆរិយនេះ។

លើកទីមួយដែលចិនចង់បាននគរក្មែរនេះ ពុំមានតែប្រស្នាឲ្យទាយគ្រាប់ក្នុងផ្លែឪឡឹកទាំងបីនោះទេ គឺមានប្រស្នាជាច្រើនទៀត ដូចជាឲ្យស្ដេចសោយសាច់ជ្រូកមួយនាឡិឲ្យបាន២ឆ្នាំ ឲ្យយកសត្វចាបមួយមកធ្វើជាម្ហូប ឲ្យពលចិនទាំង៥០០សំពៅស៊ីបានឆ្អែត ឲ្យស្ដេចស្រុកក្មែរធ្វើយុថ្កា៥០០ក្នុងមួយថ្ងៃឲ្យហើយ ដើម្បីយកមកចងបោះចតសំពៅឲ្យទាន់....។ ក្រោយអ្នកប្រាជ្ញចិនចុះចាញ់ធនជ័យហើយ ធនជ័យឲ្យអ្នកប្រាជ្ញចិនយកតែសំពៅមួយទៅវិញ ក្រៅពីនោះទុកជាជំនូនសម្រាប់អ្នកឈ្នះ។ ស្ដេចមានចិត្តត្រេកអរណាស់ ដោយបានរួចផុតពីភ័យធំនេះ ហើយបានឲ្យរង្វាន់ដល់ធនជ័យ ដើម្បីលើកទឹកចិត្ត ព្រោះធនជ័យបានជួយដោះទុក្ខភ័យពីការប៉ុនប៉ងយកនគរ ធ្វើជាចំណុះរបស់ស្ដេចក្រុងចិន។ ក្រោយពីទទួលបរាជ័យពីសំណាក់អ្នកប្រាជ្ញក្មែរហើយ ស្ដេចក្រុងចិនពុំអស់ចិត្តឡើយ ក្នុងការទទួលបរាជ័យនេះ គេប្រជុំពិភាក្សាគ្នាថា ពេលណាដែលអត់ពីធនជ័យទៅ យើងនឹងត្រឡប់ទៅយកនគរក្មែរជាថ្មីម្ដងទៀត។ រីឯស្ដេចក្មែរវិញ ដោយឃើញប្រាជ្ញាធនជ័យ អាចធ្វើឲ្យអ្នកប្រាជ្ញចិនចុះចាញ់បាន ស្ដេចគិតពិចារណាថា បើទុកអាជ័យឲ្យនៅជិតវាំង ថ្ងៃណាមួយវានឹងដណ្ដើមរាជបល្ល័ង្កអញពុំខាន ដូច្នេះមានតែឲ្យវាទៅនៅជនបទតាមដងទន្លេ តាមតែចិត្តវាចង់នៅចុះ។ ពិចារណារួចក៏ឲ្យរាជអាមាត្យ ទៅហៅធនជ័យឲ្យចូលមកគាល់ ហើយក៏បានប្រាប់តាម

ដំណើរដែលខ្លួនបានគិតទុកនោះ ដោយឲ្យធនជ័យទៅនៅឆ្ងាយពីរាជវាំង ដើម្បីការពារភ័យពីធនជ័យទៅថ្ងៃក្រោយ។ ធនជ័យទៅនៅតាមដងទន្លេ ក៏បានចេញច្បាប់ប្រកាស ឲ្យប្រជាពលរដ្ឋចេះបង់ពន្ធអាករ ក្នុងការធ្វើអាជីវកម្ម តាមដងទន្លេព្រៃកបឹងបួ ធនជ័យដើរដាក់ឈ្មោះភូមិ ស្រុក ទន្លេ បឹងបួ កំពង់ .... នឹងប្រមូលពន្ធដាក់ជារាជទ្រព្យបានជាច្រើន។ ហេតុអ្វីបានជាធនជ័យសាបអង្កាម ពុំសាបស្រូវ រហូតបានក្លាយជាឈ្មោះទន្លេបឹងវាលភក់ដ៏ធំនោះថាជាបឹងទន្លេសាប? ប្រស្នានេះនិពន្ធនិទានចង់ប្រាប់យើងថា ពូជជ័យជំនាន់ក្រោយ ឈប់សាបស្រូវដែលជានិមិត្តរូបពូជថ្មទៀត ស្រូវនេះជាឬសកែវនិមិត្តរូបព្រះមេ(មើលការពន្យល់ពីបាយ) ហើយព្រះមេនេះជាម្ចាស់អត្តសញ្ញាណជាតិខ្មែរ ជាម្ចាស់មរតកកេរតំណែលម៉ែ (បិសាចពស់) ដែលបានសាបព្រោះមរតកអច្ឆរា(អច្ឆរិយ)នេះទុក។ អង្កាមគឺសំបកស្រូវ ពាក្យអង្កាមនេះ បើយើងសម្រាយព្យាង្គតំរូតឲ្យទៅជាព្យាង្គរាយ យើងឃើញសូររបស់ពាក្យបីម៉ាត់ **អ + ង + កាម** មានន័យថា ជាភាសានិយាយអងចុះទៅរកកាមគុណ៥(រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ) យើងឈប់ងើបមើលទៅលើ ដែលជាទីខ្ពស់របស់ពូជនាគ ពូជព្រហ្ម ពូជផ្កាយ ពូជទេវតា ពូជអច្ឆរិយ ពូជប្រាំ។ បើយើងមើលផែនទីប្រទេសខ្មែរយើងទាំងមូល យើងឃើញរូបទន្លេសាប និងបឹងទាំងមូល គឺជារាងនាគមួយបើកពពារ ដែលមានទន្លេជាតួខ្លួន និងបឹងគឺជាក្បាលនាគបើកពពារ ដូចជារូបភាពមើលពីលើនៅតំបន់ភ្នំអង្គរស ដែលជាភ្នំចិនធ្វើពុទ្ធបដិមាសន្ធប់នាគ(មើលរឿងព្រេងប្រចាំភ្នំ) ដូចជារូបរាងរបស់ទន្លេសាប និងបឹង។ ទឹកទន្លេមានរសសាបស្រេចទៅហើយ ហេតុអ្វីត្រូវបន្សាបទឹកទន្លេឲ្យសាបទៀត? អត្ថន័យបង្កប់ក្នុងបឹងទន្លេសាប និពន្ធដូនតាលោកចង់ពន្យល់ប្រាប់យើងថា អ្នកបង្កបង្កើតទឹកដីសុវណ្ណភូមិនេះ ជាអ្នកជាប់ទោសរបស់យក្សឈ្មោះក្រុងរាពណ៍ទៅហើយ ហេតុអ្វីក៏ត្រូវលុបដាន សារដាន លក់ដាន(ក្នុងពិធីមង្គលការ) ធ្វើឲ្យអ្នកជំនាន់ក្រោយពួកគាត់ លែងបានស្គាល់រឿងសាវតាពិតរបស់គាត់? ហេតុនេះទើបនៅក្នុងពិធីមង្គលការ មានពិធីបុកលក្ខ័(លាក់) ធ្វើធ្មេញបន្សាបពិសនាគ ពូជខ្មែរគឺជាពូជនាគៗមានឫទ្ធិអំណាចដោយសារពិស បើនាគអស់ពិសមានអ្វីខុសពីសត្វអន្លង់ ដែលធនជ័យប្រៀបធៀបគំនូរចេញពីម្រាមទាំងប្រាំរបស់គាត់ នៅពេលចិននាំយកប្រស្នាចោទ ដើម្បីយកនគរខ្មែរជាលើកទីពីរ។ ក្នុងពេលនោះអ្នកប្រាជ្ញចិនភ្នាល់គូររូប អ្នកប្រាជ្ញចិនកាន់ជក់រួចជ្រលក់ទៅក្នុងលក្ខ័ខ្មៅ លោតហក់ទៅលើរួចគូសវាស

ទៅលើជញ្ជាំង បានរូបសត្វរាជហង្សមួយ តើសត្វហង្សពិតពណ៌ខ្មៅ ឬក៏ពណ៌មាស? និពន្ធនិទានចង់ពន្យល់ប្រាប់យើងថា សត្វហង្សដែលមានសំបុរដូចមាស ឥឡូវត្រូវចិនជ្រលក់ទឹកខ្មៅ គួរឲ្យទៅជាពណ៌សត្វក្អែក តើសត្វហង្សដែលគូរដោយទឹកលក្ខ័ពណ៌ខ្មៅជាហង្ស ឬជាសត្វក្អែក? ពេលដែលចិនគូរសត្វហង្សរួចហើយ ក៏ប្រើឲ្យធនជ័យគូរម្តង ក្នុងពេលនោះគាត់គិតតែម្នាក់ឯងថា បើគាត់មិនជ្រលក់ទឹកលក្ខ័ខ្មៅគូរទេគាត់នឹងចាញ់ នគរនឹងបានទៅគេ(ជាចំណុះ) បើគាត់ជ្រលក់លក្ខ័ខ្មៅគូរវិញ គ្រាន់តែធ្វើឲ្យពូជនាគប្រឡាក់ពណ៌ខ្មៅ ក្លាយជាអន្ទង់ តែពុំបាត់បង់នគរឡើយ។ ដូច្នេះគាត់ក៏យកម្រាមដៃទាំងប្រាំ ដែលជានិមិត្តរូបពូជផ្កាយ ព្រហ្ម នាគ ទេវតា អច្ឆរិយ..... ជ្រលក់ទៅក្នុងចានទឹកខ្មៅ រួចក៏លោតហក់ទៅគូរវាសគ្រវីគ្រវាត់ចុះក្រោម រួចគាត់ប្រាប់ចិនថា គាត់គូរបានសត្វអន្ទង់ប្រាំ ចិនក៏ព្រមចុះចាញ់គាត់ ព្រោះចិនគូរបានតែសត្វរាជហង្សពណ៌ខ្មៅមួយ។ ហេតុអ្វីធនជ័យ មិនឆ្លើយថាគូរបាននាគប្រាំ ឬក៏ពស់ប្រាំ តែគាត់បែរជាថាគូរបានអន្ទង់ប្រាំទៅវិញ? អ្នកប្រាជ្ញនិពន្ធនិទានរឿង គាត់ចង់ឲ្យកូននាគសម័យក្រោយបានយល់ថា នាគត្រូវគេបន្សាបពិសរួចលាបពណ៌(មនោគមវិជ្ជា) ឲ្យនាគមានពណ៌ផ្សេងៗគ្នា ហើយញុះញង់ឲ្យឈ្លោះដណ្តើមអំណាចគ្នា ព្រោះហេតុតែពណ៌ខុសគ្នា រហូតកើតជាការកាប់សម្លាប់ចងពៀរគ្នា សត្វនាគក្លាយទៅជាសត្វអន្ទង់ តើពូជនាគក្លាយទៅជាសត្វអន្ទង់នៅពេលណា? ន័យទី១នៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ សម័យ០៣ឆ្នាំ ០៨ខែ ២០ថ្ងៃ ចាប់ពីថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ គឺជាថ្ងៃដែលពួកកងទ័ព ដែលមានសំលៀកបំពាក់ពណ៌ខ្មៅ(ខ្មែរក្រហម) បានជំលៀសប្រជាជនចេញពីទីប្រជុំជន ទាំងក្មេងចាស់ ប្រុសស្រី គ្រហស្ថ បព្វជិត សិស្ស និស្សិត បញ្ញាវ័ន្ត អ្នកប្រាជ្ញរាជបណ្ឌិត..... យកទៅធ្វើទារុណកម្ម បង្អត់អាហារ រួចចោទប្រកាន់គ្នាសម្លាប់ជនជាតិឯងយ៉ាងព្រៃផ្សៃ ធ្វើឲ្យអ្នកចេះដឹងទាំងនោះត្រូវលាក់ប្រវត្តិពិតរបស់ខ្លួន មុជចុះទៅក្នុងទឹកកប់ក្នុងភក់ធ្វើជាសត្វអន្ទង់(និមិត្តរូប) ដើម្បីថែរក្សាជីវិតឲ្យរួចផុតពីរបបស្លៀកពាក់ជ្រលក់លក្ខ័ខ្មៅនេះ។ នេះជាហេតុដែលនិពន្ធនិទានធនជ័យ លោកបានយកម្រាមដៃទាំងប្រាំទៅជ្រលក់ក្នុងទឹកលក្ខ័ខ្មៅរបស់ចិន រួចគាត់ពោលថាគូរបានអន្ទង់ប្រាំ មិនថានាគប្រាំ ឬពស់ប្រាំ ព្រោះប្រាំជានិមិត្តរូបពូជផ្កាយ(មើលការពន្យល់លេខប្រាំក្នុងបណ្តាំមាតាបិតាព្រហ្មភាគ៤)។ ពូជផ្កាយ ព្រហ្ម អច្ឆរិយ.... ត្រូវលាបលនដោយទឹកខ្មៅ(អ្នកដឹកនាំគ្រប់គ្រងប្រទេសស្លៀកពាក់ខ្មៅ) ដែលមានចម្លាក់នៅលើថ្មប្រាសាទជា

ភ័ស្តុតាង គឺរូបចម្លាក់នៅក្នុងថែវជញ្ជាំងខាងស្ដាំប្រាសាទអង្គរវត្ត ដូនតាគាត់បានឆ្លាក់រូបមនុស្ស ដែលមានលាបពណ៌ខ្មៅលើខ្លួន។ មនុស្សចម្លាក់ទាំងនោះ ធ្លាក់ចុះថ្នាក់ក្រោមមានខ្លួនសំបុរខ្មៅរូបស្គាំងស្គមដូចជាប្រេត មានអ្នកធ្វើទារុណកម្មមាឌខ្មៅធំៗ ពួកគាត់ចង់បញ្ជាក់ឲ្យយើងមើលនៅនិមិត្តរូបពេលថ្ងៃ គឺយល់សូង ដោយគាត់ចង់ប្រាប់យើងថា ពេលដល់ដំណាក់កាលរូបចម្លាក់លាបលក្ខ័ពណ៌ខ្មៅនោះ ប្រជារាស្ត្រក្នុងនគរនេះធ្លាក់ខ្លួនដូចជាប្រេត ដោយអំណាចពណ៌លក្ខ័ខ្មៅគឺជាពណ៌ងងឹត បង្ហាញពីការធ្លាក់ចុះក្នុងប្រវត្តិដំណើររបស់ពូជនាគ។ ន័យទី២គឺគ្រប់រូបនាគនៅតាមជញ្ជាំង និងផ្ដែរប្រាសាទ ភាគច្រើនខ្លួននាគគឺពុំមានខ្លួនពិតរបស់ខ្លួនឡើយ គឺជាខ្លួនយក្ស ឬសត្វម្ករ រូបចម្លាក់នាគទាំងនេះ នៅកប់ក្នុងភក់ថ្មនៅឡើយ ដូច្នេះនាគដែលនៅកប់ក្នុងភក់ថ្ម ឬថ្មភក់គឺជាសត្វអន្លង់(ប្រស្នាធនជ័យ) លុះត្រាតែដកយកសត្វអន្លង់ទាំងនោះ ចេញពីក្នុងថ្មភក់បានហើយលាងជំរះភក់ចេញ ទើបក្លាយខ្លួនជាសត្វនាគ។ មានន័យថាអ្នកប្រាជ្ញជ័យ លោកឲ្យយើងលាងពណ៌លក្ខ័ខ្មៅឬភក់ ដែលប្រឡាក់លើខ្លួននាគនោះឲ្យជ្រះ ទើបមើលឃើញរូបរាងពិតរបស់សត្វនាគ លែងមើលឃើញជាសត្វម្ករឬអន្លង់ទៀត។ ប្រាសាទអង្គរតូចឬអង្គរវត្ត គឺនិមិត្តរូបក្បាលនាគ តាមការផ្គុំប្រាសាទរបស់ពួកអ្នកស្រាវជ្រាវបរទេស(Discovery) ប្រាសាទអង្គរតូចជាក្បាលនាគ ប្រាសាទអង្គរធំ(បាយ័ន្ត)ជាបេះដូងនាគ ប្រាសាទបន្ទាយសំរែគឺជាចុងកន្ទុយនាគ។ ការផ្គុំផែនទីប្រាសាទនេះ បង្កើតបានជារូបរាងផ្កាយនាគ ឬផ្កាយខ្លែងមួយ ដែលរះនៅទិសខាងជើង សព្វថ្ងៃកូនខ្មែរមួយនគរហៅឈ្មោះផ្កាយនោះថា ផ្កាយក្រពើ ហេតុអ្វីបានជាផ្កាយនាគប្រែឈ្មោះក្លាយទៅជាផ្កាយក្រពើ? យើងអាចដឹងប្រស្នាឈ្មោះផ្កាយនេះបាន យើងទៅមើលល្បែងចាក់ទឹកដូងលើកទីមួយ៖ ចាក់ទឹកដូងចេញពីទ្រូងម៉ែ **កន្ទុយខ្លែងក្មេរពាក់ក្បាលក្រពើ** ក្រពើជិះសេះខ្ញុំជិះដំរី ក្រពើចង់ឆីខ្ញុំឡើងផ្ទះ ក្រពើត្របាក់ខ្ញុំប្រឹងរុល ក្រពើភ្នែកទុលខ្ញុំញីម្ទេស (សូមមើលការបកស្រាយល្បែងចាក់ទឹកដូង នៅក្នុងអាថ៌កំបាំងបណ្ដាំមាតាបិតាមហានគរខ្មែរទាំង៤ភាគ)។ ត្រង់វគ្គកន្ទុយខ្លែងក្មេរពាក់ក្បាលក្រពើ និពន្ធដូនតាបានប្រាប់យើងថា ខ្លែងឯកឬខ្លែងនាគ ដែលធ្លាប់តែហោះនៅលើវេហាបញ្ចេញសម្លេងឯក ផ្សព្វផ្សាយពេញក្នុងលោក ឥឡូវត្រូវពាក់ក្បាលក្រពើ ប្រែក្លាយជាផ្កាយក្រពើ ឬខ្លែងក្រពើ តើសត្វក្រពើដែលជានិមិត្តរូបសត្វរមិលគុណ ហេតុអ្វីអាចទៅបដិសន្ធិក្នុងឋានផ្កាយបាន? អ្នកដែលអាចទៅបដិសន្ធិក្នុងទេវ

លោក ឬឋានផ្កាយបាន គឺមានតែសត្វដែលប្រកបដោយ គុណធម៌គឺការដឹងគុណ(កតញ្ញូនិង កតវេទី) ចុះហេតុអ្វីបានជាឈ្មោះក្រពើ អាចទៅបដិសន្ធិក្នុងទេវលោក ឬឋានផ្កាយបាន? នេះជាចំណោទប្រស្នារបស់អ្នកប្រាជ្ញដូនតាខ្មែរ ដែលលោកឲ្យយើងពិចារណា តើគួរនៅពាក់ក្បាលក្រពើ ឬក៏ត្រូវដោះក្បាលក្រពើចេញ ដើម្បីឲ្យកូនខ្មែរក្លាយជាពូជនាគពិតប្រាកដ ដែលមាននិមិត្តរូបផ្កាយនាគទិសខាងជើង បានបង្ហាញជាតឹកតាងស្រាប់ សូម្បីតែពួកអ្នកស្រាវជ្រាវបរទេស ក៏គេទទួលស្គាល់ថាពូជខ្មែរជាពូជផ្កាយនាគ ហេតុអ្វីកូនខ្មែរហៅផ្កាយមួយដួងនេះថាផ្កាយក្រពើទៀត?

ក្រោយពីការប្ដឹងតវ៉ាពីប្រជារាស្ត្រ ក្នុងការយកពន្ធអាករពីសំណាក់ធនជ័យ ប្រជារាស្ត្រក៏ឡើងទៅប្ដឹងស្ដេច ពេលនោះស្ដេចកោះហៅធនជ័យឲ្យចូលគាល់សួរដំណើងរឿង ធនជ័យក៏ទូលប្រាប់ស្ដេចថា ខ្ញុំត្រូវប្រមូលពន្ធចូលឃ្លាំងព្រះរាជទ្រព្យ។ ស្ដេចក៏បង្គាប់ប្រាប់ធនជ័យថា ឯងយកតែមួយបាតបានហើយ ធនជ័យត្រឡប់ទៅវិញ បានយកបាតលោកសង្ឃ មកធ្វើជារង្វាល់ ធ្វើឲ្យប្រជារាស្ត្ររឹតតែក្ដៅក្រហាយជាងមុន ហើយក៏នាំគ្នាពិតទូលស្ដេចសារជាថ្មី ដោយការដំឡើងពន្ធដារដ៏ធ្ងន់នេះ។ ហេតុអ្វីបានជាធនជ័យត្រូវធ្វើដូច្នេះ? និពន្ធនិទានចង់ពន្យល់ប្រាប់អ្នកដឹកនាំពូជជ័យជំនាន់ក្រោយ ឲ្យចេះសម្លឹងមើលសុខទុក្ខប្រជារាស្ត្រ ក្នុងការយកពន្ធដារអាករ ត្រូវមើលដង្ហើមរស់របស់ប្រជារាស្ត្រ(ចំណូល) ពុំនោះទេពន្ធដារត្រូវអាកប្រជារាស្ត្រទាំងរស់ជាពុំខាន។ ម្យ៉ាងទៀតច្បាប់ដែលអ្នកដឹកនាំបានដាក់ចុះហើយ ត្រូវតាមត្រួតពិនិត្យច្បាប់ដែលខ្លួនបានដាក់រាជបញ្ជានោះ បើពុំនោះទេអ្នកឆ្លៀតឱកាស នឹងយកច្បាប់នោះមកធ្វើជាខែល ដើម្បីបំរើនៅសេចក្ដីលោភលន់របស់ខ្លួន ដែលជាហេតុធ្វើឲ្យប្រជារាស្ត្រក្ដៅក្រហាយ ងើបឈរឡើងធ្វើបដិវត្តប្រឆាំងនឹងអ្នកកាន់អំណាច ដោយខ្វះសមត្ថភាពក្នុងការដឹកនាំគ្រប់គ្រង។ នេះជាហេតុដែលនិពន្ធនិទានបានពន្យល់ប្រាប់ក្នុងរឿង ពីការប្រមូលពន្ធអាករ ពីការដាក់រាជបញ្ជាឲ្យថ្នាក់ក្រោមអនុវត្ត ខ្លួនពុំបានតាមដានថ្នាក់ក្រោមដែលអនុវត្តរាជបញ្ជា។

ពេលដែលប្រជារាស្ត្រក្ដៅក្រហាយងើបឡើងបះបោរ ស្ដេចបានចេញរាជបញ្ជាឲ្យចាប់ធនជ័យយកទៅប្រហារជីវិត ដោយពុំបានគិតពិចារណា ថាខ្លួនគ្មានសមត្ថភាពក្នុងការគ្រប់គ្រងនគរ បែរជាទម្លាក់កំហុសទាំងស្រុងទៅឲ្យអ្នកខាងក្រោម។ ត្រង់វគ្គនេះនិពន្ធនិទាន

បានប្រាប់ថា ស្ដេចប្រើឲ្យធនជ័យយកពន្លមួយបាត តែពុំបានបញ្ជាក់ឲ្យច្បាស់ ឲ្យយកមួយបាតប្រាក់ ឬមួយបាតលោកសង្ឃ នេះជាកំហុសរបស់អ្នកចេញរាជបញ្ជាឬច្បាប់ វាពុំមែនជាកំហុសរបស់អ្នកអនុវត្តច្បាប់ឡើយ។ ស្ដេចក៏ដឹងថាធនជ័យគឺជាអ្នកប្រាជ្ញ ដែលអាចដោះចំណោទប្រស្នា ដែលចិនមកយកនគរខ្មែរធ្វើជាចំណុះបាន ចុះបើសម្លាប់អ្នកប្រាជ្ញនេះហើយ បរទេសគេមានបំណងចង់មកយកនគរខ្មែរទៀត តើត្រូវពឹងអ្នកណា? ពេលដែលនាំធនជ័យចុះទៅក្នុងទូក ដើម្បីយកទៅសម្លាប់នៅកណ្ដាលទន្លេ ធនជ័យបានរកឧបាយដើម្បីដោះខ្លួនឲ្យរួចពីការស្លាប់នេះ គាត់បានប្រើឲ្យសេនា និងពេជ្ឈឃាត ស្រែកបន្ទរតាមគាត់មុននឹងគាត់ស្លាប់ ក្នុងពេលទូកកំពុងអុំទៅមុខ។ ធនជ័យគាត់ស្រែកឡើងថា អាជ័យធ្លាក់ទឹក អ្នកបន្ទរស្រែកឡើងតាមក្រោយថា ហៃអើៗ ស្រែកបន្ទររហូតដល់ធនជ័យលោតទំលាក់ទឹក ទើបដឹងថាចាញ់បញ្ឆោតធនជ័យ ហើយក៏ទូលទៅពិតប្រាប់ស្ដេចថា ធនជ័យលោតទឹកសម្លាប់ខ្លួន តើពាក្យស្រែកបន្ទរនេះ និពន្ធនិទានចង់ឲ្យយើងយល់ពីន័យអ្វី? និពន្ធនិទានដូនតាគាត់បានទស្សន៍ទាយប្រាប់យើងថា ក្រោយការបោះបង់ចោលក្រុងអង្គរ ដែលជាទីក្រុងអច្ឆរា(អច្ឆរិយ) ធនធានមរតកទ្រព្យទាំងអស់ ដែលពូជជ័យវរ្ម័នខំប្រមូលទុកគ្រប់ជំនាន់ ជាមរតកសម្រាប់ពូជជ័យជំនាន់ក្រោយ ត្រូវធ្លាក់ទៅក្នុងទឹកវិញ គឺវិលទៅរកម្ចាស់ដើម ព្រោះទឹកជានិមិត្តរូបម្ដាយ(ធាតុទឹក១២)។ ការវិនាសបាត់បង់ទឹកដី កេរដំណែលដែលបរទេសជិតខាងឈ្លានពានយក និងការបោះបង់ចោលបន្តិចម្ដងៗ នៅទំនៀមទំលាប់ប្រពៃណី វប្បធម៌ អរិយធម៌ ដែលជាមរតករបស់ពូជផ្កាយ ព្រហ្ម នាគ អច្ឆរិយ ប្រាំ .... ហើយឈោងចាប់យកវប្បធម៌ថ្មីរបស់បរទេស ធ្វើឲ្យធនធានជ័យ(ធនជ័យ) ត្រូវធ្លាក់ទៅក្នុងទឹក អ្នកនៅលើទូកស្រែកបន្ទរថាហៃអើៗ ទោះបីជាបាត់បង់នៅមរតកទាំងនោះក៏ដោយ នេះជាប្រស្នាធនជ័យធ្លាក់ទឹកហៃអើៗ។ ពេលដែលធនជ័យធ្លាក់ទៅក្នុងទឹកជាលើកទីពីរ (និមិត្តរូបបានទៅជួបម្ដាយជាលើកទីពីរ) ធនជ័យបានទៅបួស ដើម្បីលាក់នៅប្រវត្តិរបស់ខ្លួន នេះជាដំណាក់កាលទីបី ដែលធនជ័យបានជួបនឹងមេនាគទីបី គឺព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ដែលព្រះអង្គជាសាស្ដា របស់មនុស្សនិងទេវតាគ្រប់ជាន់ថ្នាក់។ ឪវាទបណ្ដាំមេនាគទីមួយ គឺមាតាបង្កើតធនជ័យបានផ្ដាំឲ្យធនជ័យ មើលយល់សប្តិនិងយល់សូង (និមិត្តសញ្ញាពេលយប់និងថ្ងៃ)។ បណ្ដាំមេនាគទីពីរ គឺមាតាបិតាមហានគរ ផ្ដាំពេលធនជ័យលោតទម្លាក់សម្លាប់ខ្លួនទៅក្នុងទឹក ពេលចិនយក

ចំណោទប្រស្នា ដើម្បីភ្នាល់យកនគរ។ បណ្ដាំមេនាគទីបី គឺក្នុងពេលដែលស្ដេចប្រើឲ្យពេជ្ឈឃាតយកធនជ័យទៅសម្លាប់ គឺគាត់លោតទៅក្នុងទឹកបានជួបមេនាគទីពីរផង និងបានជួបមេនាគទីបី ក្នុងពេលដែលគាត់បានបួសរៀន ជាមួយនឹងព្រះពុទ្ធសាសនា។ ហេតុអ្វីក៏និពន្ធនិទានឲ្យធនជ័យស្លាប់ពីរដងនៅក្នុងទឹក មិនឲ្យស្លាប់នៅលើគោក? ព្រោះពួកគាត់ចង់ឲ្យយើងមើលឃើញនិមិត្តរូបទឹក ដំណាងឲ្យធាតុទឹកម្ដាយ១២ ដែលមាតាដើមគឺមាតាមហានគរ លោកជាប់ទោសចេញពុំរួច ដោយបង្អើយចុងក្រោយរបស់លោកនៅភ្នំអង្គរស អ្នកប្រាជ្ញចិន(អ្នកស្គាល់កាលបី)បានដឹងរឿងអាថ៌កំបាំងនេះ ក៏មកសុំស្ដេចក្មែរកសាងព្រះពុទ្ធរូបមួយអង្គ កំពស់១៨ហត្ថព្រះសន្ធប់បិទរូងនាគ ដែលជានិមិត្តរូបព្រះមាតានាគ(មើលរឿងព្រេងទាក់ទងនឹងភ្នំអង្គរស)។ ការបានសេពគប់ជាមួយនឹងមហាសប្បុរស(ព្រះសម្មាសម្ពុទ្ធ) ជាកល្យាណមិត្ត ធ្វើឲ្យធនជ័យយល់ដឹងពីធម្មៈ អរិយសច្ចៈ និងកម្លាំងរបស់កម្ម ដែលសត្វបានសាងសាបព្រោះសន្សំទុកហើយ សត្វទាំងនោះត្រូវទទួលនៅវិបាករបស់កម្មនេះ ទៅតាមកម្លាំងកម្មដែលបានសាបព្រោះទុកនោះ។ អ្វីដែលពូជជ័យ ព្រហ្ម ផ្កាយ អច្ឆរា.... បានទទួលក្រោយការបោះបង់ចោលក្រុងអច្ឆរិយនោះ គឺសុទ្ធតែជាផលកម្មចាស់ ដែលយើងបានសាបព្រោះទុកហើយ ដូចនេះនិពន្ធនិទានជូនតា ចង់ឲ្យយើងអ្នកស្ដាប់រឿងនិទានយល់ថា៖

សំបកឃ្លោកលិចក្នុងទឹកស្រែ អំបែងបែកប្រែជាអណ្ដែត ស្រុកកើតកោលាហលតេទ ផ្ករលាន់ខែចេត្រឡើងលិចស្រុក។ លិចស្រែចំការច្បារដំណាំ លិចព្រៃកទាំងប្រាំត្រពាំងថ្លុក ទើបត្រីទាំងឡាយសប្បាយសុខ ស៊ើយទុក្ខរីកមុខដោយសារឡើង។ ឡើងឡើបំផ្លុងកណ្ដាលព្រៃ រាលរាលដល់ន័យស្រីមានរាង សំពត់ពេញដីស្រីមិនលាង ព្រោះឃើញទឹកឡើងពីលើថ្នឹ។(នេះជាទំនាយប្រស្នាថ្ងៃសុក្រ សៅរ៍)

## V.<u>អ្នកប្រាជ្ញចិនមកចោទប្រស្នាយកនគរលើកទី២</u>

ក្រោយពេលដែលដំណឹងធនជ័យ ត្រូវស្ដេចបញ្ជាពេជ្ឈឃាត ឲ្យយកទៅប្រហារជីវិតនៅកណ្ដាលទន្លេមក រឿងសម្លាប់ធនជ័យនេះ ត្រូវបានផ្សព្វផ្សាយពេញទាំងនគរ រហូតឮទៅដល់នគរចិន តាមរយៈឈ្មួញចេញចូលជួញដូរក្នុងស្រុកក្មែរ។ នេះជាហេតុធ្វើឲ្យស្ដេចចិន មានបំណងចង់យកនគរក្មែរម្ដងទៀតជាលើកទីពីរ ដោយបញ្ជាឲ្យអ្នកប្រាជ្ញរបស់ខ្លួន ចុះសំពៅនាំយកនៅចំណោទប្រស្នា មកភ្នាល់យកនគរជាមួយនឹងស្ដេចក្មែរ ព្រោះដឹងថាអ្នកប្រាជ្ញស្រុកនេះត្រូវស្ដេចសម្លាប់។ ពេលអ្នកនាំសារស្ដេចក្រុងចិនឡើងទូលថ្វាយស្ដេចក្មែរ ពី

រាជបំណងរបស់ស្ដេចខ្លួន ក្នុងការចោទចំណោទប្រស្នាភ្នាល់យកនគរ បើក្មេរចាញ់ប្រស្នានគរក្លាយជាចំណុះ បើចិនចាញ់ប្រស្នានគរចិននឹងក្លាយជាចំណុះ។ ពេលនោះស្ដេចក្មេរមានការសោកស្ដាយក្រោយជាខ្លាំង ព្រោះអ្នកប្រាជ្ញដែលអាចជួយនគរឲ្យផុតពីភ័យបាន ត្រូវខ្លួនយកទៅសម្លាប់ (មនុស្សសត្វភាគច្រើនតែងស្ដាយជាខាងក្រោយ ពុំដែលស្ដាយមុនឡើយ)។ ស្ដេចក្មេរអង្គនោះ នៅមានមន្ទិលសង្ស័យ អាត្មាអញហាក់ដូចជាប្រហែលភិក្ខុមួយអង្គ ដែលមកបិណ្ឌបាតចង្ហាន់រាល់ថ្ងៃ លោកអង្គនោះមុខស្រដៀងនឹងអាជ័យ ចាំថ្ងៃស្អែកសឹមសួរលោកមើល តើមែនឬមិនមែន។ ពេលដែលភត្តកិច្ចមកដល់ ព្រះសង្ឃជាច្រើនអង្គបាននិមន្តជាជួរ មកបិណ្ឌបាតក្នុងរាជវាំង ភិក្ខុមួយអង្គដែលនិមន្តក្រោយគេ ដែលស្ដេចសង្ស័យនោះ ព្រះអង្គក៏សួរភិក្ខុអង្គនោះ លោកម្ចាស់មានមុខដូចធនជ័យ ភិក្ខុអង្គនោះក៏មានថេរដីកាតបវិញថា ជ័យថាមិនជ័យ។ ទើបស្ដេចមានរាជឱង្ការប្រាប់ភិក្ខុជ័យពីរឿងចិន នាំយកចំណោទប្រស្នាមកចោទយកនគរ ដូច្នេះមានតែលោកម្ចាស់ទេ ដែលអាចដោះស្រាយប្រស្នាចំណោទគេបាន សូមព្រះអង្គលាចាកសិក្ខាបទមកជាគ្រហស្ថ ទើបងាយស្រួលក្នុងការដោះប្រស្នា។

ក្រោយពេលដែនធនជ័យលាចាកសិក្ខាបទ(សឹក) គាត់ក៏បានឡើងទៅគាល់ស្ដេច ព្រះអង្គឃើញធនជ័យដើរចូលមក ក៏មានព្រះរាជឱង្ការថា នេះបានសមជាបណ្ឌិត(អន្ទិត)មែន ព្រោះក្បាលរលោងដូចផ្លែឪឡឹក ដោយការជ្រុះសក់ផង និងកោរផង។ ធនជ័យក៏ទូលប្រាប់ព្រះអង្គថាចាំពេលបីថ្ងៃទៀត ទើបឲ្យអ្នកប្រាជ្ញចិនយកចំណោទប្រស្នាមកតទល់គ្នា ព្រោះគាត់ត្រូវរៀបចំប្រស្នាដើម្បីទប់ទល់នឹងអ្នកប្រាជ្ញចិន។ ធនជ័យបានសំណូមពរពីព្រះអង្គ ឲ្យរាជបំរើជួយរកក្រដាសចាស់ៗ ឲ្យរកខ្មៅដុសៗឲ្យបានច្រើន ដាក់ក្នុងថាសបួន ហើយឲ្យយកក្ដារធំរាបស្មើរលោងបួនជ្រុងមកឲ្យ ហើយចាប់ក្ដាមឲ្យបានបួនក្អម ទើបធនជ័យប្រើឲ្យគេយកក្រដាសទៅលាតសន្ធឹងដាក់លើក្ដារ។ ធនជ័យគាត់ចាប់ក្ដាមជ្រលក់ជើងនឹងទឹកខ្មៅដុសរួចឲ្យវារលើក្រដាសសក្រាលលើក្ដារ ធ្វើឲ្យមានស្នាមក្រវេមក្រវាមពេញលើក្រដាស ទើបប្រើឲ្យគេយកក្រដាស ដែលមានស្នាមជើងក្ដាមទៅហាលថ្ងៃឲ្យស្ងួត ទើបយកមកម្ចូរទុក។ តើសត្វក្ដាមតំណាងឲ្យអ្វី? ក្អមតំណាងឲ្យអ្វី? អក្សរក្ដាមតំណាងឲ្យអ្វី? សត្វក្ដាមគឺជានិមិត្តរូបផ្កាយ ទាំងដំណើរច័ន្ទគតិ និងសុរិយគតិ នៅក្នុងច័ន្ទគតិខែបុស្ស គឺជាផ្កាយរូបក្ដាមដែលមាន

៣០ថ្ងៃ ក្នុងសុរិយគតិខែកក្កដា កក្កដរាសីគឺផ្កាយរូបក្ដាមមាន៣១ថ្ងៃ។ ដូច្នេះនិពន្ធដូនតាគាត់ចង់ពន្យល់ប្រាប់យើងថា ប្រស្នាដែលគាត់ត្រូវយកទៅឲ្យចិនដោះ គឺប្រស្នាមនុស្សផ្កាយ (ធនជ័យ)។ ក្ដមឬឆ្នាំជី ក៏ជានិមិត្តរូបផ្កាយដែរ ព្រោះបើសត្វក្ដាមជានិមិត្តរូបផ្កាយ ដូច្នេះរបស់ដាក់ក្ដាម ក៏ជាផ្កាយដែលជារបស់នៅទីខ្ពស់ដូចគ្នា ក្នុងដំណើរសុរិយគតិ ខែកុម្ភៈគឺជាផ្កាយរូបក្អមឬឆ្នាំង ដែលមាន២៨ឬ២៩ថ្ងៃ។ អក្សរជើងក្ដាម គឺជានិមិត្តរូបអក្សរឬភាសារបស់មនុស្សផ្កាយ ក៏ប៉ុន្តែអក្សរមនុស្សផ្កាយនេះ ត្រូវជ្រលក់ជើងនឹងលក្ខ័ពណ៌ខ្មៅ ដែលយកមកពីបរទេស ធ្វើឲ្យផ្កាយមិនអាចបញ្ចេញពន្លឺបាន។

ថ្ងៃសន្មត់ក៏បានមកដល់ ធនជ័យក៏ចុះទៅទទួលអ្នកប្រាជ្ញចិន ពាក់កណ្ដាលផ្លូវនៅមុខព្រះលានស្ដេច អ្នកប្រាជ្ញចិនឃើញធនជ័យដើរពីចំងាយទៅរកខ្លួន ក៏ធ្វើសញ្ញាជាភាសាគចង្អុលដៃទៅលើមេឃ ចំណែកធនជ័យឆ្លើយតបទៅវិញ ដោយចង្អុលដៃទៅរកព្រះអាទិត្យ អ្នកប្រាជ្ញចិនចង្អុលទៅក្រៅរួចលាបាតដៃ ធនជ័យគាត់លើកម្រាមដៃទាំងប្រាំបញ្ឈរឡើងទៅលើតបប្រស្នាវិញ អ្នកប្រាជ្ញចិនចង្អុលដៃចុះក្រោម ធនជ័យតបវិញដោយចង្អុលមកខ្លួនឯង នេះជាការចោទនឹងស្រាយប្រស្នាទីមួយ។ អត្ថន័យដែលបានបកស្រាយ រួចហើយក្នុងសាច់រឿង ចិនលើកម្រាមដៃចង្អុលទៅលើសួរធនជ័យថា នៅខាងលើមានអ្វី ធនជ័យចង្អុលទៅព្រះអាទិត្យ គាត់បានឆ្លើយប្រាប់អ្នកប្រាជ្ញចិនថា មានព្រះអាទិត្យ និងព្រះច័ន្ទនៅលើមេឃ អ្នកប្រាជ្ញចិនចង្អុលទៅក្រៅលាបាតដៃ ចង់សួរធនជ័យថា មានអ្វីខ្លះនៅខាងក្រៅ ធនជ័យលើកម្រាមដៃប្រាំបញ្ឈរឡើងលើ មានន័យថានៅខាងក្រៅមានដី ទឹកសមុទ្រ មានភ្នំព្រះសុមេរុចក្រវាល មានផ្កាយ អ្នកប្រាជ្ញចិនចង្អុលចុះក្រោមថា នៅលើផែនដីមានអ្វី ធនជ័យចង្អុលមកខ្លួន មានន័យថានៅលើផែនដីមានមនុស្សសត្វ។ ក្នុងប្រស្នាភាសាគលើកទីមួយ និពន្ធនិទានចង់ឲ្យពូជជ័យជំនាន់ក្រោយ បានយល់ពីអត្ថន័យជំរៅរបស់គាត់គឺ ធនជ័យចង្អុលទៅព្រះអាទិត្យ គាត់ចង់ប្រាប់ឲ្យយើងមើលព្រះអាទិត្យមួយដួង រះក្នុងថ្ងៃតែមួយ ដែលអាចបង្កើតនៅភាពអស្ចារ្យក្នុងពិភពលោកបាន។ នៅថ្ងៃទី២១ ២២ ២៣ ខែមីនា និងថ្ងៃទី២១ ២២ ២៣ ខែកញ្ញា ព្រះអាទិត្យមួយដួងនេះ ដែលធនជ័យបានចង្អុលដោះប្រស្នាចិននោះ បង្កើតឲ្យមានភាពអស្ចារ្យនៅលើពិភពលោក ទីមួយព្រះអាទិត្យរះចំកំពូលកណ្ដាលប្រាសាទអង្គរវត្ត(អង្គរតូច) ទីពីររះចំកណ្ដាលកំពូលប្រាសាទពីរាមីត នៅប្រទេសអេស៊ីប ក្នុងចំណោមប្រាសាទបី ទី

បីបង្កើតជាស្រមោលខ្លួននាគ ភ្ជាប់នឹងក្បាលនាគចម្លាក់ដែលគ្មានខ្លួន នៅប្រាសាទជនជាតិដើមម៉ាយ៉ាន នៅក្នុងប្រទេសមិចស៊ិចកូ ទីបួនព្រះអាទិត្យរះចំកណ្តាលសសរខ្លោងទ្វារលើកបន្ទប់ របស់ជនជាតិដើមនៅប្រទេសពែរ៉ូ (ដកចេញពីការស្រាវជ្រាវរបស់Discovery)។ ភាពអច្ឆរិយនេះ និពន្ធជូនតាក្មេរបានទុកប្រស្នាភាសាគ ដោះចំណោទអ្នកប្រាជ្ញចិន ដែលចង់យកនគរក្មេរធ្វើជាចំណុះ ដែលភាសាគនេះអ្នកប្រាជ្ញបស្ចឹមប្រទេស ភាគច្រើនគេបានសិក្សានៅប្រទេសអេស៊ីប។ ធនជ័យលើកម្រាមដែលប្រាំបញ្ឈរឡើង និពន្ធជូនតាចង់ឲ្យយើងបានយល់ថា **ក**ជាព្យញ្ជនៈសម្រាប់ភ្ជាប់ពូជប្រាំ ពូជរបាំឲ្យរស់ឡើងវិញ ទីមួយព្យញ្ជនៈ**ក** ជានិមិត្តរូបភ្ជាប់ក្បាលនិងដងខ្លួន(ព្រហ្មមានតែក្បាល មាតាមហានគរនៅប្រាសាទនាគព័ន្ធ មានតែក្បាល) ឲ្យមានរូបរាងកាយពេញលេញ។ ទីពីរព្យញ្ជនៈ**ក** ភ្ជាប់បាតដៃនិងដើមដៃឲ្យជាប់គ្នា (កដៃ) ដើម្បីលើកដៃរាំបង្ហាញពីរបាំ(ពូជប្រាំ ឬផ្កាយ) ដែលមានម្រាមដៃទាំងប្រាំ ពត់ពេនបង្កើតបានជាក្បាលនាគប្រាំបើកពពារ និមិត្តរូបតាងឲ្យព្រះមាតានាគ(អច្ឆរា)។ ទីបីព្យញ្ជនៈ**ក** ភ្ជាប់បាតជើងនិងកំភួនភ្លៅឲ្យជាប់គ្នា(កជើង) ដែលនិមិត្តរូបបាតជើងនេះ គឺស្នាមព្រះបាតដែលមានសល់នៅតាមទីស្ថាននានា(ព្រះបាតជាន់ទុក)។ ពេលក្មេរស្គាល់ឈ្មោះសម្គាល់ជាតិនឹងព្យញ្ជនៈ**ក**(**ក្មេរ**)ឈប់ស្គាល់ឈ្មោះសម្គាល់ជាតិ នឹងព្យញ្ជនៈ**ខ**(**ខ្មែរ**)ពេលនោះម្រាមទាំងប្រាំ និងត្រូវបានលើកបញ្ឈរឡើង ដូចជាសញ្ញាលើកដៃបង្ហាញរបស់អ្នកប្រាជ្ញធនជ័យ ក្នុងពេលដោះប្រស្នាចិន ដែលធនជ័យបានប្រកាសប្រាប់ចិនថា សាវតាពូជប្រាំ ឬផ្កាយ(ទេវតា) អច្ឆរិយ ព្រហ្ម ត្រូវបានបើកបង្ហាញ ទោះបីជាបរទេសចង់លាក់បាំង ក៏ធនជ័យបានលើកបញ្ឈរឡើង។ និមិត្តសញ្ញាប្រាំនេះ ដូនតាយើងបានឆ្លាក់ទុកនៅលើថ្ម នៅបាតស្ទឹងភ្នំគូលែនក្នុងខេត្តសៀមរាប និងទុកក្នុងរបាំក្មេរគ្រប់ប្រភេទ ព្រោះរបាំគឺជានិមិត្តសញ្ញាលើកដៃបង្ហាញពីម្រាមទាំងប្រាំ(របាំ ⇨ ប្រាំ ⇨ បរាំ) រនៅខាងមុខឃើញពាក្យរបាំ រនៅត្រួតពីលើឃើញពាក្យប្រាំ រនៅពីក្រោយឃើញពាក្យបរាំ។ អាថ៌កំបាំងលេខប្រាំនេះ មានតែពូជប្រាំ ក្មេរ ជ័យ ព្រហ្មអច្ឆរិយទេ ..... ដែលអាចស្រាយនៅចម្ងល់ព្រះអាទិត្យមួយដួង ដែលរះបង្កើតភាពអស្ចារ្យនេះបាន គឺក្នុងពេលដែលធនជ័យ គាត់ចង្អុលមកខ្លួនឯងប្រាប់អ្នកប្រាជ្ញចិន។ រីឯផែនទីចម្លាក់ប្រក្រតិទិន នៃជនជាតិម៉ាយាន ដែលបានទស្សន៍ទាយថា នៅថ្ងៃទី ១២ ខែ១២ ឆ្នាំ២០១២ គឺជាថ្ងៃអវសាននៃពិភពលោកនោះ នៅខាងក្រោមនៃរូបចម្លាក់ប្រក្រតិទិន មនុស្សដែលមាន

តែក្បាល(ដូចរូបព្រះម៉ែមានតែក្បាលនៅនាគព័ន្ធ) លានអណ្ដាត ដែលនៅក្នុងអណ្ដាតមានគ្រាប់សោចាក់ពេញអណ្ដាត ដែលជានិមិត្តរូបធ្វើឲ្យមនុស្សនោះគមិនអាចនិយាយបាន ហើយនៅខាងក្រោមមុខមនុស្សនោះ មានគ្រាប់ប្រាំ ដែលមានពីរប្រអប់បិទជិតក្នុងរនាំង មិនអាចបង្ហូរគ្រាប់ទាំងប្រាំនោះ ចេញមកខាងក្រៅបានឡើយ វាខុសពីគ្រាប់ប្រាំរបស់ក្មេរនៅបាតស្ទឹងភ្នំគូលែន ដែលមានចង្អូរសម្រាប់បង្ហូរគ្រាប់ប្រាំនោះចេញបាន ឲ្យតែយើងចេះដោះប្រស្នាអាថ៌កំបាំងគ្រាប់ទាំងប្រាំនោះ។ នៅខាងក្រោមបំផុតនៃរូបផែនទីប្រក្រតិទិនម៉ាយានមានរូបបុរសនិងស្ត្រីពាក់មកុដ ស្នែងសត្វពពៃឬចៀម មុខញញឹមទល់មុខគ្នា ហើយនៅខាងក្រោយក្បាលមនុស្សប្រុសស្រីទាំងពីរនោះ មាននិមិត្តរូបសញ្ញាដូចសត្វពស់ ឬនាគ ដែលសញ្ញានេះបានចង្អុលបង្ហាញប្រាប់ថា មានតែពូជនាគ ពស់ ឬអន្លង់(ធនជ័យអ្នកដាក់)ទេ ដែលអាចបើកគំរបអាថ៌កំបាំងប្រស្នាភាសារូប ឬភាសាគ ដែលមានអាយុកាលរាប់ពាន់ឆ្នាំនោះបាន។ ហើយប្រក្រតិទិនជនជាតិម៉ាយាននោះដដែល គ្រាប់ប្រាំដែលនៅក្រោមមុខលានអណ្ដាតទាំងពីរប្រអប់នោះ បានបំបែកខ្លួនក្លាយជាប្រអប់ប្រាំ ហើយបង្កើតបានជារង្វង់មូលព័ទ្ធជុំវិញ រូបចម្លាក់ដែលមានត្រឹមកលានអណ្ដាតនោះ អត្ថន័យគឺមិនឲ្យចេញពីឃុំនៃរង្វង់ប្រាំរួច។ ដូច្នេះអ្នកជំនាន់ក្រោយរបស់ពូជថ្មទាំងនោះ ពុំអាចដឹងពីភាសាគរបស់ដូនតាខ្លួនបានឡើយ ព្រោះគ្រាប់ប្រាំដែលមានក្នុងប្រអប់ មិនមានចង្អូរសម្រាប់បង្ហូរចេញនោះ បង្កើតជារង្វង់ប្រាំហ៊ុមព័ទ្ធ ពុំមានផ្លូវសម្រាប់នាំរឿងអតីតចេញ គឺមានតែពូជប្រាំទេ ដែលអាចបំបែកអាថ៌កំបាំងគ្រាប់ប្រាំនេះបាន។ ដូច្នេះប្រស្នាជម្រៅក្នុងរឿងធនជ័យ ដែលគាត់ចង្អុលមកខ្លួនឯង ចង់បញ្ជាក់ប្រាប់អ្នកប្រាជ្ញចិនថា មានតែពូជជ័យទេ ដែលអាចដោះអាថ៌ប្រស្នារបស់ព្រះអាទិត្យមួយដួង ដែលរះបំភ្លឺបង្កើតភាពអច្ឆរិយ នៅប្រទេសលើពិភពលោក(ក្មេរ ក្រិច មិចស៊ិចកូ ពែរូ..) ដែលមានសំណង់ប្រាសាទថ្ម ហើយព្រះអាទិត្យរះបំភ្លឺ បង្កើតភាពអស្ចារ្យនៅក្នុងថ្ងៃតែមួយនេះ។

ព្រឹកឡើងអ្នកប្រាជ្ញចិនបានយកប្រស្នាសញ្ញា ដែលជាភាសាគ មកចោទសួរធនជ័យជាថ្មីម្ដងទៀត ដោយពុំអស់ចិត្ត អាចារ្យចិនលើដៃធ្វើជារង្វង់ ធនជ័យគាត់បត់ជុំដៃបង្ហាញទៅអ្នកប្រាជ្ញចិន អ្នកប្រាជ្ញចិនលើកបង្ហាញម្រាមដៃទាំងប្រាំ ចំណែកឯធនជ័យលើកម្រាមចង្អុលដៃតែមួយ។ ភាសាសញ្ញាឬគនេះ អ្នកប្រាជ្ញធនជ័យគាត់អាចបកស្រាយបានបីយ៉ាង

គាត់បកស្រាយប្រាប់ព្រះចៅអធិការផ្សេង គាត់បកស្រាយប្រាប់ស្តេចចៅហ្វាវាំងផ្សេង និងបកស្រាយប្រាប់ស្តេចផែនដីផ្សេង តើចម្លើយទាំងបីនៃភាសាសញ្ញានេះ ចម្លើយណាមួយជាចម្លើយពិត?

ក.ចម្លើយភាសាគធនជ័យបានប្រាប់លោកគ្រូសង្ក្រាជ ឬព្រះគ្រូចៅអធិការ ក្នុងចម្លើយទីមួយ ដែលមានក្នុងរឿងរួចហើយ ព្រោះហេតុតែចង់បានលាភ យស សក្ការ លោកក៏និមន្តទៅសួររកចម្លើយពីអ្នកប្រាជ្ញជ័យ ដើម្បីយកទៅឆ្លើយទូលថ្វាយស្តេច។ ទង្វើប្រព្រឹត្តនេះ វាបញ្ជាក់សនឹងធម៌វិន័យរបស់សមណ ឬអ្នកបួស ដែលសមណ(អ្នកមានចិត្តស្ងប់)គឺចិត្តរបស់លោកមិនញាប់ញ័រក្នុងលោកធម៌ទាំងប្រាំបី(បានលាភបាត់លាភ បានយសបាត់យស និន្ទាសសើរ សុខនិងទុក្ខ)។ ធនជ័យក៏បកស្រាយប្រាប់លោកគ្រូសង្ក្រាជថា ដែលអ្នកប្រាជ្ញចិនគេលើកដៃធ្វើជារង្វង់ គឺគេប្រាប់ខ្ញុំករុណាថា គេមានអង្រុតមួយ ខ្ញុំករុណាលើកដុំដៃបត់ហុចកែងដៃទៅឲ្យ គឺខ្ញុំករុណាបានប្រាប់ចិនថា រុតបានសត្វត្រី(ស្ត្រី)មួយ ចិនលើកម្រាមបញ្ឈរប្រាំឡើង គេប្រាប់ខ្ញុំករុណាថា គេយកសត្វត្រីដែលរុតបាននោះ មកច្រៀកជាប្រាំចម្រៀកធ្វើងៀត ខ្ញុំករុណាក៏លើកម្រាមចង្អុលមួយតបវិញ គឺបានប្រាប់គេថា ខ្ញុំករុណាព្យាយាមស៊ីត្រីងៀតនោះ មួយថ្ងៃមួយចម្រៀក។

ខ.ចម្លើយភាសាគធនជ័យបានប្រាប់សម្តេចចៅហ្វាវាំង ព្រោះហេតុតែសម្តេចចង់បានលាភយស..... សុខចិត្តដាក់ឋានៈខ្លួនចុះ ទៅសួររកចម្លើយពីធនជ័យ ដើម្បីយកទៅទូលថ្វាយស្តេច។ ធនជ័យបានប្រាប់សម្តេចចៅហ្វាវាំងថា អ្នកប្រាជ្ញចិនគេលើកដៃធ្វើជារង្វង់ធ្វើជាសញ្ញា គេប្រាប់ខ្ញុំថា គេមកយកនគរក្មេរយើងហើយ ខ្ញុំបានលើកដៃបត់ជាដុំបង្ហាញកែងដៃទៅចិន ខ្ញុំបានតបទៅអ្នកប្រាជ្ញចិនវិញថា អ្នកឯងមិនអាចយកនគរខ្ញុំបានទេ ខ្ញុំថង(វាត់ឃិះ) អ្នកឯងនឹងកែងដៃ អ្នកប្រាជ្ញចិនក៏លើកម្រាមប្រាំបង្ហាញតប គេចង់ប្រាប់ខ្ញុំថា គេមានគ្នាប្រាំនាក់(ច្រើន) ខ្ញុំក៏លើកចង្អុលម្រាមមួយបង្ហាញប្រាប់អ្នកប្រាជ្ញចិន ខ្ញុំបានប្រាប់គេថា ខ្ញុំតែម្នាក់ឯង ក៏ឡើងតស៊ូរើបំរះតទល់ពីការគាបសង្កត់បិទពីអ្នកឯងដែរ។

គ.ចម្លើយភាសាគ ដែលធនជ័យបានទូលប្រាប់ដល់ព្រះចៅអធិការ និងប្រាប់ដល់សម្តេចចៅហ្វាវាំង អ្នកទាំងពីរបានយកចម្លើយទៅទូលថ្វាយស្តេច ពេលនោះស្តេចនឹកឆ្ងល់ក្នុងចិត្តថា តើចម្លើយទាំងពីរនេះ ចម្លើយមួយណាដែលជាចម្លើយពិតហើយត្រូវ? ដើម្បី

បំបាត់ចម្ងល់ ក៏កោះហៅធនជ័យឲ្យចូលវាំងដើម្បីសួររកចម្លើយពិត។ ពេលនោះធនជ័យបានទូលថ្វាយស្ដេចថា អ្នកប្រាជ្ញចិនគេលើកដៃធ្វើជារង្វង់នោះ គេសួរខ្ញុំព្រះករុណាថា តើចក្រវាលទាំងមូលមានអ្វីជាកណ្ដាល? ខ្ញុំព្រះករុណាបានលើកបត់ដុំដៃបង្ហាញទៅគេ ដោយប្រាប់អ្នកប្រាជ្ញចិនថា នៅកណ្ដាលចក្រវាលមានភ្នំព្រះសុមេរុ(សុម៉ែ) អ្នកប្រាជ្ញចិនបានលើកម្រាមប្រាំបញ្ឈរឡើងលើ គេប្រាប់ខ្ញុំព្រះករុណាថា នៅក្នុងកប្ប(ផែនដី)យើងនេះ ត្រូវមានព្រះសម្មាសម្ពុទ្ធបានត្រាស់ដឹងប្រាំព្រះអង្គ(ភទ្ទកប្ប) ខ្ញុំព្រះករុណាលើកម្រាមដៃមួយបង្ហាញតបទៅចិនវិញ ដោយប្រាប់អ្នកប្រាជ្ញចិនថា នៅសល់មួយអង្គទៀតមិនទាន់បានត្រាស់ (បួនព្រះអង្គត្រាស់ដឹងបរិនិព្វានហើយ) គឺព្រះពោធិសត្វអរិយមេត្តេយ្យ។ ក្នុងពេលនោះស្ដេចរឹតតែឆ្ងល់ថែមទៀត ព្រោះចម្លើយវាប្រាប់ព្រះចៅអធិការផ្សេង វាប្រាប់សម្ដេចចៅហ្វាវាំងផ្សេង ហើយវាប្រាប់មកអញផ្សេង បើអញសួរទៅវារកចម្លើយពិត អញជាស្ដេចផែនដីនិងត្រូវអាប់នូវកិត្តិយស ទើបស្ដេចទុកចម្ងល់ចម្លើយប្រស្នានេះ រហូតមកដល់សព្វថ្ងៃ តើចម្លើយទាំងបីចម្លើយមួយណាពិត? តើការចោទប្រស្នាភាសាគ ជាលើកទីពីរនេះនិពន្ធនិទាន លោកចង់ឲ្យយើងមើលឃើញនឹងយល់ពីអ្វី? ចម្លើយដែលធនជ័យបានឆ្លើយប្រាប់ ព្រះចៅអធិការ សម្ដេចចៅហ្វាវាំងនិងស្ដេចផែនដី គឺជាចម្លើយពិតទាំងបី និពន្ធនិទានលោកចែកចម្លើយជាភាសានិយាយបី ភាសានិយាយរបស់បណ្ឌិត គឺនិយាយពីអត្ថគំនិត ភាសារបស់អ្នកប្រាជ្ញនិយាយពីការគ្រប់គ្រង ដឹកនាំ ថែរក្សា ប្រជារាស្ត្រ និងព្រះនគរ ភាសាមនុស្សសាមញ្ញធម្មតានិយាយពីរឿងស៊ីផឹក ស្រី ស្រា ល្បែង.....។ ហើយពាក្យនិយាយទាំងបីបែបរបស់មនុស្សនេះមានពាក្យចងក្រងជាសុភាសិតថា បណ្ឌិតនិយាយពីគំនិត អ្នកប្រាជ្ញនិយាយពីហេតុការណ៍ មនុស្សធម្មតានិយាយពីរឿងស៊ីផឹក តើចម្លើយទាំងបីនេះ និពន្ធនិទានលោកចង់ឲ្យយើងមើលឃើញពីអ្វីទៀត?

១.ព្រះចៅអធិការគឺជាអ្នកបួស ធម្មតាអ្នកបួសត្រូវលះគ្រឿងជំពាក់សៅហ្មងទាំងពួងដែលមាននៅក្នុងចិត្ត ព្រោះវាជាភារៈធ្ងន់របស់បុថុជ្ជន ដើម្បីរក្សានិងអប់រំចិត្តឲ្យបានផូរផង់ ហេតុដូចម្ដេចបានជាធនជ័យ ប្រាប់សមណអ្នកបួសពីរឿងរតត្រី ស៊ីត្រីទៅវិញ? តើសត្វត្រីជានិមិត្តតំណាងឲ្យរូបអ្វី? សត្វត្រីនៅក្នុងដំណើរសុរិយគតិ ជារូបផ្កាយមួយដួង គឺនៅក្នុងខែមីនា(មិនរាសី ផ្កាយរូបសត្វត្រីមាន៣១ថ្ងៃ) ហើយពាក្យសត្វត្រីនិងស្ត្រីគឺមានសូរសម្លេង

ដូចគ្នា។ និពន្ធនិទានលោកចង់បញ្ជាក់ប្រាប់ ពីកិច្ចរបស់សមណ ដែលជាអ្នកបួសមានចិត្តស្ងប់រំងាប់ មានការចម្រើននូវសតិ ពិចារណានូវកាយក្នុងកាយ វេទនាក្នុងវេទនា ចិត្តក្នុងចិត្ត ធម៌ក្នុងធម៌ ដើម្បីឲ្យកើតបញ្ញាជាលោកិយ និងឈានឆ្លងគោត្រភូទៅរកបញ្ញាជាលោកុត្តរ។ ដោយមិនរវល់ខ្វល់ខ្វាយក្នុងលោកទាំង៦មាន លោកភ្នែក(ឃើញរូប) លោកត្រចៀក(ឮសម្លេង) លោកច្រមុះ(ធុំក្លិន) លោកអណ្ដាត(ដឹងរស) លោកកាយ(ដឹងផោដ្ឋព្វតឹងរឹងកំរើកញ័រ) លោកចិត្ត(ដឹងនៅធម្មារម្មណ៍)។ គ្រឿងដឹងទាំងនេះជាហេតុ ជាអន្ទាក់ឆ្នាក់ស្រេះរួបរឹត ចិត្តឲ្យជាប់នៅក្នុងសង្សារវដ្ដ មិនមានទីបំផុត រកកោះត្រើយគ្មាន ដូច្នេះទើបនិពន្ធនិទាន លោកយកភេទសមណដែលមានភេទខ្ពស់គឺឧត្ដមភេទ ទំលាក់ឲ្យមកទាប គឺស្គាល់ត្រឹមរុតត្រីស៊ីត្រី ដែលជាភាសាសាមញ្ញរបស់គ្រហស្ថ អ្នកដែលពុំមានសីល។ រីឯន័យបង្កប់ដែលមាននៅក្នុងចម្លើយទីមួយនេះគឺ ចិនដែលមានររអង្រុតមួយមករុតក្រុងសត្វត្រី នោះគឺមកឃុំក្រុងពូជស្ត្រី (សត្វត្រី) ដែលជានិមិត្តរូបពូជផ្កាយ ដោយធ្វើទារុណកម្មច្រៀកសត្វត្រីនោះជាប្រាំចម្រៀក គឺឃុំទុកក្នុងសោទ្វារទាំងប្រាំជាន់ (មើលការពន្យល់ពីសោទ្វារ នៅលើទ្វារថ្មបញ្ចោតតាមប្រាសាទ នៅក្នុងអាថ៌កំបាំងភាគ៣)។ អត្ថន័យច្រៀកងៀត គឺរក្សាឃុំទុកបានយូរ មិនងាយនឹងពុកផុយរលួយ ហើយត្រូវគេលាក់បិទរឿងរបស់ស្ត្រីនោះទៀត អាថ៌កំបាំងប្រស្នានេះគឺមានតែធនជ័យដែលដឹង ទើបគាត់លើកចង្អុលដៃមួយឡើង ដោយគាត់ប្រាប់ចិនថា គាត់នឹងព្យាយាមស៊ីសត្វត្រីនោះម្ដងមួយចម្រៀក។ អត្ថន័យស៊ីសត្វត្រីម្ដងមួយចម្រៀកគឺមានន័យថា គាត់ស៊ីពេលវេលា ដើម្បីព្យាយាមដោះនៅសោឃុំម្ដងមួយៗ ព្រោះពាក្យស៊ីភាសាមនុស្សសាមញ្ញ ច្រើនប្រើជំនួសពាក្យអស់រយៈពេល តែពាក្យសាមញ្ញស៊ីពេលវេលាអស់ ដូច្នេះពាក្យស៊ីត្រីម្ដងមួយចម្រៀក គឺមានន័យថាស៊ីពេលវេលា ដើម្បីដោះស្ត្រីដែលត្រូវគេឃុំទុកយូរដូចជាត្រីងៀត ឲ្យបានចេញពីក្រុងក្នុងអង្រុត។

២.សម្ដេចចៅហ្វាវាំងមានតួនាទី ជាអ្នកមើលការខុសត្រូវរាជកិច្ច ជំនួសព្រះអង្គដែលជាស្ដេចផែនដី ហេតុអ្វីបានជាមិនគិតពីភារកិច្ចតួនាទីរបស់ខ្លួន បែរជាទៅស្វែងរកចម្លើយពីធនជ័យ ដើម្បីឆ្លើយផ្ដាប់ផ្ដុនដូរយកកិត្តិយសទៅវិញ? និពន្ធនិទានលោកបានពោលដាស់តឿនចំពោះនាម៉ឺន មន្ត្រី អ្នកប្រាជ្ញ រាជបណ្ឌិត ដែលមានយសផងមានបញ្ញាផង គួរចេះពិចារណារកវិធីទប់ទល់ នឹងបរទេសកំពុងឈ្លានពាន ដែលចង់មកយកនគរធ្វើជាចំណុះ ពុំ

មិនរវល់តែយកគាប់គួរជាមួយនឹងស្ដេចនោះឡើយ បើធ្វើដូច្នេះនគរនិងត្រូវបាត់បង់ក្លាយជាចំណុះគេ។ ចំណែកន័យបង្កប់និពន្ធនិទានបានប្រាប់យើងថា បរទេសគេបានមកយកនគរហើយ គាត់ត្រូវវាត់ថងនឹងកែង សញ្ញាបត់ដុំដៃនេះគឺចង់បញ្ជាក់ប្រាប់ថា កណ្ដាប់ដៃបត់ចង្អុលមកចំបេះដូង មានន័យថា គាត់នឹងព្យាយាមចាក់ទឹកចិត្តចេញពីបេះដូងម៉ែ (មើលការពន្យល់ចាក់ទឹកដូងភាគ១) ហេតុអ្វីបានជាត្រូវចាក់ទឹកដូង? ពេលចាក់ទឹកចិត្តចេញពីក្នុងបេះដូង ទើបដឹងរឿងក្នុងចិត្ត ព្រោះរឿងក្នុងចិត្តរបស់សត្វ តែងលាក់ទុកក្នុងហទយគឺបេះដូង ទើបក្នុងការចាប់កំណើតរបស់ធនជ័យ ម្ដាយធនជ័យយល់សប្ដិដូចយល់សូង យល់សប្ដិបេះដូងបេះបានទាំងផ្លែ យល់សប្ដិឃើញខែៗពេញបូណ៌មី។ និពន្ធនិទានគាត់បានបង្កើតល្បែងប្រស្នាចាក់ទឹកដូង ទុកឲ្យកូនក្មេងខ្មែរលេងបន្តគ្នាពីមួយជំនាន់ទៅមួយជំនាន់ ដែលលោកបានទស្សន៍ទាយទុកថា ថ្ងៃណាមួយល្បែងនេះ នឹងរត់ចូលទៅផ្គុំគ្នាក្នុងរឿងធនជ័យវិញ។ ចំណែកចិនលើកម្រាមទាំងប្រាំនោះ ចង់បញ្ជាក់ប្រាប់ធនជ័យថា ទោះអ្នកឯងខំថយជាតិកំណើតទៅក្រោយ រកសាវតារឿងក្នុងអតីតកាលយ៉ាងណា ក៏សាវតាអ្នកឯងលាក់ទុកក្នុងសោទ្វារទាំងប្រាំជាន់ និមិត្តរូបប្រាំដែលចិនលើកបង្ហាញប្រាប់នោះ និពន្ធនិទានបានទស្សន៍ទាយទុករួចទៅហើយ ថ្ងៃក្រោយប្រទេសនេះមាននិមិត្តសញ្ញាលើទង់ គឺផ្កាយប្រាំ(សូមមើលអាថ៌កំបាំងលេខប្រាំ ក្នុងបណ្ដាំមាតាបិតា(ព្រហ្មភាគ៤)។ ធនជ័យគាត់លើកម្រាមដៃមួយ គាត់បានបញ្ជាក់ប្រាប់ពីសុឆន្ទៈរបស់គាត់ដល់ចិន ទោះបីខ្ញុំមានតែម្នាក់ឯង ក៏ខ្ញុំព្យាយាមចូលទៅក្នុងបេះដូងរបស់ស្ត្រីនោះ ស្វែងរកអាថ៌កំបាំងសាវតារបស់គាត់ ដើម្បីជួយគាត់ នេះជាអត្តន័យបង្កប់ក្នុងចម្លើយទីពីរប្រាប់សម្ដេចចៅហ្វាវាំង។

៣.ធនជ័យបានស្រាយប្រស្នាភាសាសញ្ញា ទូលប្រាប់ស្ដេចផែនដីតាមដំណើររឿងប្រាជ្ញចិនសួរថាចក្រវាលទាំងមូលនេះមានអ្វី? ខ្ញុំព្រះករុណាបានឆ្លើយប្រាប់អ្នកប្រាជ្ញចិនថា មានភ្នំព្រះសុមេរុនៅកណ្ដាល មានន័យថាម្ចាស់ដើមនៃដែនដីសុវណ្ណភូមិនេះ គឺព្រះនាងនាគដែលជានិមិត្តរូបព្រះមេ ក្រោយមកបានប្រែក្លាយឈ្មោះទៅជាព្រះម៉ែ(មែរុ) ព្រោះហេតុដែលគាត់មានស្វាមី(ព្រះថោង) ហើយគាត់ត្រូវតែមានបុត្រគឺកូន។ ពាក្យដែលជនជាតិនេះហៅម្ដាយថាម៉ែ ព្រោះឈ្មោះនេះក្លាយចេញពីឈ្មោះភ្នំ ដែលស្ថិតនៅកណ្ដាលចក្រវាល គឺភ្នំព្រះសុមេរុ(សុមែរុ) ដែលភ្នំនេះទ្រនៅស្ថានទេវតាទាំងមូល ហើយត្រូវបានជនជាតិខ្មែរ សឹងតែ

គ្រប់ស្រទាប់វណ្ណៈ ហៅអ្នកមានគុណ ដែលជាមាតាឬម្តាយថាម៉ែៗ។ ក្នុងន័យដដែលនេះ និពន្ធនិទាន លោកចង់ឲ្យយើងជាពូជជ័យខាងក្រោយ ស្គាល់ពីឈ្មោះរបស់ស្ត្រី(សត្វត្រី) ដែលជាប់ឃុំនៅក្នុងអង្រុត ដែលធនជ័យបានប្រាប់ព្រះចៅអធិការនោះ មានឈ្មោះថាជាម៉ែ(សុមែរុ) ដែលបានបើកបង្ហាញអត្តសញ្ញាណរបស់គាត់ មិនមែនត្រឹមតែជាសត្វត្រីជានិមិត្តរូបផ្កាយ ដែលរស់នៅក្នុងទឹកនោះទ្បើយ។ អ្នកប្រាជ្ញចិនលើកម្រាមប្រាំ ជាសញ្ញាប្រាប់ធនជ័យថា អ្នកដែលអាចជួយស្ត្រី ដែលជាឈ្មោះរបស់ស្តេចភ្នំនោះបាន (សុមែរុ) លុះត្រាតែនៅក្នុងចំណោមព្រះសម្មាសម្ពុទ្ធទាំងប្រាំអង្គ។ ចំណែកធនជ័យលើកម្រាមចង្អុលមួយ បានបង្ហាញប្រាប់ទៅអ្នកប្រាជ្ញចិនថា ព្រះសម្មាសម្ពុទ្ធបានត្រាស់ដឹងនិងបរិនិព្វាន ហើយទើបតែបានបួនព្រះអង្គទេ នៅខ្វះមួយព្រះអង្គទៀត (ចង្អុលមួយ) ហើយមួយព្រះអង្គដែលមិនទាន់ត្រាស់ដឹងនេះ គឺជាពោធិសត្វលោកេស្វរ ដែលត្រូវមកបំពេញបារមីជួយស្ត្រី ដែលជាស្តេចភ្នំ ដែលជាប់ឃុំក្នុងអង្រុតឲ្យបានរួចពីទុក្ខទោសនេះ នេះជាអត្ថន័យបង្កប់ក្នុងចម្លើយប្រស្នាទីបី។ ដូច្នេះ និពន្ធនិទាន លោកចង់ឲ្យពូជជ័យដែលជាអ្នកស្តាប់ រឿងនិទាននិយាយតៗគ្នានេះ និពន្ធនិទានលោកបានដើរតួអង្គជាសេដ្ឋី នាម៉ឺនមន្ត្រី ស្តេចផែនដីខ្មែរ ស្តេចចិនអ្នកប្រាជ្ញចិន .... រួចលោកអ្នកប្រាជ្ញចងជាប្រស្នាផង លោកស្រាយប្រស្នាផង ដើម្បីទុកមរតកប្រស្នាឲ្យកូនជ័យសម័យខាងក្រោយ បានយល់ពីហេតុភេទរបស់នគរ ដែលត្រូវដើរតាមទំនាយប្រស្នាធនជ័យនេះ។

ចុងក្រោយធនជ័យ លោកបានយកក្រដាសដែលមានស្នាមជើងក្តាម (ភាសាផ្កាយ) ដែលជ្រលក់ជើងនឹងទឹកល័ក្ខខ្មៅនោះ មកឲ្យក្មេងៗអានថាទៅតាមចិត្តរបស់វា ដោយក្មេងទាំងនោះពុំមានងឿងឆ្ងល់សួរទៅអ្នកប្រាជ្ញជ័យ ហេតុអ្វីបានជាអុំឲ្យខ្ញុំអានថាតាមចិត្តដូច្នេះ? នេះជាហេតុធ្វើឲ្យយើងជាពូជជ័យជំនាន់ខាងក្រោយ ពុំស្គាល់អត្ថន័យភាសាក្តាម ដែលជាភាសាមនុស្សឋានផ្កាយ ឬទេវតា បានត្រឹមតែពោលរឿងនិទានតៗគ្នាប៉ុណ្ណោះ គឺបង្ហាញពីជ័យជំនះដែលដូនតាឈ្នះអ្នកប្រាជ្ញចិន។ អ្នកប្រាជ្ញចិនបានចុះចាញ់ធនជ័យ ដោយមើលភាសាក្តាមនេះពុំយល់ ក៏ប៉ុន្តែអ្នកប្រាជ្ញចិនទាំងនោះពុំអស់ចិត្តទ្បើយ បានសុំយកភាសាក្តាមពីធនជ័យត្រឡប់ទៅស្រុកវិញ ដើម្បីស្រាវជ្រាវរកអាថ៌កំបាំងនៅក្នុងភាសាក្តាមនោះ។ ថ្វីត្បិតតែធនជ័យបានឈ្នះអ្នកប្រាជ្ញចិន ធនជ័យពុំមានសេចក្តីលោភលន់ ចង់យកនគរចិនមកធ្វើ

ជាចំណុះឡើយ គឺយកតែរបស់របរដែលអ្នកប្រាជ្ញចិន យកមកតាមសំពៅតែប៉ុណ្ណោះ រីឯព្រះនគរថ្វាយជូនទៅស្ដេចក្រុងចិនវិញ លោកគ្រាន់តែផ្ដាំផ្ញើរសម្ដីតាមអ្នកប្រាជ្ញចិនថា ពីថ្ងៃនេះតទៅមុខឲ្យតែអ្នកឮឈ្មោះថាធនជ័យនៅរស់ អ្នកកុំមានគំនិតចង់បាននគរខ្មែរ និងធ្វើបាបពូជជ័យដែលជាពូជផ្កាយនេះឡើយ។

៤.តើប្រស្នាអក្សរក្ដាមមានន័យដូចម្ដេច? ខ្ញុំបាទបានបកស្រាយម្ដងរួចមកហើយ នៅក្នុងបណ្ដាំមាតាព្រហ្មភាគទី៤ ពេលនេះខ្ញុំបាទយកចម្លើយនេះ មកសរសេរបកស្រាយឡើងវិញ ដើម្បីឲ្យចំអត្ថន័យចំណាងជើងនៃអត្ថបទនេះ ងាយស្រួលដោយពុំចាំបាច់ទៅអានអត្ថបទមុន។ ក្ដាមគឺជាសត្វរស់នៅក្នុងទឹកផងលើគោកផង ពេលរដូវធ្លាក់ខ្យល់ពីទិសខាងជើងមកដល់ វាតែងកាយភក់ធ្វើជារន្ធ ដើម្បីការពារខ្លួនពីគ្រោះភ័យ ក្រចកជើងវាពេលដែលវារដើរលើដីភក់ តែងជិតស្នាមដានជើងវាជាប់នៅក្នុងដីភក់នោះ។ ពាក្យក្ដាមបើយើងសម្រាយពាក្យតម្រួតនេះ យើងបានពាក្យពីរម៉ាត់ **ក្ដាម ⇨ ក + ដាម** គឺមានន័យថា កឲ្យមានដាមស្នាមកើតឡើង ដូចជាក្រដាសប្ញសំពត់ ដែលដាមដោយទឹកខ្មៅ ហេតុអ្វីក្នុងការទប់ទល់ជាមួយនឹងអ្នកប្រាជ្ញចិន និពន្ធនិទានលោកបែរជាប្រើអក្សរក្ដាម ដែលធ្វើឲ្យអ្នកប្រាជ្ញចិនចុះចាញ់? គ្រប់ប្រាសាទបុរាណពីអតីតកាលរបស់ជនជាតិខ្មែរ ដូនតាយើងគាត់តែងជញ្ជូនថ្មភក់យកទៅសាងសង់ប្រាសាទ រួចឆ្លាក់សាវតារឿងរបស់ពួកគាត់ ទុកនៅលើថ្មភក់ទាំងនោះ ដែលមានជាក្បាច់ក្បូរចម្លាក់លាយឡំជាមួយសាវតារឿង។ ចម្លាក់ទាំងនោះ លោកឆ្លាក់ទុកនៅលើជញ្ជាំង ផ្ដែរ ក្បាំងក្លែង ...... មានដានស្នាមក្រវេមក្រវាម(អ្នកមិនចេះភាសាចម្លាក់) សុទ្ធតែក្បាច់ផ្កាភ្ញី បង្កប់ទៅដោយសាវតារឿង ដូចជាជើងក្ដាមដែលវានៅលើភក់ថ្ម។ មានកូនខ្មែរខ្លះ តែងពោលឡើងថា ទៅលេងអង្គរនៅខេត្តសៀមរាប មិនដឹងជាទៅមើលអ្វីឡើយ គឺមើលតែដុំថ្ម ពាក្យទាំងនេះខ្ញុំធ្លាប់បានឮផ្ទាល់នឹងត្រចៀក ដូច្នេះវាអយុត្តិធម៌ណាស់ចំពោះដូនតា ដែលលោកខំជញ្ជូនថ្មមកកសាងប្រាសាទរាប់ពាន់ ទុកជាមរតកឧស្សាហកម្មគ្មានផ្សេង សម្រាប់ឲ្យពូជជ័យកើបយកនៅលាភសក្ការៈ ដែលប្រាសាទទាំងនោះ ជាឃ្លាំងមរតកជាតិ ហើយបានបង្កប់នៅសាវតាអ្នកកកើតជាតិ។ អ្នកប្រាជ្ញចិនចុះចាញ់ ព្រោះហេតុតែមើលអក្សរជើងក្ដាមក្នុងក្រដាសពុំយល់ កូនក្មេងដែលស្រែកអានអក្សរជើងក្ដាមក៏ពុំយល់ ព្រោះហេតុតែពុំព្រមឆ្ងល់ យើងបានដឹងហើយថា ធនជ័យពុំបានរៀនសូត្រឲ្យត្រឹមត្រូវឡើយ

ហើយគាត់ពុំចេះគូរគំនូរទេ ដោយការបង្ខំពីសម្នាក់អ្នកប្រាជ្ញចិន គាត់ត្រូវតែដោះប្រស្នា បើគាត់មិនដោះ នគរនឹងត្រូវបានទៅគេ បើគាត់ដោះប្រស្នា នគរខ្មែរគ្រាន់តែទទួលឥទ្ធិពលល័ក្ខខ្មៅ(មនោគមន៍វិជ្ជា) មកលាបលើខ្លួននាគ ឲ្យប្រែក្លាយជាសត្វអន្ទង់ មកជ្រលក់ជើងក្ដាមដែលជាពូជផ្កាយ មិនអាចផ្សាយបញ្ចេញពន្លឺបាន។

៥.ការប្រៀបធៀបភាសាគម្ភាសាសញ្ញា ក្នុងរឿងធនជ័យទៅនឹងរឿងព្រះមហោសថ គឺមានភាពស្រដៀងគ្នា ក្នុងវគ្គនាងបរិព្វាជិកា មានព្រះនាមថាភេរី ដែលជាអ្នកបួសជាទីស្រឡាញ់គោរពរាប់អាននៃស្ដេចចុល្លនី ព្រះនាងតែងតែមកឆាន់ក្នុងព្រះរាជដំណាក់ព្រះអង្គរាល់ៗថ្ងៃ ហើយព្រះនាងបានឮល្បីមកថា ព្រះមហោសថជាបុគ្គលមានប្រាជ្ញាណាស់ ប៉ុន្តែព្រះនាងពុំដែលបានឃើញព្រះមហោសថសោះ។ ក្នុងឱកាសពេលដែលព្រះនាងបានជួបនឹងព្រះមហោសថ ព្រះនាងភេរីនឹកគិតក្នុងព្រះទ័យថា តើព្រះមហាក្សត្របានទំនុកបម្រុងព្រះមហោសថហើយឬនៅ? រួចព្រះនាងក៏បានប្រើភាសាគម្ភាសាសញ្ញា ដោយលើកព្រះហស្ដលាបាតដៃ ហើយក្ដាប់ដៃជាសញ្ញាសួរព្រះមហោសថ តើព្រះមហាក្សត្រទំនុកបម្រុងអ្នកហើយឬនៅ ព្រះមហោសថបានឆ្លើយភាសាសញ្ញាទៅព្រះនាងភេរី ដោយលើកព្រះហស្ដរួចក្ដាប់ដៃ ជាសញ្ញាប្រាប់ថា ព្រះរាជាពុំទាន់ទំនុកបម្រុងខ្លួននៅឡើយទេ។ ព្រះនាងភេរីលើកព្រះហស្ដអង្អែលព្រះកេសខ្លួន ដោយសួរព្រះមហោសថថា បើគ្មានមុខតំណែងអ្វីទេ ម្ដេចមិនបួសដូចខ្ញុំ? ព្រះមហោសថអង្អែលពោះជាសញ្ញា ប្រាប់តបវិញថា ខ្ញុំបួសពុំទាន់បានឡើយ ព្រោះមានកូនច្រើនណាស់ ដែលមានពោះចាំតែរស់ដោយសារខ្ញុំ។ នេះជាភាសាគម្ភាសាសញ្ញា ដែលព្រះមហោសថបានប្រាស្រ័យចរចា ជាមួយនឹងព្រះនាងភេរី ដោយពុំបានបញ្ចេញសម្លេងវាចាឲ្យឮឡើយ ហើយភាសាសញ្ញានេះ មានតែបុគ្គលមានបញ្ញាទើបអាចយល់នូវអត្ថសញ្ញាទាំងនេះបាន។ យ៉ាងណាមិញនិពន្ធនិទានរឿងធនជ័យ លោកបានយកភាសាសញ្ញាឬភាសាគ ដែលមាននៅក្នុងរឿងព្រះមហោសថនេះ មកនិទានបញ្ចូលក្នុងរឿងរបស់ខ្លួន ទីមួយចង់ឲ្យកូនខ្មែរស្គាល់ធនជ័យថាជាអ្នកមានប្រាជ្ញា ទីពីរលោកចង់ឲ្យកូនខ្មែរស្គាល់ធនជ័យជាព្រះពោធិសត្វលោកេស្វរ ដែលនឹងត្រូវបានត្រាស់ដឹងក្នុងកាលខាងមុខ ដោយលោកពុំយករឿងមហោសថជាតកមកប្រើឡើយ ព្រោះព្រះពោធិសត្វមហោសថ ព្រះ

អង្គបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ព្រះនាមថាសក្យមុនីគោតម ហើយព្រះអង្គបានបរិនិព្វានទៅហើយ។

## VI.អ្នកប្រាជ្ញជ័យស្វែងរកភរិយា

ក្រោយពេលដែលអ្នកប្រាជ្ញចិន ទទួលបរាជ័យជាលើកទីពីរ ក្នុងការប៉ុនប៉ងយកព្រះនគរខ្មែរដាក់ជាចំណុះ ការភ្នាល់ចាញ់នេះ សម្បត្តិទ្រព្យទាំងឡាយដែលមានក្នុងសំពៅចិន ធនជ័យបានប្រមូលទៅទុកក្នុងព្រះរាជឃ្លាំងរបស់ជាតិ ឯនគរចិនប្រគល់ឲ្យទៅចិនវិញ ដោយមិនបៀតបៀនគេឡើយ។ ស្តេចមានសេចក្តីត្រេកអររីករាយជាពន់ប្រមាណ ទីមួយនគរបានរួចពីការដាក់ជាចំណុះរបស់ស្តេចចិន ទីពីរទ្រព្យសម្បត្តិជាច្រើន ដែលឈ្នះក្នុងការភ្នាល់នេះ ធនជ័យបានប្រមូលទុកក្នុងព្រះរាជឃ្លាំង។ ហេតុនេះស្តេចមានព្រះទ័យចង់រកភរិយាឲ្យធនជ័យ តបនូវគុណដើម្បីលើកទឹកចិត្តធនជ័យ ដោយប្រើធនជ័យឲ្យរើសយកស្ត្រីណាមួយក្នុងរាជវាំង មកធ្វើជាភរិយា លើកលែងតែមហេសីខ្លួនចេញ។ ធនជ័យបានប្រកែកចំពោះរាជបំណងនេះ ដោយឆ្លើយទៅព្រះករុណាវិញថា អ្នកទាំងនេះពុំមែនជាស្រីឡើយ គឺសុទ្ធតែជាញី ការឆ្លើយតបរបស់ធនជ័យនេះ ធ្វើឲ្យស្តេចសណ្តាប់ហើយមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ក៏សួរតបទៅធនជ័យវិញថា តើស្រីដែលឯងត្រូវការនោះ មានន័យដូចម្តេច? ធនជ័យក៏សូមឱកាសពីព្រះករុណា ដើម្បីដើរស្វែងរកប្រពន្ធ ស្តេចក៏ប្រទានមាស ប្រាក់ កែវកង សំពត់ហូលព្រៃ..... ដែលមានតម្លៃ ឲ្យធនជ័យស្វែងរកភរិយាតាមបំណងរបស់គាត់។ ត្រង់វគ្គនេះក្នុងរឿងធនជ័យ និងរឿងព្រះមហោសថ គឺមានន័យស្រដៀងគ្នា ព្រះអគ្គមហេសីរបស់ ព្រះចៅវិទេហរាជ ព្រះនាមឧទុម្ពរទេវី ដែលជាបងធម៌របស់ព្រះមហោសថ ព្រះនាងចង់ដណ្តឹងភរិយាឲ្យ តែព្រះមហោសថពោលឃាត់ ព្រះអង្គនឹងស្វែងរកភរិយាដោយខ្លួនឯង ព្រោះស្ត្រីនៅក្នុងរាជវាំង ពុំសាកសមនឹងខ្លួនឡើយ។ ព្រះមហោសថបានធ្វើដំណើរឆ្លងកាត់និគមជនបទ បានទៅជួបនឹងនាងអមរាទេវី ដែលបិតារបស់នាងពីអតីតជាសេដ្ឋី តែក្រោយមកត្រូវធ្លាក់ខ្លួនក្រជាមនុស្សសាមញ្ញ។ ក្នុងពេលនោះនាងអមរាកំពុងយួរអាហារ ទៅឲ្យឪពុកនៅឯស្រែ ដែលកំពុងភ្ជួរ ហើយបានឃើញព្រះមហោសថពីចំងាយ រីឯព្រះមហោសថក៏បានឃើញនាងអមរា ក៏ដឹងថាជាស្រីមានលក្ខណាហៈនុ លោកពិចារណាថា បើស្រីនេះពុំទាន់មានប្តីទេអាត្មាអញនឹងដណ្តឹងស្ត្រីនេះធ្វើជាភរិយា។ ព្រះមហោសថគិតដូច្នោះហើយ ក៏ភ្ជាប់ដៃធ្វើជា

សញ្ញាបង្ហាញប្រាប់ទៅនាងអមរា ចំណែកនាងអមរាក៏ដឹងថាភាសាសញ្ញានេះ គឺព្រះមហោសថសួរនាងថា មានស្វាមីហើយឬនៅ? នាងយល់សំនួរហើយក៏ឈរ រួចលាបាតដៃមកកាន់ព្រះមហោសថ ដោយចង់បញ្ជាក់ប្រាប់ថា នាងពុំទាន់មានប្ដីទេ។ ពេលនោះព្រះមហោសថដឹងថា នាងនេះចេះដោះអាថ៌ប្រស្នា ហើយក៏ចូលទៅជិតដណ្ដឹងសួរថា ម្នាលនាងក្រមុំនាងមានឈ្មោះអ្វី? ខ្ញុំឈ្មោះគេកន្លងរំលងទៅហើយ គេវិលមកវិញ ព្រះមហោសថបានឆ្លើយតបថា នាងឈ្មោះអមរាឬ? នាងអមរាបានឆ្លើយថា ឈ្មោះខ្ញុំដូចអ្នកពោលដូច្នោះ ព្រះមហោសថសួរនាងបន្តទៅទៀតថា នាងយកអាហារទៅជូននរណា? នាងអមរាឆ្លើយថា ខ្ញុំយកទៅជូនទេព្តារក្សាអំពីមុន ព្រះមហោសថសួរនាងថា នាងយកអាហារទៅជូនឪពុកឬ? នាងអមរាឆ្លើយថា ដូចអ្នកឆ្លើយនោះហោង។ ព្រះមហោសថសួរបន្តទៀតថា ឪពុកនាងទៅធ្វើអ្វី? នាងអមរាឆ្លើយថា នាបីហៅថាធ្វើការមួយជាពីរ ព្រះមហោសថឆ្លើយថា ឪពុកនាងទៅភ្ជួរស្រែឬ? នាងអមរាឆ្លើយថា ដូចអ្នកថានោះហោង។ ព្រះមហោសថសួរថាគាត់ទៅភ្ជួរស្រែនៅទីណា? នាងអមរាពោលថា គាត់ទៅភ្ជួរស្រែក្នុងទីឋានដែលគេទៅតែម្ដង មិនមកវិញនោះ ព្រះមហោសថឆ្លើយថា ឪពុកនាងទៅភ្ជួរឯខាងព្រៃខ្មោចឬ? នាងអមរាឆ្លើយថា ដូចអ្នកឆ្លើយនោះហោង។ ព្រះមហោសថសួរបន្តទៀតថា នាងទៅមកឥឡូវវិញ ឬមិនទាន់មក? នាងអមរាឆ្លើយថាអ្នកអើយ នាបីគេនោះមក ខ្ញុំមិនបានមកឡើយ បើនាបីគេមិនមកខ្ញុំមកវិញហោង ព្រះមហោសថឆ្លើយថា ឪពុកនាងទៅភ្ជួរស្រែនៅខាងនាយស្ទឹង បើទឹកជន់អ្នកពុំបានមក បើទឹកស្ទឹងពុំជន់ទេ នាងបានមកវិញ នាងអមរាឆ្លើយថា ដូចអ្នកឆ្លើយនោះហោង។ នេះជាអាថ៌ប្រស្នា ក្នុងការស្វែងរកភរិយារបស់ព្រះមហោសថ ហើយបានជួបនឹងនាងអមរាដែលជាស្ត្រីមានប្រាជ្ញាឈ្លាសវៃ នឹងប្រកបដោយរូបសម្បត្តិ សក្តិសមជាកល្យាណីទៀតផង។

ចំណែកឯធនជ័យវិញ ពេលដែលគាត់ស្វែងរកភរិយា ក៏បានដើរទៅគ្រប់និគមជនបទហើយសួរអ្នកស្រុកដែលគាត់បានជួបទាំងនោះ ថាតើនៅក្នុងស្រុកនេះមានស្រីឬទេ? អ្នកស្រុកតែងចង្អុលស្រីៗដែលប្រទះឃើញ តែធនជ័យគាត់បែរជាឆ្លើយថាញីទៅវិញ។ លុះគាត់ដើរទៅដល់ភូមិនាងសួស្តី គាត់បានឃើញនាងសួស្តីកំពុងអង្គុយនៅខាងមុខផ្ទះ ធនជ័យក៏សួរទៅនាងសួស្តីថា ប្អូននៅស្រុកនេះមានស្រីដែរឬទេ? នាងសួស្តីស្តាប់ហើយក៏សួរទៅវិញថា អ្នកឯងនៅស្រុកណា ស្រុកអ្នកឯងមានប្រុសដែរឬទេ? ធនជ័យក៏សួរតបទៅវិញថា តើពាក្យ

និយាយថាប្រុសនោះមានន័យដូចម្តេច? នាងសួស្តីក៏ឆ្លើយថា ដែលហៅថាប្រុសនោះត្បិតគេនោះឈ្មោះជ័យ ជ័យនោះជាធំឈ្នះអស់អ្នកផងទាំងពួងក្នុងផែនដីនេះ ទើបហៅថាប្រុស។ សួស្តីសួរត្រឡប់ទៅធនជ័យវិញ ដូចម្តេចដែលហៅថាស្រីនោះ? ធនជ័យបានឆ្លើយតបថា ដែលហៅថាស្រី គឺអ្នកដែលមានឈ្មោះថាសួស្តី ដែលមានប្រាជ្ញាឈ្លាសវាងវៃ អាចដោះអាថ៌ប្រស្នាគ្រប់បែបយ៉ាងបាន។ ធនជ័យសួរទៅនាងសួស្តីថា នាងខ្លាចឬទេ? នាងសួស្តីឆ្លើយតបទៅធនជ័យវិញថា ខ្ញុំមិនខ្លាចទេ សួស្តីសួរត្រឡប់ទៅធនជ័យវិញថា អ្នកក្រែងឬមិនក្រែង? ធនជ័យឆ្លើយថា ខ្ញុំមិនក្រែងទេ។ អត្ថន័យដែលធនជ័យសួរនាងសួស្តី ថាខ្លាចឬមិនខ្លាច នាងសួស្តីឆ្លើយថាមិនខ្លាច ព្រោះនាងមិនទាន់មានប្តី នាងមិនខ្លាចប្តីនាងជេរទេ ឯធនជ័យឆ្លើយថា ខ្ញុំមិនក្រែង ព្រោះធនជ័យគាត់ពុំទាន់មានភរិយាទេ បើមានភរិយាខ្លាចក្រែងចិត្តភរិយាប្រចណ្ឌរករឿង។ នេះជាហេតុធ្វើឲ្យធនជ័យ ស្តីដណ្តឹងនាងសួស្តីធ្វើប្រពន្ធ ព្រោះនាងគឺជាស្ត្រី ដែលមាននូវរូបសម្បត្តិ និងបញ្ញាឈ្លាសវៃ អាចដោះអាថ៌ប្រស្នាបាន។ បើយើងប្រៀបធៀបនាងសួស្តីទៅនឹងនាងអមរា ក្នុងរឿងព្រះមហោសថ គឺមានអត្ថន័យស្រដៀងគ្នា ដូចនេះទើបយើងហ៊ានអះអាងថា ធនជ័យគឺជាព្រះពោធិសត្វលោកេស្វរៈ ព្រោះនៅក្នុងសាច់រឿងព្រះមហោសថ រឿងធនជ័យ មានចំណុចជាច្រើនដូចគ្នា។ តើអត្ថន័យបង្កប់ក្នុងវគ្គស្វែងរកភរិយានេះ និពន្ធនិទានលោកចង់ឲ្យយើងយល់ពីអ្វី? ពាក្យដែលធនជ័យពោលសួរអ្នកស្រុករកស្រីនោះ គឺមានន័យថាពាក្យស្រី បើយើងសម្រាយពាក្យ គឺមានពាក្យ **សិ + រី** ពេលសរសេរជាព្យាង្គតម្រួត ឃើញពាក្យ**ស្រី** ។ ពាក្យសិរីបង្កើតបានជាពាក្យស្រីៗនេះហើយដែលជាអ្នករកនៅសួស្តី ឲ្យក្រុមគ្រួសារនីមួយៗ សហគមន៍មួយរហូតដល់នគរទាំងមូល គ្រួសារ សហគមន៍ ប្រទេស បានសុខឬទុក្ខក៏ព្រោះតែស្រី (សូមមើលការពន្យល់អត្ថន័យជីនាង ជនាង ជុំនាង បណ្តាំមាតាបិតា(ព្រហ្មភាគ២)។ ហើយរឿងស្រីឬសិរីនេះ បង្កើតបានជាមហាសង្ក្រាន្តសម្រាប់ផ្លាស់ឆ្នាំចាស់ប្តូរឆ្នាំថ្មី គឺរឿងកបិលមហាព្រហ្ម ដែលចាញ់ការភ្នាល់ជាមួយនឹងធម្មបាលកុមារ ត្រូវបាត់ខ្លួននៅសល់តែក្បាល រស់ពួនសំងំក្នុងទុក្ខអស់កាលដ៏យូរអង្វែងរាប់ពាន់ឆ្នាំ។ ដូចនេះនិពន្ធនិទាន លោកឲ្យមើលពាក្យស្រី ដែលក្លាយមកពីពាក្យសិរី បង្កើតបានរឿងមហាសង្ក្រាន្ត(មហាភ្លើង) សម្រាប់ផ្លាស់ឆ្នាំចាស់ប្តូរឆ្នាំថ្មី ដើម្បីឲ្យកូនជ័យខាងក្រោយ ស្វែងរកតួខ្លួនរបស់កបិលមហាព្រហ្ម។ ព្រោះគាត់ចង់សួរកូនជ័យជំនាន់ក្រោយថា ទាំងព្រហ្មម្តាយ

ទាំងព្រហ្មឱពុក តើតួខ្លួនពួកគាត់នៅឯណា? តើតួខ្លួនព្រះមាតាមហានគរ ដំរី សេះ រាជសីហ៍ ដែលនៅប្រាសាទនាគព័ន្ធនៅឯណា? នេះជាអត្ថន័យដែលនិពន្ធនិទាន លោកឲ្យយើងដោះប្រស្នា ពាក្យដែលអ្នកប្រាជ្ញជ័យស្វែងរកស្រីធ្វើជាភរិយានេះ ដែលពាក្យស្រី ឬសិរីនេះ បង្កប់នូវរឿងរ៉ាវដ៏ជូរចត់របស់ពួកគាត់ក្នុងអតីតកាល។ ពាក្យស្រីនេះបង្កើតបានជារឿងប្រស្នាសិរីបីប្រការ គឺសិរីទីមួយនៅលើមុខពេលព្រឹក សិរីទីពីរនៅលើដើមទ្រូងថ្ងៃត្រង់ សិរីទីបីនៅចុងជើងថ្ងៃល្ងាច ហេតុអ្វីសិរីទាំងបីប្រការមានតែពេលថ្ងៃ មិនមានពេលយប់?

ក.សិរីទីមួយនៅលើមុខ ពេលព្រឹកកូនខ្មែរភាគច្រើន ត្រូវយកទឹកមកលាងលុបមុខដើម្បីបានសិរី និពន្ធនិទានគាត់ផ្ដាំឲ្យយើងមើលនិមិត្តពេលថ្ងៃគឺយល់សូង ដែលគ្រប់ប្រាសាទបុរាណភាគច្រើន តែងតែមានក្បាំងភ្លែង។ ហើយក្បាំងភ្លែងនេះ គឺជាក្បាំងដែលពាក់នៅលើក្បាលអប្សរា ឬអច្ឆរា ដូច្នេះតើក្នុងមុខអប្សរា ធ្លាក់រៀបរាប់ពីរឿងសាសនា ឬក៏និយាយរៀបរាប់ពីរឿងមុខអ្នកពាក់ក្បាំង? ហើយពាក្យក្បាំងនេះ មានបន្ថែមពាក្យភ្លែង បង្កើតបានជាពាក្យក្បាំងភ្លែង ដែលពាក្យភ្លែងមានន័យថា ភ្លែងបន្លំលាក់បាំងនូវប្រវត្តិពិត កុំឲ្យអ្នកមើលស្ដាប់.... ចាប់អារម្មណ៍យល់បានភ្លាម នៅពេលដែលអ្នកមើលពុំបានពិនិត្យពិចារណាឲ្យបានម៉ត់ចត់។ ហេតុនេះគ្រប់សាច់រឿងចម្លាក់ ដែលមាននៅក្នុងក្បាំងភ្លែងគ្រប់ប្រាសាទពីបុរាណជនបរទេសបានជួលពួកទុច្ចរិត ឲ្យដាប់បំផ្លាញរូបចម្លាក់ទាំងនោះ ដោយពួកគេបានមើលយល់ ភាសារូប ភាសាគ ភាសាក្ដាម ដែលដូនតាបានសរសេរដាប់ឆ្លាក់ជាសាច់រឿង របស់ម្ចាស់រឿងសិរី ឬស្រី(រឿងក្នុងមុខរបស់ម្ចាស់ក្បាំង)។

ខ.សិរីទីពីរនៅលើទ្រូង កូនខ្មែរដែលនៅប្រកាន់ជំនឿសិរី ពេលថ្ងៃត្រង់តែងនាំគ្នាយកទឹកលាងទ្រូង ព្រោះប្រកាន់យល់តគ្នាថា សិរីសួស្ដីថ្ងៃត្រង់នៅលើទ្រូង អត្ថន័យរបស់ពាក្យទ្រូង បើយើងសម្រាយពាក្យ ឃើញពាក្យពីរម៉ាត់ គឺពាក្យ **ទ + រូង** ។ ទគឺជាប្រដាប់ត្រងនាំទឹកចុងសំយាប ដែលហូរចេញឬចូល ឯពាក្យរូងគឺជារន្ធប្រហោងដ៏ធំ ឧទាហរណ៍រូងភ្នំឬគុហារ។ តើសិរីទីពីរនេះ ហេតុដូចម្ដេចបានជានៅលើទ្រូង? ពុំនៅត្រង់ផ្ចិត ដែលជាចំណុចកណ្ដាលរបស់ខ្លួនមនុស្ស? នេះជាហេតុដែលនិពន្ធនិទាន លោកឲ្យមើលរឿងសិរី ឬស្រីទីពីរនៅលើទ្រូង ព្រោះនៅក្នុងទ្រូងមានបេះដូង ដែលបេះដូងគឺជាទីស្នាក់អាស្រ័យរបស់ចិត្ត ដែលចិត្តនេះជាធំជាប្រធានលើខន្ធទាំងប្រាំ ពេលដែលចិត្តចុតិ មានន័យថាស្លាប់។ ហេតុនេះហើយក្នុង

រឿងធនជ័យ និពន្ធនិទានផ្តើមរឿងគឺម្តាយធនជ័យយល់សប្តិផង យល់សូងផង យល់សប្តិបេះដូងបេះបានទាំងផ្លែ យល់សប្តិឃើញខែ១ពេញបូណ៌មី។ បើចង់ដឹងរឿងក្នុងដូង(បេះដូង) ទាល់តែចាក់ទឹកដូងចេញពីទ្រូងម៉ែ ឬមាតា (មីឡូងមីឡៃ មីឡូងមីឡា) ទើបឃើញរឿងសិរីបីប្រការ ដែលសិរីទីពីរគឺនៅក្នុងបេះដូង ដែលស្ថិតនៅដើមទ្រូងនេះ (សូមមើលការពន្យល់បន្ថែមក្នុងភាគទី១)។ យើងអាចចាក់ទឹកបេះដូងចេញពីក្នុងទ្រូងមកបាន ទើបដឹងរឿងស្រី ឬសិរី ពុំមែនយកទឹកទៅលាបលាងពីខាងក្រៅ ហើយដឹងរឿងសិរីនោះឡើយ ត្រូវព្យាយាមគិតពិចារណា ពីការបំពេញពលិកម្មរបស់ស្ត្រីមានឈ្មោះថាម៉ែនេះ ដែលរឿងរបស់ពួកគាត់បានយកទៅលាក់កប់ទុកក្នុងបេះដូងគឺចិត្ត។ មាតាបិតានៃគ្រួសារមួយ ព្រួយបារម្ភណ៍ត្រឹមគ្រួសារមួយ រីឯឪពុកម្តាយដែលគ្រប់គ្រងសហគមន៍ ឬប្រទេសមួយ តែងព្រួយបារម្ភណ៍ពីកូនចៅបង្កើតខ្លួនឯងផង ព្រួយបារម្ភណ៍ពីប្រជារាស្ត្រ ដែលខ្លួនជាអ្នកដឹកនាំធ្វើជាម៉ែឪគេផង។ ព្រះបាទជ័យវរ្ម័នទីព៧លោកបានពោលជាគាថាក្នុងចិត្តទុកថា «ទុក្ខវេទនារបស់រាស្ត្រ (ផ្លូវកាយផ្លូវចិត្ត) ឈឺចាប់ជាងអាពាធដែលកើតលើខ្លួនរបស់ខ្ញុំទៅទៀត ព្រោះប្រជារាស្ត្រគឺជាសរសៃឈាមនៅក្នុងខ្លួនរបស់ខ្ញុំ»។ ហេតុនេះទើបមានរូបចម្លាក់ព្រហ្ម ដែលមានមុខប្រាំបី នៅចំប្រាង្គកណ្តាលប្រាសាទបាយ័ន្ត គឺព្រហ្មមុខ៤ត្រួតលើព្រហ្ម៤ទៀត (មើលក្របខាងមុខសៀវភៅបណ្តាំអច្ឆរមាតាមហានគរភាគ២) ដែលន័យមុខព្រហ្មថ្នាក់ទី១ ជានិមិត្តរូបតាងឲ្យព្រហ្មវិហារធម៌ មាតាបិតាបង្កើតរបស់កូន ផ្សាយទៅលើកូនប្រុសស្រីរបស់ខ្លួន។ ព្រហ្មមុខ៤ត្រួតពីលើព្រហ្មមុខ៤ខាងក្រោម ជានិមិត្តរូបព្រហ្មវិហារធម៌របស់អ្នកគ្រប់គ្រងនគរ ផ្សាយគ្របដណ្តប់ទៅលើប្រជារាស្ត្ររបស់ខ្លួន នេះជាអត្ថន័យព្រហ្មមុខ៨ ដែល៤ខាងក្រោមផ្សាយគ្របថែរក្សាលើកូនប្រុសស្រី ៤ខាងលើផ្សាយគ្របថែរក្សាកូនខ្មែរគឺប្រជារាស្ត្រ។ ចំណែកឯព្រហ្មចុងក្រោយ ដែលធំជាងគេនេះគឺព្រហ្មមានមុខ១២ ព្រហ្មត្រួតលើព្រហ្មមានមុខ៨ ដែលនៅក្នុងរូបចម្លាក់ពីបុរាណ ដូនតាខ្មែរបានឆ្លាក់ទុករួចមកហើយ។ ព្រហ្មមុខ១២នេះ ជានិមិត្តសញ្ញាតាងឲ្យព្រហ្មវិហារធម៌ ផ្សាយគ្របថែរក្សាកូនប្រុសស្រី ថែរក្សាប្រជារាស្ត្រ និងចុងក្រោយគឺផ្សាយគ្របទៅលើសព្វសត្វលោកក្នុងភពទាំង៣ ដែលមានកាមភព រូបភព និងអរូបភព គឺជាព្រហ្មវិហារធម៌របស់ព្រះពោធិសត្វគ្រប់ព្រះអង្គ ដែលខំសន្សំបារមី ទ្បេងតែនឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ។ ព្រោះព្រះទ័យរបស់ព្រះអង្គ ប្រកបដោយមហាករុណាទិគុណ

សុខចិត្តលះបង់ រួចហែលឆ្លងនូវមហាសមុទ្រសង្សារវដ្ដដ៏សែនវែងឆ្ងាយ ដើម្បីសន្សំនូវបារមី ១០ ឧបបារមី១០ និងបរមត្ថបារមី១០ឲ្យពេញបរិបូណ៌ សម្រាប់ជួយស្រោចស្រង់សត្វលោក ឲ្យបានរួចផុតពីវដ្ដសង្សារទុក្ខ។ ហេតុនេះមេនាគ(មេដ៏ប្រសើរ)ត្រូវមានបី មេនាគទី១និមិត្តរូបមុខព្រហ្មថ្នាក់ទី១ គឺមាតាបិតាបង្កើតកូនប្រុសស្រី មេនាគទី២និមិត្តរូបមុខព្រហ្មថ្នាក់ទី២ គឺជាមាតាបិតារបស់ប្រជារាស្ត្រ មេនាគទី៣និមិត្តរូបមុខព្រហ្មថ្នាក់ទី៣ គឺជាមាតាបិតារបស់សព្វសត្វក្នុងភពទាំង៣ ដែលព្រះអង្គគឺជាមេនាគធំជាងគេ ដឹកនាំសត្វលោកឲ្យរួចផុតពីវដ្ដសង្សារ នាំទៅដល់ត្រើយគឺអមតៈមហានិព្វាន។ ហេតុអ្វីក្រុងរាពណ៍ក្នុងរឿងរាមាយណៈឥណ្ឌា មានមុខតែមួយ ចំណែកឯក្រុងរាពណ៍ក្នុងរឿងរាមកេរ្តិ៍ខ្មែរ មានមុខ១០ទៅវិញ? បើដូនតាខ្មែរចម្លងពីឥណ្ឌា តើមុខ៩ទៀតដែលលើសពីក្រុងរាពណ៍ឥណ្ឌា មុខលើសទាំងនេះបានមកពីណា?

រឿងសិរីទីពីរនៅលើទ្រូងនេះ គឺទាក់ទងនឹងរឿងកបិលមហាព្រហ្មមានតែសិរសា (ក្បាល) ព្រោះចាញ់ប្រស្នាខ្លួនឯង ក្នុងការភ្នាល់ជាមួយធម្មបាល ចុងបញ្ចប់នៃរឿងបានត្រឹមតែជាប់ឃុំនៅក្នុងរូងគុហារភ្នំព្រះសុមេរុ(មេរុ)។ ចង់ដឹងរឿងកបិលមហាព្រហ្មដែលមាននៅលើថ្មប្រាសាទ និងនៅក្នុងរឿងនិទានកបិលមហាព្រហ្ម ទាល់តែរកអត្ថន័យស្រី(សិរី)បីប្រការឲ្យឃើញ ទើបអាចដោះប្រស្នាអាថ៌កំបាំងដូនតាបាន។ ហេតុនេះបានជានៅក្នុងរឿងធនជ័យនិពន្ធនិទានលោកបានឲ្យតួអង្គនេះ ដើរស្វែងរកស្រី(សិរី) ហើយលោកចង់ឲ្យពូជជ័យសម័យខាងក្រោយបានដឹងថា អ្នកបង្កើតពាក្យស្រែកជ័យហោង(ជ័យផង) សួស្ដីហោង(សួស្ដីផង) ដែលយើងតែងឮអាចារ្យស្រែកក្នុងពិធីមង្គលនោះ ពាក្យនោះចេញមកពីណា។ តើធម្មបាលកុមារជាអ្វី? ធម្ម = ធម្មជាតិ បាល = ទ្វារបាល(អ្នករក្សាទ្វារ) ធម្មបាលគឺជាអ្នកស្រាយបើកនូវប្រស្នាទ្វារធម្ម របស់កបិលមហាព្រហ្ម ដែលជាប្រស្នាអាថ៌កំបាំងរបស់កបិល មហាព្រហ្មចាញ់ភ្នាល់ព្រោះរឿងសិរី(ស្រី)បីប្រការ នៅសល់តែសិរសា(ក្បាល) ដែលដឹតជាប់ក្នុងថ្មប្រាសាទ ដែលមានក្នុងរឿងនិទាន។

គ.សិរីទីបីនៅលើជើង យើងតែងនាំគ្នាយកទឹកទៅលាងជើង ស្វែងរកសិរីក្នុងពេលល្ងាច ដោយសំគាល់ថាសិរីពេលល្ងាចនៅជើង។ ហើយក្នុងពេលលាងជើងនោះទៀត ពុំដែលបានផ្ងារបាតជើងឡើងមកលាងឡើយ គឺនាំគ្នាលាងតែខ្នងជើង ដោយយកបាតជើង

ម្ខាងទៅដុសខ្នងជើងម្ខាង ពុំងាយនឹងឱនលាងបាតជើងទេ។ ដូច្នេះហើយទើបកូនជ័យប្រុសស្រី ពុំងាយនឹងដឹងពីរឿងប្រស្នាបាតរបស់សិរី(ស្រី)ឡើយ ព្រោះយើងលាងត្រឹមតែខ្នងជើង តើនៅលើខ្លួនមនុស្សមានខ្នងប៉ុន្មាន? នៅលើខ្លួនមនុស្សមានខ្នង៥(ប្រាំ)គឺ ខ្នងជើង២(ពីរ) ខ្នងដៃ២(ពីរ) ខ្នងប៉ែកខាងក្រោយពោះ១(មួយ) រួមសរុបជា៥(ប្រាំ)។ និពន្ធនិទានលោកចង់ប្រាប់សិរីចុងក្រោយនៅលើជើងថា បើកូនជ័យខាងក្រោយ នាំគ្នាលាងតែខ្នងដូច្នេះ ធ្វើដូចម្ដេចអាចស្គាល់បាតជើង បាតដៃ និងផ្ទៃមុខនោះទៅ? គ្រូទស្សន៍ទាយ គេអាចមើលវាសនាមនុស្សបាន គឺគេមើលភិនភាគនៅលើបាតដៃ មើលរឿងក្នុងស្នាមព្រះបាទជាន់ទុក គឺមើលស្នាមបាតជើង ពុំមែនមើលស្នាមខ្នងជើងឡើយ មើលសម្គាល់ភិនភាគមនុស្ស គឺគេមើលមុខគេពុំមើលខ្នងឡើយ។ នេះជាប្រស្នាសិរីទីបី ដែលបុព្វាចារ្យនិពន្ធនិទាន លោកឲ្យយើងមើលបាតដៃលជាឬសកែវរបស់រឿងសិរី(ស្រី) ដែលឬសកែវនេះបានធ្វើដំណើរឆ្លងកាត់អតីតកាល មកទល់នឹងបច្ចុប្បន្ននេះមានអាយុរាប់ពាន់ឆ្នាំទៅហើយ ហើយសិរីទីបីនេះ គឺជាកាលចែកពេលវេលាយប់និងថ្ងៃ (យល់សប្តិយល់សូង)។ ដូនតាគាត់ឆ្លាក់ទុកស្នាមព្រះបាទ(ព្រះបាទជាន់ទុក) គាត់ទុកមេបទកំណាព្យ ភុជង្គលីលា(នាគលូនវារទុកស្នាមបាត) ទុកប្រស្នាទាក់ទងនឹងជើងនេះ គឺទិសខាងជើងផ្ទុយពីទិសខាងត្បូង(ក្បាល) ទុកឈ្មោះផ្កាយនាគ ដែលរះនៅទិសខាងជើងសព្វថ្ងៃយើងហៅផ្កាយនាគនេះថា ផ្កាយក្រពើ ខែកត្តិកធ្លាក់ខ្យល់ពីទិសខាងជើង យើងនាំគ្នាប្រារព្ធធ្វើនៅពិធីបុណ្យ អុំទូក អកអំបុក សំពះព្រះខែ និងពិធីបង្ហោះខ្លែងឯក... ..។ល។ ប្រស្នាសិរីទីបីដែលនៅលើជើងនេះ បើនៅក្នុងប្រស្នាព្រះពុទ្ធសាសនា ព្រះអង្គរៀបនឹងបរិនិព្វាន្ត ព្រះសម្មាសម្ពុទ្ធព្រះអង្គផ្ទំក្រោមចន្លោះដើមរាំងភ្នំ ដាក់ព្រះសិរសាទៅទិសខាងជើង ដាក់ព្រះបាទទៅទិសខាងត្បូង បែរព្រះភក្ត្រទៅទិសខាងលិច តើមានអត្ថន័យយ៉ាងដូចម្ដេច? ខាងជើងជាសិរីទីបីនេះដដែល ប្រៀបដូចជាអ្នកជំនាន់ក្រោយ ខាងត្បូងដូចជាអ្នកជំនាន់មុន នៅប្រាសាទនាគព័ន្ធ គាត់បានឆ្លាក់រូបសិរសា(ក្បាល) ព្រះមាតាមហានគរទូលយោនីនៅទិសខាងកើត ឆ្លាក់ក្បាលសេះនៅទិសខាងលិច ឆ្លាក់ក្បាលដំរីនៅទិសខាងត្បូង និងឆ្លាក់ក្បាលរាជសីហ៍នៅទិសខាងជើង តើន័យសិរសារបស់រូបទាំងនោះចង់បង្ហាញពីន័យអ្វី? ដូនតាយើងគាត់ចង់ឲ្យអ្នកទទួលមរតកជ័យជំនាន់ក្រោយ ស្វែងរកដងខ្លួនដែលបានបាត់ គឺខ្លួនព្រហ្ម នាគ មាតាមហានគរ សេះ រាជសីហ៍ និងខ្លួនដំរី តើខ្លួនអ្នកទាំងនោះ នៅឯណា?

ក្បាលដំរីដែលស្ថិតក្នុងទិសខាងត្បូង គឺជាសញ្ញាប្រាប់ថា ខាងលើឬជំនាន់មុន ដែលទីក្រុងក្មែរសម័យអង្គរ ឈ្មោះថាទីក្រុងដំរី ឬយសោធបុរៈ ព្រោះមាននិមិត្តសញ្ញាចម្លាក់ដំរីក្បាលបីមិនមានខ្លួននៅលានជល់ដំរី ក្បាលរាជសីហ៍នៅទិសខាងជើង និមិត្តសញ្ញាខាងក្រោមឬជំនាន់ក្រោយ ក្រុងព្រះសីហនុឬទីក្រុងរាជសីហ៍ ដែលជាទីក្រុងកើតខាងក្រោយ មានចម្លាក់តោថ្មធំពីរ។ នៅជ្រុងទាំងបួននៃប្រាសាទនាគព័ន្ធដែលស្ថិតនៅកណ្ដាលស្រះ ដូនតាគាត់បានឆ្លាក់រូបសត្វរាជសីហ៍ជិះលើសត្វដំរី(រូបនៅសេសសល់សព្វថ្ងៃ មើលស្ទើរពុំយល់) គ្រប់ជ្រុងទាំងបួន។ និមិត្តរូបសត្វរាជសីហ៍ជិះលើសត្វដំរីនេះ ដូនតាគាត់ចង់ឲ្យយើងស្គាល់សត្វមួយថ្មីដែលត្រូវកើតឡើង ពីសត្វពីររួមគ្នា គឺសត្វគុជសីហ៍ ដែលសត្វគុជសីហ៍នេះ មានប្រមោយជាសត្វដំរីផង និងខ្លួនជាសត្វរាជសីហ៍។ ប្រស្នារូបសត្វគុជសីហ៍នេះ យើងអាចមើលឃើញនៅលើផ្ដែរចម្លាក់ប្រាសាទ ហើយចុងប្រមោយរបស់សត្វគុជសីហ៍នេះ ដូនតាច្រើនឆ្លាក់ឲ្យបួងកាន់គប់ផ្កា ឬគប់ភ្លើង ជានិមិត្តសញ្ញាពន្លឺ ដោយបានប្រាប់ថា ភាពខ្មៅងងឹតនឹងត្រូវកំចាត់បង់ នៅពេលដែលកើតមានសត្វគុជសីហ៍ ពេលនោះពន្លឺប្រស្នាសិរី៣ប្រការ(ស្រី)នឹងត្រូវបើកបង្ហាញហើយរះចែងចាំងសារជាថ្មី។ ដូច្នេះសិរីទីបីដែលឆ្លាក់មកដល់ចុងជើង ប្រស្នាបានប្រាប់ឲ្យយើងមើលដំណើរការវិវឌ្ឍន៍របស់នគរ កាលជាខាងក្រោយ ត្រូវបានបើកផ្ទារបាតដែលពីមុនធ្លាប់តែបិទផ្កាប់។ ត្រូវបានផ្ងារឡើងមកលើ ហើយអាចមើលឃើញនូវបាត ដែលជាអតីតកាលបច្ចុប្បន្ននិងអនាគតរបស់ខ្លួន ព្រោះយើងជាពូជជ័យឈប់នាំគ្នាលាងខ្នង មើលខ្នងទៀត ព្រោះបើមើលខ្នងទាំងបី គឺពុំអាចដឹងរឿងពិតរបស់សិរីឡើយ។ និពន្ធនិទានលោកបានយករឿង ស្វែងរកភរិយារបស់ធនជ័យ មកភ្ជាប់រឿងការប្រើពាក្យស្រីនិងញី ដើម្បីឲ្យអ្នកស្ដាប់ ឬអានឆ្ងល់រួចពិចារណា ហេតុអ្វីបានជាគាត់ត្រូវស្វែងរកស្រី ដែលមានឈ្មោះថាសួស្ដី ហើយពាក្យសួស្ដីនេះ យើងតែងឮអាចារ្យស្រែកក្នុងពិធីមង្គលផ្សេងៗ ដែលមានពាក្យថា ជ័យផង សួស្ដីផង (ជ័យហោង សួស្ដីហោង)។ ក្នុងរឿងកបិលមហាព្រហ្មអ្នកដែលអាចដោះប្រស្នាសិរីបីប្រការបាន គឺធម្មបាលកុមារ ឈ្មោះធម្មបាលនេះ និពន្ធនិទានលោកបានដកចេញពី ធម្មបាលជាតក ដែលក្នុងកាលនោះ ព្រះបរមសាស្ដាសមណគោតមបរមគ្រូនៃយើង នៅបំពេញបារមីជាព្រះពោធិសត្វនៅឡើយ ព្រះអង្គមានឈ្មោះថាធម្មបាល។ ដូចនេះធម្មបាលក្នុងរឿងកបិលមហាព្រហ្ម ក៏ជាព្រះពោធិសត្វដែរ គឺព្រះ

ពោធិសត្វព្រះសិរអារ្យមេត្រី ឬព្រះពោធិសត្វលោកេស្វរៈ ដែលដូនតាបានយកឈ្មោះធម្មបាល នេះមកបង្កប់ទុកក្នុងរឿងកបិលមហាព្រហ្ម សម្រាប់ឲ្យកូនក្មេរជំនាន់ក្រោយឆ្ងល់ ហេតុអ្វី សត្វឥន្ទ្រីម៉ែនិងកូនក្នុងរឿងចេះនិយាយរឿងដោះប្រស្នាសិរីបីប្រការ តើសត្វឥន្ទ្រីជាអ្វី? រឿង កបិលមហាព្រហ្មភ្នាល់ដាក់អាយុជីវិត ហេតុអ្វីបានជាសត្វឥន្ទ្រីដឹងចម្លើយសិរីបីប្រការ? និមិត្តរូបទឹកសម្រាប់យកទៅលាងឲ្យកើតសិរី ក៏តាងឲ្យស្រីដែរគឺម៉ែ ដែលមានធាតុទឹក១២ គឺ យកនិមិត្តរូប១២ធាតុទឹកនិមិត្តរូបម៉ែទៅលាង ឲ្យសិរីទាំងបីកាល គឺពេលព្រឹក ថ្ងៃត្រង់ ល្ងាច អតីត បច្ចុប្បន្ន អនាគត តែនៅពុំអាចរកឃើញចម្លើយប្រស្នានេះ ព្រោះយើងភ្លេចចាក់ទឹក ចេញពីទ្រូងម៉ែ និងទ្រូងមាតា(មើលល្បែងចាក់ទឹកដូង)។

ដប់ពីរតាងទឹកលាងរាល់ថ្ងៃ     លាងរឿងសិរីបីប្រការ
លាងជ្រះទាំងមុខទាំងកាយា     តែមើលប្រស្នាស្រីពុំយល់។
ទាល់តែចាក់ទឹកចេញពីទ្រូង     ចូលតាមទ្វារទរូងនិមល
ដោះអាថ៌បុព្វជនបំបាត់ឆ្ងល់     នឹងឃើញហើយយល់រឿងសិរី។
លាក់ខ្លួនបំពួនទុកក្នុងថ្ម     កេរម៉ែសែនល្អប្រពៃណី
ទុកឲ្យពូជជ័យឃើញរាល់ថ្ងៃ     តែមិនយល់ន័យសិរីល្អ។
ជ័យឈ្នះរំស្រែកហ៊ោតែម្នាក់ឯង     ឥតមានខ្លាចក្រែងដើម្បីត
ពូជជ័យសិរីសួស្តីល្អ     ចារទុកលើថ្មសាវតាពិត។
បង្ហាញពូជពង្សសាវតាស្រី     កេរម៉ែប្រពៃណីវិចិត្រ
អច្ឆរាព្រះមេម្ចាស់គំនិត     អច្ឆរិយពិតតាងពូជព្រហ្ម។

ក្រោយពេលដែលសាកសួរឪពុកម្តាយនាងសួស្តីរួចហើយ ឪពុកម្តាយនាងសួស្តីក៏បាន ប្រើឲ្យធនជ័យទៅរកទិញមាន់ ទា ជ្រូក អណ្តើក បើមិនបានអណ្តើកនោះ មេបាយើងមិន ទទួលទេ។ នៅក្នុងពិធីភ្ជាប់ពាក្យ យើងតែងឮដូនតាយើងនិយាយតៗគ្នា ពីរឿងមេអណ្តើក និងកូនអណ្តើក តើសត្វអណ្តើកនៅក្នុងរឿងធនជ័យ ដែលម្តាយឪពុកសួស្តីប្រើធនជ័យឲ្យរក នោះ គាត់ចង់ឲ្យយើងយល់ពីគំនិតអ្វី បង្កប់នៅក្នុងឈ្មោះសត្វនេះ? បើយើងក្រឡេកមើល ទៅក្នុងជាតកគម្ពីររបស់ព្រះពុទ្ធសាសនា យើងបានឃើញរឿងមួយឈ្មោះថា រឿងដំបូក ហុយផ្សែង ឬវម្មកសូត្រ ដែលព្រហ្មជាទេវតាបានមកចោទប្រស្នា ចំពោះកុមារកស្សបៈថា៖

១.អ្វីទៅជាដំបូក

២.ហុយផ្សែងក្នុងពេលយប់

៣.ឆេះចេញជាភ្លើងក្នុងពេលថ្ងៃ

៤.អ្វីទៅជាព្រាហ្មណ៍

៥.អ្វីទៅជាសុមេធ

៦.អ្វីទៅជាសាស្ត្រាវុធ

៧.អ្វីទៅជាការជីក

៨.អ្វីទៅជាសន្ទះទ្វារកង់

៩.អ្វីទៅជាហ៊ឹង

១០.អ្វីទៅជាផ្លូវបែកជាពីរ

១១.អ្វីទៅជាសំពត់តម្រងក្បុង

១២.អ្វីទៅជាអណ្ដើក

១៣.អ្វីទៅជាកាំបិតនិងជ្រុញ

១៤.អ្វីទៅជាដុំសាច់

១៥.អ្វីទៅជានាគ

ប្រស្នាដែលទេវតាបានសួរទៅព្រះកុមារកស្សបៈ គឺមានពាក្យសត្វអណ្ដើកនៅក្នុងប្រស្នាទី១២ ហើយទេវតាដែលបានសួរសំនួរប្រស្នានេះ ទេវតានោះបានពោលថា មានតែព្រះអរហន្តសម្មាសម្ពុទ្ធទេ ដែលអាចដោះស្រាយនូវប្រស្នានេះបាន។ ស្អែកឡើងព្រះកុមារកស្សបៈ បានយករឿងទេវតាសួរប្រស្នានេះ ទៅទូលថ្វាយព្រះសម្មាសម្ពុទ្ធ ដើម្បីឲ្យព្រះអង្គបកស្រាយនូវអត្ថប្រស្នារបស់ទេវតាដែលបានសួរនេះ។ ព្រះអង្គបានត្រាស់សម្ដែងពន្យល់ប្រាប់កុមារកស្សបៈថា៖

១.អ្វីដែលជាដំបូកព្រះអង្គ? ដំបូកគឺរូបរាងកាយរបស់មនុស្សប្រុសស្រី ហើយដំបូកនេះតែងធ្លាក់ចុះក្នុងជរា ព្យាធិ មរណៈ ដំបូកនេះមានទ្វារ៩ គឺទ្វារភ្នែក២ ទ្វារត្រចៀក២ ទ្វារច្រមុះ២ ទ្វារមាត់១ ទ្វារលាមក១ និងទ្វារនោម១។

២.អ្វីហុយផ្សែងក្នុងពេលយប់ព្រះអង្គ? ហុយផ្សែងក្នុងពេលយប់ គឺជាការគិតត្រិះរិះគិត របស់ពួកសត្វទាំងឡាយ តើថ្ងៃស្អែកខ្លួនត្រូវធ្វើកិច្ចការអ្វី ដូចនេះការត្រិះរិះគិតរបស់សត្វគ្រប់អង្គប្រៀបដូចជាផ្សែងដែលហុយចេញពីដំបូក ដែលមានទ្វារ៩នេះ។

៣.អ្វីដែលឆេះចេញជាអណ្ដាតភ្លើងក្នុងពេលថ្ងៃព្រះអង្គ? គឺជាការប្រកបការងារដែលសត្វទាំងឡាយបានត្រិះរិះគិតទុកកាលពីយប់ ធ្វើឲ្យឆេះចេញជាភ្លើងក្នុងពេលថ្ងៃ គឺការប្រកបការងារ ។

៤.អ្វីទៅជាព្រាហ្មណ៍ព្រះអង្គ? ព្រាហ្មណ៍គឺជាព្រះអរហន្តសម្មាសម្ពុទ្ធ។

៥.អ្វីទៅជាសុមេធព្រះអង្គ? សុមេធគឺជាអ្នកប្រាជ្ញ បណ្ឌិត ដែលជាព្រះអរិយបុគ្គលថ្នាក់សេក្ខបុគ្គលចាប់ពីថ្នាក់ សោតា សកទា អនាគា .... គឺព្រះអង្គនៅមានកិច្ចត្រូវសិក្សាបន្ត។

៦.អ្វីទៅជាសាស្ត្រាវុធព្រះអង្គ? សាស្ត្រាវុធគឺជាបញ្ញាដ៏ប្រសើរ ដែលបញ្ញានេះគឺជាបញ្ញាលោកុត្តរៈ ដែលអាចកាប់ឆ្ការនូវព្រៃគឺកិលេសបាន។

៧.អ្វីទៅជាការជីកព្រះអង្គ? ការជីកគឺជាសេចក្ដីព្យាយាមរបស់សុមេធនោះ ដើម្បីជីកគាស់រំលើងឲ្យរបើកនូវអវិជ្ជា។

៨.អ្វីទៅជាសន្ទះទ្វារកង់ព្រះអង្គ? សន្ទះទ្វារកង់គឺអវិជ្ជា ព្រាហ្មណ៍បានប្រើឲ្យសុមេធជីកយកសន្ទះទ្វារកង់គឺអវិជ្ជានោះចេញ។

៩.អ្វីទៅជាសត្វហ៊ឹងព្រះអង្គ? សត្វហ៊ឹងគឺជាសេចក្ដីក្រោធខឹង សេចក្ដីក្រោធនេះ តែកើតឡើងនៅលើចិត្តបុគ្គលណាហើយ វាតែងបំប៉ោងទោសចិត្តឲ្យប៉ោងឡើង ប្រៀបដូចជាសត្វហ៊ឹង ដែលខំប្រឹងបំប៉ោងខ្លួននៅពេលដែលគេប៉ះវា ព្រះអង្គប្រើឲ្យសុមេធលើកហ៊ឹងដែលជាសេចក្ដីក្រោធចេញ រួចប្រើសុមេធឲ្យជីកបន្តទៅទៀត។

១០.អ្វីទៅជាផ្លូវបែកជាពីរព្រះអង្គ? ម្នាលសុមេធ ផ្លូវបែកជាពីរគឺសេចក្ដីសង្ស័យ (វិចិកិច្ឆា) សត្វតែងសង្ស័យខ្លួនឯងថា ធ្វើបុណ្យបានបុណ្យដែរឬទេ? ធ្វើបាបបានបាបដែរឬទេ? សត្វស្លាប់ហើយកើតទៀតដែរឬទេ? ពីជាតិមុនខ្លួនមានអត្តភាពកំណើរជាអ្វី? ក្រោយពីស្លាប់ទៅៗកើតជាអ្វី? .....។ល។ ដូច្នេះសត្វទាំងឡាយសង្ស័យពុំដឹងជាទៅផ្លូវណា ព្រាហ្មណ៍បានប្រើឲ្យសុមេធលើកផ្លូវបែកជាពីរចេញ ហើយឲ្យជីកបន្តទៀត។

១១.អ្វីទៅជាសំពត់តម្រងក្បុងព្រះអង្គ? ម្នាលសុមេធ សំពត់តម្រងក្បុងគឺនីវរណធម៌៥ មាន ១-កាមច្ឆន្ទៈ សេចក្ដីប្រាថ្នាឬការពេញចិត្តចំពោះកាម; ២-ព្យាបាទៈ គំនុំឬសេចក្ដីគុំគួន ធ្វើឲ្យអ្នកដទៃវិនាស; ៣-ថីនមិទ្ធៈ ការច្រអូសធុញទ្រាន់និងការងងុយដេក; ៤- ឧទ្ធច្ច-កុក្កុច្ចៈ សេចក្ដីរាយមាយនិងសេចក្ដីរសាប់រសល់ឬក្ដៅក្រហាយក្នុងចិត្ត; ៥-វិចិកិច្ឆា សេចក្ដីសន្ទិះសង្ស័យមិនដាច់ស្រេចក្នុងចិត្ត : នីវរណធម៌ជាទំនាស់នៃសមាធិ។ ព្រាហ្មណ៍បានប្រើឲ្យសុមេធលើកនីវរណធម៌ចេញ ហើយជីកបន្តទៅទៀត។

១២.អ្វីទៅជាអណ្ដើកព្រះអង្គ? ម្នាលសុមេធ អណ្ដើកគឺជាឧបាទានក្ខន្ធ៥ មានរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ចូរអ្នកលើកយកសត្វអណ្ដើកចេញ ហើយជីកបន្តទៅទៀត។

១៣.អ្វីទៅជាកាំបិតនិងជ្រុញព្រះអង្គ? ម្នាលសុមេធ កាំបិតនិងជ្រុញគឺកាមគុណ៥ មានរូប សម្លេង ក្លិន រស ផោដ្ឋព្វ ម្នាលសុមេធចូរអ្នកលើកយកកាំបិតនិងជ្រុញចេញ ហើយជីកបន្តទៅទៀត។

១៤.អ្វីទៅជាដុំសាច់ព្រះអង្គ? ម្នាលសុមេធ ដុំសាច់គឺឈ្មោះរបស់នន្ទិរាគៈ គឺជាការត្រេកត្រអាលជាប់ស្អិតនៅក្នុងកាមគុណទាំង៥ រួចកាប់ចិញ្ច្រាំដុំសាច់នេះ ធ្វើឲ្យសាច់ជាប់ស្អិតប្រឡាក់ជាប់នៅលើជ្រុញនិងកាំបិត គឺធ្វើឲ្យសត្វជាប់នៅក្នុងភព(កាមភព រូបភព អរូបភព) ព្រាហ្មណ៍បានប្រើឲ្យសុមេធលើកដុំសាច់ចេញរួចជីកបន្តទៀត។

១៥.អ្វីទៅជានាគព្រះអង្គ? ម្នាលសុមេធ នាគគឺជាព្រះខីណាស្រពជាព្រះអរហន្ត ម្នាលសុមេធអ្នកចូរទុកនាគនោះ ហើយគោរពបូជាចំពោះនាគនោះ។

នៅក្នុងប្រស្នាដំបូកហុយផ្សែងខាងលើ មានសត្វហ៊ីង អណ្ដើក និងនាគ សត្វអណ្ដើកគឺតំណាងឲ្យឧបាទានក្ខន្ធ៥ មេអណ្ដើកគឺមេខន្ធ៥ ដូច្នេះមេអណ្ដើកគាត់តែងនាំបុរស(ខន្ធ៥) ទៅជួបស្ត្រី(ខន្ធ៥) ឲ្យបានគ្នាជាប្ដីប្រពន្ធ នេះជាប្រស្នាដែលនិពន្ធនិទាន បានប្រើពាក្យឲ្យរកសត្វអណ្ដើក។ ចំណែកឯកូនអណ្ដើក ក៏ជានិមិត្តរូបខន្ធ៥ដូចមេអណ្ដើកដែរ មេអណ្ដើកចាប់កូនអណ្ដើកមកផ្គុំគ្នា បង្កើតបានជាភរិយាស្វាមី រួចបង្កើតបុត្រាបុត្រី ជានិមិត្តរូបខន្ធ៥ដែលមានឧទាហរណ៍ក្នុងរឿងដំបូកហុយផ្សែងជាភស្ដុតាងស្រាប់។ សត្វហ៊ីងនិមិត្តតំណាងឲ្យសេចក្ដីក្រោធ ម្ចាស់ទឹកដីមានឈ្មោះថា ព្រះនាងហ៊ីងធរណី ដូនតាគាត់បានឆ្លាក់រូបព្រះនាងហ៊ីងធរណី ឈរពីលើសត្វក្រពើរួចច្បូតសក់បញ្ចេញទឹក តើឈ្មោះព្រះនាងហ៊ីងធរណី

ដែលជានិមិត្តរូបស្ត្រីម្នាក់ ឈរលើសត្វក្រពើរូចច្បូតសក់ តើមានអត្ថន័យដូចម្ដេច? សត្វហ៊ីង និមិត្តរូបតំណាងសេចក្ដីក្រោធ ធរណីនិមិត្តរូបតំណាងឲ្យដី ច្បូតសក់តំណាងឲ្យរឿងព្រះនាងសក់ក្រអូបនៅប្រាសាទបាយ័ង្កកោ ច្បូតសក់ចេញទឹកនិមិត្តរូបម្ដាយធាតុទឹក១២ ទឹកចេញពីក្បាលតាមសរសៃសក់ គឺនិមិត្តរូបតំណាងឲ្យបញ្ញាដ៏ក្រអូបរបស់ម្ចាស់មរតកអច្ឆរិយ ក្រពើនិមិត្តរូបតំណាងឲ្យសត្វដែលរមិលគុណ។ ទើបគាត់ឈរជាន់ក្រពើឲ្យលិចចុះដោយក្ដីក្រោធ (សត្វហ៊ីង) ព្រោះអ្នកទទួលមរតកគាត់ពុំស្គាល់គាត់ ពុំដឹងគុណគាត់ ហើយថែមទាំងជេរប្រមាទមើលងាយគាត់ ដូច្នេះសត្វក្រពើត្រូវលិចចុះដោយអំណាចទឹកចិត្ត ដែលហូរចេញពីសក់ដែលគាត់ច្បូត។ ដូច្នេះទើបដូនតាដាក់ឈ្មោះឲ្យរូបចម្លាក់នេះថា ព្រះនាងហ៊ីងធរណី ព្រោះគាត់ជាម្ចាស់អ្នកកកើតទឹកដីមាតុភូមិនេះ ហើយមរតករបស់គាត់កូនខ្មែរគ្រប់ជំនាន់បានទទួលកេរមរតកនេះបន្តគ្នា ក្រោយពេលយើងបោះបង់ចោលក្រុងអង្គរជាងមួយរយឆ្នាំ សាវតាប្រវត្តិរបស់ពួកគាត់ត្រូវបានដាច់បាត់ ដែលយើងមិនអាចស្វែងរកឬសកែវរបស់គាត់បាន ភាគច្រើនបានត្រឹមតែសិក្សារពីការស្រាវជ្រាវរបស់បរទេស។ សត្វនាគជានិមិត្តរូបឲ្យព្រះនាងនាគ(មើលការពន្យល់ពាក្យនាគក្នុងវចនានុក្រម សម្ដេចព្រះសង្ឃ) ដែលជាម្ចាស់ទឹកដីដំបូង ហើយឈ្មោះនេះត្រូវបានបំបែកក្នុងរឿងព្រេងគឺ ព្រះនាងហ៊ីងធរណី ព្រះនាងសក់ក្រអូប ព្រះនាងអាក់អរ ព្រះនាងក្រពុំឈូក ព្រះនាងរំសាយសក់ ព្រះនាងទិព្វសេតាច័ន្ទ ព្រះនាងវិមានច័ន្ទ ... សូមមើលបន្ថែមបណ្ដាំមាតាមហានគរទាំង៤ភាគ។ កម្មទាំងឡាយដែលសត្វបានសាបព្រោះហើយ រមែងឲ្យផលទៅតាមកម្មដែលបានសាបព្រោះនោះ លុះត្រាតែបានត្រាស់ដឹង អរិយមគ្គអរិយផលថ្នាក់ខ្ពស់ ទើបកម្មទាំងនោះក្លាយជាអហោសិកម្មបាន គឺកម្មឈប់ឲ្យផលបន្តទៀត(និព្វាន)។

ក្នុងពិធីភ្ជាប់ពាក្យនេះក៏មានពាក្យមួយ ដែលគេហៅថាស្លាដក់ស្លាកន្សែង តើពាក្យនេះមានន័យដូចម្ដេច? ស្លាបានដក់ទុកក្នុងថ្នក់កន្សែង បង្កើតបានជាពាក្យស្លាពាន់ម្លូពាន់(ព័ន្ធ) តើពាក្យពាន់ឬព័ន្ធមួយណាពិត? ព័ន្ធគឺម្លូ ស្លា កំបោរព័ន្ធចូលគ្នា ចំពោះអ្នកហូបម្លូ ដែលបង្កើតបានជាពាក្យប្រដៅថា «អ្នកទាំងបីអួតខ្លួនសុទ្ធតែជាអ្នកខ្លាំង កើតជាចម្បាំងឈាមធ្លាក់ដល់ដី»។ ពាន់មួយទៀតគឺរឿងម្លូស្លាកំបោរនេះ មានអាយុកាលរាប់រយពាន់ឆ្នាំហើយ ដែលបានក្លាយទៅជាមរតករបស់ម៉ែ ពីដើមពេលដែលម៉ែចាស់តែងបរិភោគម្លូស្លា រហូតមាន

ពាក្យស្លោកថា «ស៊ីម្លូស៊ីឲ្យច្រៀក កុំបីបៀកទាំងមូលមិញ តូចធំឲ្យច្រៀកចេញ តាមពាក្យចាស់ថា អភ័ព្វ» ហេតុអ្វីត្រូវច្រៀកស្លឹកម្លូ? ព្រោះស្លឹកម្លូជានិមិត្តរូបតាងឲ្យភេទ ឬយោនីរបស់ម្ដាយ ពេលច្រៀកស្លឹកម្លូ ប្រៀបដូចជាបើកទ្វារមាសម្ដាយ ត្រង់នេះនិពន្ធនិទានរឿងធនជ័យ បានបង្ហាញពីមេបទកំណាព្យល្បែងចាក់ទឹកដូងលើកទី២ ចាក់ទឹកដូងពីទ្រូងមាតាកន្ទុយត្រីប្រាក្បាលនាងកុក អកកំបោរចាំកូនស្រង់ **បំពង់ស្រីចាំកូនវែក** ក្បាលម៉ែព្រែកក្អែកជុះអាចម៍ដាក់ក្បាលម៉ែបក់។ ពាក្យជូនស៊ីម្លូស៊ីឲ្យច្រៀក និងពាក្យជូនក្នុងល្បែងចាក់ទឹកដូងបំពង់ស្រី(យោនី ឬភេទស្ត្រី)ចាំកូនវែក គឺមានអត្ថន័យដូចគ្នា ពេលដែលយើងវែកបើកទ្វារយោនីឬភេទម្ដាយ បើម៉ែមានផ្ទៃពោះ នឹងឃើញក្បាលរបស់កូន បើម៉ែទូលភេទឬយោនីខ្លួនឯងលើក្បាល (រូបមាតាទូលភេទ ឬទ្វារមាសនៅប្រាសាទនាគព័ន្ធ) បើកូនវែកទ្វារមាសនោះនឹងឃើញក្បាលរបស់ម៉ែជាពុំខាន នេះជាប្រស្នាបង្កប់ក្នុងកាព្យនេះ។ ចំណែកន័យរបស់ស្លាដក់ស្លាកន្សែង គឺស្លាបានដក់ចងថ្នក់ទុកក្នុងកន្សែង បង្កើតបានជាល្បែងដែលកូនក្មេរនាំគ្នាលេង ក្នុងរដូវផ្លាស់មហាសង្ក្រាន្ត ប្ដូរឆ្នាំចាស់ផ្លាស់ឆ្នាំថ្មី គឺល្បែងលាក់ថ្នក់កន្សែង។ ថ្នក់កន្សែងដែលនាំគ្នាលាក់ក្នុងល្បែងនេះ បានត្រូវលាក់នៅពីក្រោយខ្នង (មើលប្រស្នាខ្នងទាំងបីខាងលើ) ពេលដែលរកកន្សែងលាក់ឃើញ បានត្រឹមតែយកកន្សែងដែលដក់ថ្នក់ ដេញវាយគ្នាតែប៉ុណ្ណោះ ពុំបានស្រាយលាប្រស្នាថ្នក់កន្សែងមើលឡើយ។ ពេលដែលឈប់លេងល្បែងលាក់ថ្នក់កន្សែង ក៏យកថ្នក់កន្សែងនោះមកបង្កើតល្បែងថ្មីបន្តទៀត គឺល្បែងចោលថ្នក់កន្សែង ឬចោលឈូង(ឈោង) គឺបោះថ្នក់កន្សែងឲ្យគ្នាពីម្ខាងទៅម្ខាង អ្នកម្ខាងទទួលឈោងចាប់ថ្នក់កន្សែង បើចាប់បានគឺគប់ឲ្យគ្នាទៅវិញទៅមក ពុំបាននាំគ្នាស្រាយប្រស្នាល្បែងថ្នក់កន្សែងនេះឡើយ។ នេះជាហេតុបង្កើតឲ្យមានប្រស្នាពាក្យស្លាពាន់ ម្លូព័ន្ធ ស្លាដក់ ស្លាកន្សែង ល្បែងលាក់កន្សែងចោលឈូង(ឈោង).... ដែលប្រស្នាមរតកទាំងនេះត្រូវបានលាក់ទុកយ៉ាងស្ងៀមស្ងាត់ ក្នុងប្រពៃណីទំនៀមទម្លាប់ ដោយពុំបានស្រាយប្រស្នាធនជ័យឡើយ។ នៅក្នុងពិធីមង្គលការនេះ មានកិច្ចជាច្រើនទៀត ដែលទាក់ទងនឹងបណ្ដាំប្រស្នាធនជ័យ ដែលគាត់បានបន្សល់ទុកក្នុងពេលរៀបការជាមួយនឹងនាងសួស្ដី (មើលកិច្ចក្នុងពិធីមង្គលការរបស់ក្មេរ) ហើយដែលអ្នកមេបានិងចៅមហា តែងស្រែកបន្តមកខាងក្រោយនោះ គឺពាក្យជ័យហោង(ធនជ័យហោង) សួស្ដីហោង(សិរី = ស្រី សួស្ដីហោង)។

ក្រោយពីរៀបការហើយ ធនជ័យបានទៅជួបនឹងពួកនាម៉ឺនមន្ត្រី ដើម្បីភ្នាល់គ្នាពីរឿងប្រើស្តេច ធនជ័យបានធ្វើសំបុត្រជំពាក់ប្រាក់ ដើរកាន់ចូលទៅសាលាជំនុំ ដែលមានមន្ត្រីតូចធំកំពុងជួបជុំគ្នា ធនជ័យក៏ពោលទៅកាន់នាម៉ឺនមន្ត្រីទាំងនោះថា ខ្ញុំនឹងប្រើស្តេចឲ្យមើល មន្ត្រីទាំងនោះក៏ពោលតបធនជ័យវិញថា ឯងហ៊ានប្រើព្រះករុណាមែនឬ? ធនជ័យឆ្លើយប្រាប់ថា ខ្ញុំហ៊ាន បើដូច្នេះយើងភ្នាល់គ្នា ធនជ័យក៏យកលិខិតជំពាក់ប្រាក់ទៅឲ្យនាម៉ឺនមន្ត្រីទាំងនោះចុះចំនួនទឹកប្រាក់ជំពាក់រួចផ្តិតមេដៃជាកិច្ចសន្យា បើនាម៉ឺនមន្ត្រីទាំងនោះចាញ់ត្រូវសងប្រាក់ តែបើធនជ័យចាញ់វិញធនជ័យនឹងសងតាមចំនួនប្រាក់ ដែលមានក្នុងលិខិតជំពាក់។ ធនជ័យបានប្រាប់ឲ្យនាម៉ឺនមន្ត្រីទាំងនោះទៅទូលថ្វាយព្រះករុណាមុន ទើបធនជ័យធ្វើដំណើរទៅតាមក្រោយ ពេលនោះព្រះមហាក្សត្រមានបន្ទូលទាំងសេចក្តីក្រោធ មកកាន់ធនជ័យថា អាជ័យអាថានឹងមកប្រើអញមែនឬ? ធនជ័យទូលថ្វាយព្រះករុណាថា ខ្ញុំមិនទាន់ហ៊ានប្រើព្រះអង្គឡើយ តែសូមព្រះអង្គបែរព្រះភក្ត្រទៅក្រោយទើបខ្ញុំករុណាប្រើបាន។ ស្តេចសណ្តាប់ហើយក៏បែរព្រះភក្ត្រមើលទៅក្រោយ ហើយក៏បែរត្រឡប់មកវិញ ស្តេចមានព្រះរាជឱង្ការថា ឥឡូវអញបែរទៅក្រោយហើយ ឯងប្រើអញចុះ ធនជ័យបានក្រាបទូលតបទៅព្រះករុណាវិញថា នេះហៅថាប្រើហើយព្រះអង្គ គឺខ្ញុំព្រះករុណាប្រើឲ្យព្រះអង្គបែរព្រះភក្ត្រទៅក្រោយហើយ ខ្ញុំព្រះករុណាពុំអាចប្រើឲ្យព្រះអង្គទៅទូលរែករបស់អ្វីក៏ទេដែរក្រាបទូល។ ស្តេចស្តាប់ហើយក៏នៅស្ងៀមពុំមានព្រះបន្ទូលអ្វីឡើយ ដោយចាញ់ប្រាជ្ញាបញ្ឆោតរបស់ធនជ័យ ធនជ័យក៏ក្រាបថ្វាយបង្គំលាព្រះអង្គ បានឱកាសក៏ទៅទារប្រាក់ជំពាក់ពីនាម៉ឺនមន្ត្រីដែលភ្នាល់ជាមួយនឹងខ្លួនហើយត្រូវចាញ់នោះ ប្រមូលយកទៅឲ្យប្រពន្ធទុកដាក់ រួចក៏នៅជាសុខទៅ។ ហេតុអ្វីបានជាធនជ័យត្រូវប្រើស្តេច? តើធនជ័យគាត់ចង់ឈ្នះប្រាក់ពីពួកនាម៉ឺនមន្ត្រីទាំងនោះឬ?

ន័យទីមួយ ធនជ័យប្រើស្តេចព្រោះគាត់ចង់ដឹងថា ព្រះនគរដែលខ្លួនបានដោះឲ្យរួចពីការប៉ុនប៉ងយកនគរធ្វើជាចំណុះរបស់បរទេសនោះ បើខ្លួនគាត់មានកំហុស តើស្តេចអាចលើកលែងទោសឲ្យគាត់បានដែរឬទេ?

ន័យទីពីរ បើបរទេសមានបំណងចង់យកព្រះនគរទៀត តើស្តេចព្រមស្តាប់មតិយោបល់របស់ខ្លួនដែរឬអត់ ក្នុងពេលដែលមានបញ្ហាកើតឡើង បើស្តេចព្រមស្តាប់គំនិត

យោបល់គាត់អត្ថន័យដូចជាគាត់ប្រើស្ដេចបាន តែបើស្ដេចពុំស្ដាប់គំនិតយោបល់គាត់ គឺគាត់ប្រើស្ដេចពុំបានឡើយ។ នេះជាហេតុដែលនិពន្ធនិទានធនជ័យ បានយករឿងប្រើស្ដេចទៅភ្ជាល់ជាមួយពួកនាម៉ឺនមន្ត្រី ដែលពុំយល់ហេតុផល ស្អប់បណ្ឌិតអ្នកប្រាជ្ញ បានត្រឹមតែចេះលើកជើងសរសើរ ឲ្យចេះភ្ញាក់ស្មារតីពិចារណារកហេតុផល និងយល់ពីបំណងរបស់អ្នកប្រាជ្ញដែលចង់ឲ្យនគរបានសុខនឹងរុងរឿង។

ន័យទីបី និពន្ធនិទានចង់ប្រាប់អ្នកដឹកនាំគ្រប់ជំនាន់ ត្រូវចេះស្ដាប់ពីមតិយោបល់របស់ប្រជារាស្ត្រ ដែលជាមនុស្សថ្នាក់ក្រោម ពេលដែលពួកគាត់សំណូមពរចង់បាននូវអ្វី ដែលត្រឹមត្រូវតាមច្បាប់មនុស្សធម៌ និងគុណធម៌ អ្នកដឹកនាំគ្រប់គ្រងត្រូវតែធ្វើតាម ការចង់បាននោះ ព្រោះអ្នកដឹកនាំគ្រប់លំដាប់ថ្នាក់ ជាអ្នកបំរើរបស់ប្រជារាស្ត្រ សេដ្ឋីជាអ្នកបំរើទុកប្រាក់ឲ្យកម្មករ.... ប្រជារាស្ត្របានសុខ អ្នកដឹកនាំគ្រប់គ្រងត្រូវមានព្រហ្មវិហារធម៌។

ពួកនាម៉ឺនមន្ត្រីទាំងនោះ ពេលដែលចាញ់ភ្នាល់ជាមួយនឹងធនជ័យ អស់ប្រាក់យ៉ាងច្រើននោះ ក៏នាំគ្នាឡើងទៅទូលពិតថ្វាយស្ដេចឲ្យស្ដេចក្រោធខឹងដែរ រួចក៏រិះរកគំនិតដើម្បីកំចាត់ធនជ័យឲ្យចេញពីព្រះនគរ។ មន្ត្រីទាំងនោះក៏ទូលថ្វាយស្ដេចថា សូមព្រះអង្គបំបរបង់ធនជ័យឲ្យទៅនៅស្រុកចិន(ចិន្ត) ព្រោះចិនស្រុកគេធំ ម្យ៉ាងទៀតចិនគេស្អប់ធនជ័យ ពេលគេឃើញវាទៅដល់ ពួកគេនឹងសម្លាប់វាជាពុំខាន។ ពិភាក្សាគ្នារួចហើយ ស្ដេចប្រើអាមាត្យឲ្យកោះហៅធនជ័យចូលគាល់ រួចក៏ប្រាប់ពីរាជបំណងរបស់ខ្លួន យើងនឹងបំបរបង់ឯងទៅនៅស្រុកចិនឯណោះ ត្បិតស្រុកចិនគេធំ ឯងនៅស្រុកខ្មែរនេះពុំបានឡើយ។ ធនជ័យបានដឹងពីរាជបំណងបំបរបង់ទៅស្រុកចិន របស់ស្ដេចនិងពួកនាម៉ឺនមន្ត្រី ដោយសារខឹងនឹងខ្លួនក្នុងការចាញ់ភ្នាល់ គាត់ក៏រៀបចំតវ៉ាន់ចុះក្នុងសំពៅ ដែលត្រូវទៅធ្វើជំនួញនៅស្រុកចិន។ ពេលទៅដល់ស្រុកចិនហើយ ធនជ័យក៏ផ្ដាំតាមអ្នកជំនួញឲ្យទៅប្រាប់ប្រពន្ធខ្លួនថា សូមនាងកុំគិតទន្ទឹងមើលផ្លូវយើងឡើយ យ៉ាងយូរ៧ខែចិនគេនឹងជូនអញត្រឡប់ទៅវិញហើយ សូមនាងកុំព្រួយបារម្ភឡើយ។

## VII.<u>អ្នកប្រាជ្ញជ័យផ្ចាញ់ស្ដេចចិន</u>

ដោយការខឹងក្រោធច្រណែននិន្ទាភ័យខ្លាច ស្ដេចនាម៉ឺនមន្ត្រីរួមគំនិតគ្នាបំបរបង់ធនជ័យចេញពីព្រះនគរ ដោយពុំមានការស្ដាយស្រណោះ ដោយអ្នកទាំងនោះ បានប្រើកល្បិចខ្ចី

ដៃបរទេសឲ្យជួយសម្លាប់អ្នកប្រាជ្ញរូបនេះ កុំឲ្យមានជីវិតរស់នៅលើលោកនេះតទៅទៀត ព្រោះហេតុតែយល់ខុស។ ពួកគេពុំបាននឹកឃើញពីឧបការរបស់បុគ្គលនេះ ពេលដែលបរទេសឈ្លានពានចង់បានព្រះនគរជាច្រើនលើក ពួកគេបានត្រឹមតែរួញខ្លួនដូចជាសត្វអណ្ដើកនៅក្នុងស្នូក ពេលដែលអ្នកប្រាជ្ញដោះភ័យធំរួច កំហុសជាប្រស្នាតិចតួច បែរជាពុំយល់បានយកអ្នកប្រាជ្ញម្នាក់ទៅឲ្យគេជួយសម្លាប់ នេះពិតជាបុគ្គលរមិលគុណ មិនដឹងគុណទោសមែន។

ធនជ័យទៅដល់ស្រុកចិន មិនដឹងប្រកបមុខរបរអ្វីដើម្បីចញ្ចឹមជីវិត ព្រោះខ្លួនមិនទាន់ស្គាល់ស្ថានភាពស្រុកទេសរបស់គេ ដូច្នេះមានតែទៅធ្វើជាខ្ញុំចិនសិន គឺទៅបម្រើការឲ្យអ្នកមានចិនណាម្នាក់ ដើម្បីចញ្ចឹមជីវិតនិងសន្សំប្រាក់ រួចបង្កើតមុខរបរដោយខ្លួនឯង។ ការប្រឹងប្រែងរបស់គាត់ក៏បានសម្រេច ពេលដែលគាត់សន្សំប្រាក់ ល្មមអាចធ្វើជាដើមទុនបាន គាត់ក៏បង្កើតមុខរបរថ្មីមួយដោយខ្លួនឯង គឺធ្វើនំបញ្ចុក(ប៉ែនចុក) រែកដើរលក់។ ក្នុងសម័យនោះ ចិននូវពុំទាន់ស្គាល់នំសរសៃវែងៗនេះ ក៏នាំគ្នាទិញបរិភោគ រហូតដល់ធ្វើឲ្យឈ្មោះនំនេះ ល្បីសុះសាយពីមាត់មួយទៅមាត់មួយៗទៅដល់ស្ដេចចិន។ ពេលនោះហើយដែលអ្នកប្រាជ្ញរូបនេះមានឱកាសចូលទៅក្នុងរាជវាំង ដើម្បីមើលមុខស្ដេចចិនឲ្យបានច្បាស់ តើស្ដេចនេះមានមុខយ៉ាងម៉េច បានជាចង់បាននគរក្មែរអញខ្លាំងម្ល៉េះ? ពេលដែលធនជ័យរែកនំបញ្ចុកទៅជួបនឹងស្ដេចចិន ស្ដេចចិនក៏សួរធនជ័យថា នំនេះឈ្មោះនំអ្វី? ធនជ័យឆ្លើយតបទៅស្ដេចវិញថា នំនេះឈ្មោះនំបញ្ចុក(ប៉ែនចុក) ស្ដេចចិនក៏សួរធនជ័យទៀតថា តើនំនេះគេស៊ី(សោយ)ដូចម្ដេច? ធនជ័យឆ្លើយថា ព្រះអង្គត្រូវងើយមុខមើលទៅលើ ចាំទូលបង្គំជាខ្ញុំចាប់បញ្ចុក ធនជ័យក៏ចាប់យកចង្កឹះចាប់សរសៃនំ បញ្ចុកស្ដេចចិនរួចក៏ពោលឡើងថា «មើលមុខស្ដេចចិនដូចមុខឆ្កែ មើលមុខស្ដេចក្មែរដូចខែរះពេញបូណ៌មី»។ ពេលតិះដៀលស្ដេចចិនរួច ស្ដេចចិនកើតសេចក្ដីខឹងក្រោធជាខ្លាំង បានបញ្ជាឲ្យរាជអាមាត្យចាប់ធនជ័យ យកទៅដាក់ឃុំក្នុងគុកសំរឹទ្ធ ដើម្បីឲ្យគាត់ស្លាប់ក្នុងអាកាសធាតុដ៏ត្រជាក់។ ក្នុងវគ្គនេះនិពន្ធនិទានដូនតាលោកចង់ឲ្យយើងមើលឃើញនៅប្រស្នារបស់លោកថា ហេតុអ្វីស្ដេចចិនមិនចេះកាន់ចង្កឹះជនជាតិចិន គឺជាជនជាតិដែលមានភាពស្ទាត់ជំនាញ ក្នុងការប្រើចង្កឹះបរិភោគអាហារ ហើយស្ដេចចិនគឺជាអធិបតីលើប្រជាជនរបស់ខ្លួន ដែលមានចំនួនរាប់រយពាន់លាននាក់

ក្នុងការប្រើចង្កិះ (ពូកែលើសប្រជាជន) ហេតុដូចម្តេចស្តេចចិនក្នុងរឿងធនជ័យ មិនចេះកាន់ចង្កិះ បែរជាប្រើឲ្យធនជ័យចាប់នំបញ្ចុកទៅវិញ? ហេតុអ្វីឈ្មោះនំបញ្ចុក បែរជាមានឈ្មោះពិតនៅក្នុងនគរចិនទៅវិញ តើមានបង្កប់អាថ៌ប្រស្នាអ្វីទាក់ទងនឹងសាវតានំនេះ? និពន្ធនិទានលោកបានដាក់ប្រស្នា ឲ្យយើងស្តាប់ អាន រួចឆ្ងល់ហើយពិចារណា រកហេតុផលបង្កប់នៅក្នុងប្រស្នាគំនិតនៃរឿងនេះ។ ពេលដែលយើងបានពិចារណាឈ្វេងយល់ នោះយើងនឹងឃើញពីប្រស្នាគំនិត ដែលនិពន្ធនិទានលោកលាក់គំនិតកប់ទុកក្នុងរឿង ដូចជាពេលស្តេចចិនបញ្ជាឲ្យរាជបុរស ចាប់យកធនជ័យទៅដាក់គុកសំរឹទ្ធ ធនជ័យអាចលួចបង្ហោះខ្លែងឯកបាន តើគុកនោះមានទំហំប៉ុនណា? ទើបធនជ័យអាចបង្ហោះខ្លែងបាន តើគុកនោះជាគុកអ្វី? ហើយន័យពិតរបស់ពាក្យខ្លែងឯកគឺជាអ្វី? ទើបធ្វើឲ្យចិនចុះចាញ់ បើគ្រាន់តែក្រដាសមួយសន្លឹកយកមកដាសខ្លែងបង្ហោះ ហើយចិនចុះចាញ់ក្មេរនោះ ប្រជាពលរដ្ឋបង្ហោះខ្លែងឯករាល់ឆ្នាំក្នុងរដូវរំហើយ ចិនត្រូវចុះចាញ់ពួកគាត់ហើយ។ នេះជាហេតុដែលយើងជាអ្នកស្នងមរតកជ័យជំនាន់ក្រោយ ត្រូវប្រមូលផ្តុំនៅកាកគំនិត(កាកគតិ)ជ័យជំនាន់មុន ក្នុងសម័យមហានគរ យកមកបើកផ្ទារ រួចមើលនៅកាកគំនិតរបស់ដូនតាជ័យ។ យើងអាចមើលឃើញនៅឬសកែវពិត ដែលអាចធ្វើឲ្យបរទេសចុះចាញ់ ដោយពិតប្រាកដបាន ពុំមែនគ្រាន់តែចុះចាញ់មានតែក្នុងរឿងនោះឡើយ គឺត្រូវដោះនៅអាថ៌ប្រស្នារបស់ពួកគាត់ ដែលបង្កប់ទុកក្នុងមរតកអច្ឆរិយនេះ។ ដូចជាប្រស្នាបង្កប់នៅក្នុងព្យញ្ជនៈក្មេរ តួអក្សរ**ធ** និង **ន** នៅជាប់គ្នា តែពុំអាចមើលឃើញគ្នា បង្កើតជាពាក្យធនឡើយ ព្រោះហេតុតែតួអក្សរ**ន**វាខ្វាក់(នខ្វាក់ ន្ល) លុះត្រាតែដកតួអក្សរ**ធ** និង **ន**ចេញពីព្យញ្ជនៈ ទើបបង្កើតពាក្យ**ធន**បាន។ យើងស្គាល់ធនបានព្រោះយើងលែងជាប់ឃុំក្នុងគុកសំរឹទ្ធ(ប្រស្នាដូនតា) ព្រោះក្នុងភាសាបាលី សម្លេងព្យញ្ជនៈ **ន** = នៈ(នាក់) នខ្វាក់មានន័យថា នៈខ្វាក់(នាក់ខ្វាក់) នរណាខ្វាក់?

ស្តេចចិនដែលមិនចេះកាន់ចង្កិះ គឺជាស្តេចនិមិត្តរូបតាងឲ្យស្តេចចិន ដែលនិពន្ធនិទានលោកបង្កើតជាប្រស្នាឡើង ដើម្បីឲ្យយើងគិតពិចារណា។ ម៉្យាងទៀតស្តេចក្តី មន្ត្រីនាម៉ឺន ឬអ្នកមានយសធំៗ តែងប្រយ័ត្នប្រយែងណាស់ក្នុងការសោយ ឬបរិភោគ គឺភាគច្រើនសុទ្ធតែមានអ្នកភ្លក់ម្ហូបអាហារមុន ដោយខ្លាចមានបង្កប់ថ្នាំពុល ចុះហេតុអ្វីស្តេចចិនក្នុងរឿងធនជ័យ គ្មានការប្រុងប្រយ័ត្នដូច្នេះ? រហូតដល់ប្រើធនជ័យឲ្យចាប់នំបញ្ចុកៗថែមទៀត។

នំបញ្ចុកឈ្មោះនំនេះ កើតមានដោយសារធនជ័យបញ្ចុកស្ដេចចិន ឈ្មោះពិតរបស់នំនេះ គឺនំប៉ែនចុក ដែលជានិមិត្តរូបធ្វើទារុណកម្មព្រះមេ តាំងពីនៅគ្រាប់អង្ករគ្រាប់បាយ បានក្លាយខ្លួនជាម្សៅ។ តើទារុណកម្មជានិមិត្តរូបនោះ យ៉ាងដូចម្ដេច? ហេតុម្ដេចបានជាឈ្មោះនំនេះ កើតមានឈ្មោះនៅស្រុកចិន? នំបញ្ចុកមុនដំបូង គេយកអង្ករទៅត្រាំទឹកឲ្យរីក រួចគេយកអង្ករជានិមិត្តរូបព្រះមេ ទៅកិនបំបែកកាយឲ្យក្លាយជាម្សៅ រួចយកទឹកម្សៅនោះទៅចងសង្កត់ស្ពៀត ឲ្យច្រោះទឹកអស់នៅសល់តែម្សៅ រួចយកម្សៅដែលកកផ្ដុំគ្នានោះ ទៅបុកក្នុងត្បាល់ រួចក៏ផ្ដុំយកទៅស្ងោរ ស្ងោររួចយកទៅបុកម្ដងទៀតឲ្យទន់ ទើបផ្ដុំម្សៅនោះជាដុំប៉ុនៗរន្ធប៉ែន ហើយក៏យកទៅញាត់នៅក្នុងរន្ធប៉ែន រួចយកឈើផ្ទួកចុកបិទពីលើ ហើយដាក់ឈើសង្កត់លើផ្ទួកនោះ ឈ្មោះនំកកើតពេលនេះ។ ម្សៅនិមិត្តរូបព្រះមេដែលនៅក្នុងរន្ធប៉ែនដោយកម្លាំងឈើផ្ទួកអង្គុយសង្កត់ពីលើ សរសៃម្សៅត្រូវធ្លាយតាមរន្ធតូចៗរបស់ប៉ែន ហើយទំលាក់ខ្លួនចូលក្នុងខ្ទះទឹកក្ដៅកំពុងពុះ ដែលជានិមិត្តរូបអបាយភូមិ។ គេដួសយកសរសៃនំដែលស្ងោរឆ្អិន ទៅត្រាំក្នុងថ្លាងទឹកត្រជាក់ ទើបគេចាប់សរសៃនំនោះ យកមកពាក់ឆ្វាយលើម្រាមមេដៃ បង្កើតបានជាចង្វាយ ចង្វាយនំនេះគឺជានិមិត្តរូបតំណាងឲ្យភេទរបស់ស្ត្រី(យោនី) ដោយអង្ករជានិមិត្តរូបព្រះមេ មេដៃដែលបង្កើតរន្ធចង្វាយ គឺជាប្រស្នាតំណាងឲ្យភេទម្ដាយ តើនរណាជាប្រមុខមេបង្កើតនូវប្រស្នានេះ? (សូមមើលបណ្ដាំមាតាមហានគរទាំង៤ភាគ)។ កាលខ្លួននៅជាគ្រាប់បាយ កំពុបនឹកស្ដាយដឹងគុណព្រះមេ ពេលក្លាយអំបុក នំបញ្ចុក(ប៉ែនចុក) កំពុបឈប់ស្ដាយ ព្រោះយើងពុំធ្លាប់ព្ដូនតាម៉ែឪ ប្រដៅថាកុំឲ្យកំពុបអំបុកនំបញ្ចុក ត្រូវដឹងគុណព្រះមេ។ ដូចជាផ្កាយព្រឹក ផ្កាយយោង...... ឈ្មោះល្អពេលរះនៅទិសខាងកើត ពេលធ្លាក់ខ្លួនទៅនៅពីទិសខាងលិច ក៏ប្រែឈ្មោះក្លាយជាផ្កាយចោរ តើព្រោះហេតុអ្វី?

នំនេះដែលមានកំណើតឈ្មោះនៅប្រទេសចិន ក្នុងរឿងធនជ័យ ព្រោះអាថ៌កំបាំងការធ្វើទុក្ខទារុណកម្មរបស់ព្រះមេ ត្រូវបានលាក់បំពួនដោយមនោគមវិជ្ជាបរទេស ដូចជាសព្វថ្ងៃយើងអាចដឹងអាថ៌កំបាំងបិសាចពស់ ក៏ត្រូវសិក្សាពីឯកសារចិនជាវតាខ្វាន់។ ហើយរឿងអាថ៌កំបាំងព្រះមេ និពន្ធនិទានលោកបានទម្លាយនៅក្នុងឈ្មោះនំបញ្ចុក(ប៉ែនចុក) អំបុក សរសៃសូត្រ ខ្លែងឯក..... ដែលនិពន្ធនិទានបានបង្កប់ប្រស្នាទារុណកម្មរបស់ដូននាគ ដូនវិមានច័ន្ទ ទិព្វសេតាច័ន្ទ សោមា លីវយី សក់ក្រអូប រំសាយសក់ ហ៊ីងធរណី ក្រពុំឈូក

អាក់អរ អច្ឆរាឬអប្សរា កបិលមហាព្រហ្ម .......។ល។ ឈ្មោះទាំងនេះ ជានិមិត្តរូបតាងឲ្យព្រះមេតែម្នាក់គត់ ដែលគាត់បានហាន់ឈ្មោះគាត់ទៅជាចំណិតៗ ដែលមានឈ្មោះប្រាសាទហាន់ជ័យជាតឹកតាង សម្រាប់ឲ្យយើងជាពូជជ័យជំនាន់ខាងក្រោយពិចារណាប្រស្នា។ គុកសំរឹទ្ធឬគុកត្រដាក់ ដែលចាប់ធនជ័យឃុំ ហើយគាត់អាចបង្ហោះខ្លែងឯកបាន គឺជាគុកមនោគមវិជ្ជា ដែលគុកនេះគ្មានជញ្ជាំង គ្មានស្រមោល គ្មាននិមិត្ត។ ដូចជាសត្វលោកជាបុថុជ្ជន ជាប់ឃុំក្នុងគុកគឺសង្សារវដ្ត តែសត្វលោកពុំបានដឹងថាខ្លួនជាអ្នកទោសជាប់ឃុំក្នុងគុកឡើយ គឺមានតែព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គត្រាស់ដឹងឡើងក្នុងលោក ហើយព្រះអង្គត្រាស់សម្ដែងនូវព្រះធម៌ ទើបធម្មចក្ខុអាចកើតមានឡើង ដល់សត្វមានឧបនិស្ស័យ អាចចេញពីទីឃុំនេះបាន។ ពាក្យថាខ្លែងឯក អ្នកស្រុកខ្លះហៅឈ្មោះខ្លែងនេះថា ខ្លែងឰង ឬញ្ញង ព្រោះស្លាបរបស់ខ្លែងមានរាងដូចជាផ្ទៀងនង្គ័ល ហើយពាក្យខ្លែងនិងក្លែង ភាសានិយាយមានសូរដូចគ្នា យើងពុំដឹងពាក្យមួយណាពិត ថាខ្លែងសរសេរព្យញ្ជនៈខ ឬព្យញ្ជនៈកឡើយ។

ខ្លែង ( ន. ) ឈ្មោះសត្វស្លាបមួយប្រភេទ សម្បុរក្រហមក្រមៅ ត្រង់កមានសម្បុរ-សចំពុះខុប ក្រញ៉ាំជើងចំណាប់មាំ អាចចាប់សត្វតូចៗ ស៊ីបាន ។ (ដកចេញពីវចនានុក្រមសម្ដេច)

ខ្លែង ( ន. ) រូបតំណាងសត្វខ្លែង ធ្វើដោយក្រដាសសម្រាប់បង្ហើរ : ខ្លែងបង្ហើរ, បង្ហើរខ្លែង ។(ដកចេញពីវចនានុក្រមសម្ដេច)

ក្លែង ( កិ. ) ធ្វើឲ្យប្លែកចាករូបរាងដើម ទៅយករូបរាងថ្មី ដើម្បីកុំឲ្យគេស្គាល់ ឬ ពោលឲ្យខុសចាកសំដីដើមទៅពោលសំដីថ្មីដើម្បីកុំឲ្យគេដឹង : ក្លែងរូប, ក្លែងសំដី, ក្លែងសំឡេង។ (ដកចេញពីវចនានុក្រមសម្ដេច)

សូរស័ព្ទនិយាយខ្លែងឯក បើយើងសម្រាយពាក្យតម្រួតនេះ យើងឃើញពាក្យ **ខ + លែង + ឯក** មានន័យថា ខលែងដើរតួជាទីមួយទៀតហើយ(តួឯក) រីឯពាក្យឯកគឺ ឯនិងក បើត្រឡប់ពាក្យឯនិងក គឺអនិងកែ មានន័យថា អកើតឡើងបាន លុះត្រាតែព្រមកែ ហេតុអ្វីត្រូវកែ? ព្រោះពាក្យសរសេរសម្គាល់ជាតិខ្មែរសព្វថ្ងៃ យើងសរសេរខ្មែរនិងខ ជាបណ្ដូលខ្លឹមរបស់ពាក្យ ទើបអ្នកប្រាជ្ញជំនាន់មុន ដោយអាងហេតុក្នុងសិលាចារឹក មានប្រើពាក្យខ្មែរនិងខ ពួកគាត់បានទាញពាក្យខ្មែរសរសេរដោយព្យញ្ជនៈខនេះ ទៅភ្ជាប់នឹងពាក្យខេមរៈ ដែលមាន

ន័យថាអ្នកមានសេចក្ដីក្សេមក្សាន្ត។ ពួកគាត់ភ្លេចគិតពីគ្រោះថ្នាក់ កើតមានចំពោះអ្នកជំនាន់ក្រោយ ដែលពាក្យសម្គាល់ជនជាតិមួយម៉ាត់នេះ ដកយកចេញពីភាសាអ្នកដែនមគធៈ (បាលី) សព្វថ្ងៃជាភាសារបស់ប្រទេសឥណ្ឌា ធ្វើឲ្យផលផ្លែផ្កាទាំងឡាយ ដែលជាមរតករបស់ដូនតា បានក្លាយទៅជារបស់សាសនា។ ដូចជាទស្សនៈរបស់ឧកញ៉ាឈឹមក្រសេម លោកបានទាញហេតុផលថា ជនជាតិខ្មែរយើងធ្វើចំណាកស្រុកចេញពីដែនកុមេរុរដ្ឋ ដែលជារាជវង្សមួយនៅឥណ្ឌាពីអតីតកាល ហើយបានមកបង្កើតរដ្ឋមួយនៅជ្រោយសុវណ្ណភូមិនេះ ដូច្នេះខ្មែរយើង ជាជនជាតិភាគតិច(ព្នង)ឥណ្ឌា ធ្វើចំណាកស្រុកដូចទស្សនៈលោកឈឹមក្រសេមមែនឬ? សូមមើលការបកស្រាយរបស់អ្នកប្រាជ្ញជំនាន់មុន ក្នុងទស្សនៈពាក្យខ្មែរដែលមាននៅក្នុងសៀវភៅប្រវត្តិសាស្ត្រខ្មែរភាគ១និងភាគ២ របស់លោកត្រឹងា សាស្ត្រាចារ្យបរិញ្ញាផ្នែកវប្បធម៌និងអរិយធម៌អាស៊ី និងជាសាស្ត្រាចារ្យប្រវត្តិសាស្ត្រខ្មែរ បង្រៀននៅមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ ក្នុងសតវត្សឆ្នាំ១៩៧០ និងសៀវភៅប្រវត្តិសាស្ត្រផ្សេងៗទៀត ដែលទាក់ទងក្នុងការបកស្រាយពាក្យខ្មែរនឹងព្យញ្ជនៈ**ខ**នេះ។

យើងភ្លេចគិតថាក្រោយពេលដែល ជនជាតិស្យាម ឬសៀមឈ្មោះក្នុងរឿងព្រេងដំបងក្រញូង ពេលដែលបានធ្វើសង្គ្រាមលុកលុយចូលក្រុងអង្គរ ក្នុងអំឡុងសតវត្ស១៣ - ១៤ បានវាយដេញឲ្យជនជាតិខ្មែរ បោះបង់ចោលទីក្រុងអច្ឆរិយនេះ អស់រយៈកាលជាង១០០ឆ្នាំ។ មកដល់រជ្ជកាលព្រះបាទអង្គច័ន្ទរាជា ដោយការធ្វើប្រពាតព្រៃ របស់ស្ដេចអង្គនេះ ជាមួយនឹងជនជាតិព័រទុយហ្គេ ជាអ្នកផ្សព្វផ្សាយគ្រិស្តសាសនា ធ្វើឲ្យការលុកលុយប្រពាតព្រៃនេះ បានជួបប្រទះនៅប្រាសាទបុរាណដ៏ធំស្កឹមស្កៃ ដែលបានលាក់បំពួនកំបាំងក្នុងព្រៃស្មសាន សែនស្ងាត់ជ្រងំ។ តើពេលបរទេសវាយលុកលុយចូល ទីក្រុងអង្គរបានជោគជ័យនោះ គម្ពីរក្បួនខ្នាត និងទ្រព្យសម្បត្តិមានតម្លៃនានា ដែលគេយកទៅពុំរួច គេទុកឲ្យយើងឬដុតកំទេចបំផ្លាញចោល? ដើម្បីលាក់ប្រវត្តិរឿងរបស់ដូនតានៃជនជាតិនេះ ដែលធ្លាប់តែរុងរឿងកាលពីអតីតកាលនោះ តើគេអាចដាប់ឆ្លាក់កែសិលាចារឹកបានដែរឬទេ? ដែលក្នុងរជ្ជកាលសៀមគ្រប់គ្រងជាង១០០ឆ្នាំនោះ? ព្រោះខ្មែរមានពាក្យទំនៀមមួយឃ្លា ដែលខ្ញុំបាទធ្លាប់បានឮចាស់និទានប្រាប់តគ្នាថា «ខ្មែរជាព្រះរាម(រៀម) សៀមជាព្រះលក្ស្មណៈ(លាក់) បារាំងគឺជាយក្ស ជប៉ុនជា

ហនុមាន» សៀមជាព្រះលក្ស្មណៈ តើភាសានិយាយពាក្យលាក់មួយណា សូមមើលការពន្យល់ពាក្យលក្ស្មណៈ

លក្ស្មណៈ ល័ក-ស្មៈ ណៈ សំ. ( ន. ) (លក្ស្មណ) នាមព្រះអនុជរបស់ព្រះរាមជាព្រះរាជបុត្រនៃព្រះបាទទសរថនិងនាងសុមិត្រាទេវី : ព្រះរាមនិងព្រះលក្ស្មណ៍ (សរសេរជា លក្ខណ៍ ឬ លក្សណ៍ ក៏មាន) ។

លាក់ ( កិ. ) ធ្វើឲ្យមានគន្លាក់ : លាក់ឈើ ។

លាក់ ( កិ. ) បិទបាំង, បំបាំងឬទុកមិនឲ្យគេឃើញ មិនឲ្យគេដឹង : លាក់របស់, លាក់ខ្លួន, លាក់ពុត ។ លាក់កំនួច លាក់គំនិតដែលក្បួចកាន់ទុក ឬលាក់ល្បិច, លាក់ចំណេះ ។ លាក់បាំងអ្វី និ. ពាក្យនិបាតសម្រាប់និយាយផ្ដើមប្រាប់សេចក្ដីទៀងត្រង់មិនលាក់មិនបំបាំង : លាក់បាំងអ្វី ខ្ញុំសព្វថ្ងៃនេះទ័លក្រណាស់បានជាមករកខ្ចីប្រាក់អ្នក ។ លាក់លៀប ឬលាក់លៀម លាក់ក្បិតក្បៀតទុកសំចៃ ឬលាក់ទុកនៅកៀនកោះ ។ លាក់សុំ លាក់ទុកត្រដក់ត្រសុំ ។ល។

លក្ខ ល័ក-ខៈ បា. ឬ សំ. ( ន. ) កំណត់; ទីសម្គាល់, គ្រឿងចំណាំ; ចន្លោង; គ្រឿងកំណត់រាប់, ខ្នាត, ទីវ; បុណ្យ, បុណ្យភ័ព្វ, សំណាង ។ សំខ្យា . ចំនួនសែន, មួយសែន (១០០,០០០) ។ លក្ខមូល តម្លៃមួយសែន (ហៅ អនេកត្ថសំខ្យា ប្រើជា ន.) ។

លក្ខណ ល័ក-ខៈ ណៈ បា.; សំ. ( ន. ) (លក្ខណ; លក្សណ) គ្រឿងសម្គាល់, គ្រឿងចំណាំ; គ្រឿងសង្កេតនាខ្លួនប្រាណ ចង្អុលឲ្យឃើញច្បាស់ថាមានភ័ព្វឬឥតភ័ព្វ; គុណសម្បត្តិ : លក្ខណៈមានបុណ្យ, --ឥតបុណ្យ; ហោរទាយលក្ខណៈ ។ លក្ខណញ្ញូ, លក្ខណវិទូ ឬ លក្ខណវិទ អ្នកស្គាល់លក្ខណៈ; ហោរ ។ លក្ខណប្បញ្ញត្តិ បញ្ញត្តិតាមលក្ខណៈច្បាប់ ។ លក្ខណមន្ត ឬ--វិជ្ជា មន្តឬចំណេះសម្រាប់ទាយលក្ខណៈខ្លួនប្រាណ ។ លក្ខណហេតុ ឬលក្ខណការណ៍ ហេតុឬការណ៍ ដែលប្រកបដោយលក្ខណៈ, ដែលត្រូវលក្ខណៈ ។ លក្ខណវិបត្តិ វិបត្តិលក្ខណៈ, ការខូចលក្ខណៈ, ទាស់លក្ខណៈ ។ លក្ខណសម្បត្តិ ការគ្រប់ព្រមដោយលក្ខណៈ ។ លក្ខណាការ អាការនៃលក្ខណៈ ។ល។

លក្ខណ៍ ល័ក ( ន. ) លក្ខណៈ ។ មនុស្សខាតលក្ខណ៍ មនុស្សមានលក្ខណៈអភ័ព្វឬមានឫកពាថោក ។ ស្ត្រីគ្រប់លក្ខណ៍ ស្ត្រីដែលបរិបូណ៌ដោយលក្ខណៈល្អ ។ល។ (សរសេរជា ល័ក្ខណ៍ ឬ ល័ក្សណ៍ ក៏បាន ។ ម. ព. លក្ស្មណៈ ឬ លក្ស្មណ៍ ផង) ។

លក្ត លាក់ សំ.; បា. ( ន. ) លក្តក, អលក្ត, លាក្សា; លាខា, អលត្តក) ជ័រខះរឹងកើត អំពីសត្វល្អិតពួកមួយ មានសម្បុរក្រហម សម្រាប់ប្រើការជ្រលក់សូត្រ, អម្បោះជាដើម : លក្ត ស្រម៉ ។ លក្តដុំកន្លង់ ស្រម៉លក្តដែលដុះព័ទ្ធស្រោបរុំជុំវិញមែកឈើ ។ កាកលក្ត ឬ អាចម៍លក្ត កាករបស់លក្តស្រម៉ ដែលស្ងោររំងាស់អស់ជាតិហើយ, សម្រាប់ប្រើការបិទឬភ្ជួរភ្ជាប់អ្វីផ្សេង ៗ ។ ចងលក្តឬ បន្ទំលក្ត យកស្រម៉លក្តដែលនៅមានសត្វល្អិតជាមេ ដាក់ក្នុងសំបកកាតំស្លឹក ត្នោតជាដើមចងភ្ជាប់នឹងឈើរស់មានដើមសង្កែ, ត្រាំង, ស្នួលជាដើម ដើម្បីឲ្យមេនោះចេញ មកវារវោមមែកឈើ កកើតបានជាស្រម៉លក្តតទៅទៀត : របរចងលក្ត ។ ផង់ល្អិតឬកករឹងជា ដុំមានព័ណ៌ផ្សេងៗ សម្រាប់ប្រើជាគ្រឿងជ្រលក់ : លក្តខៀវ, --បៃតង, --ស្វាយ, --លឿងទុំ... ។ ឈ្មោះឈើឬដំណាំដែលមានសម្បុរដូចលក្តស្រម៉ : ចេកលក្ត, ម្ទេសលក្ត ... ។ (ដកចេញពី វចនានុក្រមសម្ដេច)

ដោយការពន្យល់ពាក្យលាក់ ដែលមានសូរដូចគ្នាខាងលើ តើពាក្យទំនៀមរបស់ដូនតា ដែលថាសៀមជាព្រះលក្ខណៈ តើនៅក្នុងពាក្យលាក់ណាមួយ លាក់រឿងឬលក្ខណៈម្ហូន? កូននាគទាំងអស់សុទ្ធតែធ្លាប់ដឹង បរទេសវាយឲ្យកូនក្មេររត់ផ្លាស់ប្ដូរទីក្រុង ពីទីក្រុងល្វៃមក ទួលគោកធ្លក(អង្គរបុរី) ឈើកាច់បាភ្នំ គូលែន យសោធបុរៈ ឧត្ដុង្គ លង្វែក ចតុមុខ ទួលបា សាន....... និងទីប្រជុំជនទីក្រុងផ្សេងទៀត ដែលប្រវត្តិសាស្ត្រពុំបានចារឹកសរសេរទុក តើមាន ប៉ុន្មាន? ទីកន្លែងខ្លះនៅសល់ត្រឹមបុរាណដ្ឋាន ដែលនៅសល់ខ្លះ និងនៅនិមិត្តខ្លះ ដើម្បីធ្វើការ ស្រាវជ្រាវ ចុះបើពុំសល់វិញ តើយើងទៅរកដានស្នាមឯណាទៅ? បើបរទេសដែលចូលលុក លុយ គេដុតដាប់បំផ្លាញផង បាត់បង់ដោយគ្រោះធម្មជាតិផង ត្រូវបរទេសបង្វែររឿងពិតផង ជាពិសេសគឺអ្នកចេះដឹងជំនាន់នៅក្រោមការត្រួតត្រារបស់សៀម ពួកគាត់តែងទៅរៀនក្បួន ច្បាប់ធម៌អាថ៌ពីប្រទេសសៀម និងពីបរទេសដទៃទៀតនោះ តើយើងអាចទទួលបានសារតា ពិត ពីប្រវត្តិជាតិខ្លួនដូចម្ដេចទៅ? ហើយប្រវត្តិជាតិកំណើតខ្លួនឯង យើងទៅសិក្សារៀនសូត្រ ពីបរទេសដូច្នេះ បរទេសជាអ្នកសិក្សាស្រាវជ្រាវឲ្យយើងរៀន ធ្វើម្ដេចគេអាចស្គាល់ ពាក្យ សម្គាល់ជាតិថាក្មេរ ក្មែរ ឬខ្មេរ ខ្មែរ? បើពាក្យខ្លែងឯកសរសេរនឹងព្យញ្ជនៈ**ក**វិញ (ក្លែង អែក) គឺយើងនឹងមើលឃើញន័យ តាមការពន្យល់ពាក្យថា គេបំភ័ន្ត បន្លំ ដោយបង្កើតពាក្យថ្មីន័យ ថ្មី ដោយលុបបំបាត់ពាក្យចាស់ន័យចាស់ តើធនជ័យលួចបង្ហោះខ្លែង ក្នុងបន្ទប់គុកសំរឹទ្ធនោះ

គាត់ចង់ឲ្យពូជជ័យជំនាន់ខាងក្រោយ ឈ្វេងយល់ពីអ្វី? គ្រាន់តែក្រដាសមួយសន្លឹកយកមកដាសខ្លែង រួចបង្ហោះចិនពិតជាចុះចាញ់គាត់មែនឬ? ឬមួយមានបង្កប់អាថ៌ប្រស្នាអ្វីផ្សេងទៀត សម្រាប់ទុកឲ្យកូនជ័យជំនាន់ក្រោយស្រាយ? ពាក្យថាខ្លែងព្នង ឬខ្លែងព្នាង បើយើងសម្រាយពាក្យតម្រួតនេះជាសម្រាយ គឺមានពាក្យ **ព + នាង** តើពនាងយកទៅណា? គឺពនាងចេញពីអបាយភូមិ យកទៅដាក់ក្នុងសុគតិភព តើពនាងណា? ពនាងនាគ នាងសក់ក្រអូប នាងហ៊ីងធរណី នាងទិព្វសេតាច័ន្ទ...... យកគាត់ទៅដាក់លើអាកាស ដើម្បីបង្ហាញពីអច្ឆរិយភាពរបស់ពូជនាគ ពូជព្រហ្ម ពូជផ្កាយ ពូជទេវតា ...... ដែលប្រវត្តិរឿងរបស់គាត់ ត្រូវយក្សលេបឲ្យក្លាយជាប្រេតបិសាច រាប់ពាន់ឆ្នាំហើយ សូមមើលប្រវត្តិរឿងរបស់អ្នកការទូតចិនដែលនិយាយពីរឿងបិសាចពស់ ឬនាគ ដែលជាព្រះភូមិថៃវក្សានគរនេះ។ ធនជ័យបង្ហោះខ្លែងឯក គឺបង្ហោះប្រវត្តិសាវតាម្ចាស់មរតកឯកនេះ ដែលត្រូវគេបិទលាក់ រួចក្លែងបន្លំ ដោយឲ្យព្រះនាងនាគបាត់សាវតាពិតរបស់ខ្លួន នាងនាគត្រូវក្លាយទៅជាអន្ទង់ កប់នៅក្នុងភក់ថ្មលុះត្រាតែទាញយករូបចម្លាក់នាគទាំងអស់ចេញពីភក់ថ្មក្នុងប្រាសាទរាប់ពាន់ ដែលមាននៅលើទឹកដីអច្ឆរិយនេះ ទើបភក់ថ្មទាំងនោះជ្រះចេញពីខ្លួនសត្វអន្ទង់ ក្លាយជានាគដូចដើមវិញ។ ពូជខ្មែរគឺជាពូជនាគពិតប្រាកដ ព្រោះបានប្រសូត្រចេញពីទ្វារមាស របស់ព្រះមាតានាគដែលលោកជាម្ចាស់មាតុភូមិនេះ។ ដូច្នេះអ្នកដែលចាញ់ធនជ័យ ក្នុងពេលដែលគាត់បង្ហោះខ្លែងឯកនោះ ដោយពួកគេលែងបិទសន្ធប់ពូជនាគបានទៀតហើយ ព្រោះព្រះមាតានាគឬបិសាចនាគលោកបានរួចពីទុក្ខទោស កំពុងសោយសម្បត្តិជាទិព្វក្នុងសុគតិភព។

ស្តេចចិនពុំចេះកាន់ចង្កឹះ នំប៉ែនចុក(នំបញ្ចុក) គុកសំរឹទ្ធ ខ្លែងឯក ដែលមាននៅក្នុងរឿងធនជ័យ ប្រស្នាទាំងនេះនិពន្ធនិទានបានបង្កើតឲ្យមានឡើងនៅក្នុងស្រុកចិន គឺមិនមែននៅស្រុកឥណ្ឌា ឥណ្ឌូនេស៊ី(ជ្វា) សៀម យួន ភូមា លង្កា ..... ព្រោះនិពន្ធនិទានចង់ឲ្យពូជជ័យជំនាន់ក្រោយពិចារណា រកអ្នកលាក់ប្រវត្តិសាវតាព្រះនាងនាគ ឬព្រះមេជាព្រះមាតានាគ។

«មើលមុខស្តេចខ្មែរដូចខែពេញបូណ៌មី» តើន័យប្រស្នានេះ កើតមានឡើងក្នុងពេលណា? ក្រោយពេលចូលទីវង្គត់របស់ព្រះបាទសម្តេចនរោត្តមសីហនុ ពេលដែលប្រជាជនខ្មែរចូលរួមធ្វើបុណ្យឧទ្ទិស ក្នុងពិធីបុណ្យពថ្ងៃនោះ យើងទាំងអស់គ្នាភាគច្រើនជាកូនខ្មែរ នាំគ្នាភ្ញាក់ផ្អើលមើលឃើញរង់ភ័ក្ត្រព្រះអង្គនៅក្នុងវង់ព្រះច័ន្ទ។ ចំណុចត្រង់នេះសរបញ្ជាក់ឲ្យបាន

ឃើញថា ការព្យាករណ៍របស់ធនជ័យ ពេលបញ្ចុកនំស្ដេចចិន គាត់បានពោលតិះដៀលស្ដេចនោះថា «មើលមុខស្ដេចចិនដូចមុខឆ្កែ មើលមុខស្ដេចក្មែរដូចខែពេញបូណ៌មី» ហើយពាក្យតិះដៀលព្យាករណ៍នេះ យើងអាចមើលឃើញវង់ភ័ក្ត្ររបស់ព្រះបាទសម្ដេចសីហនុ រាល់ថ្ងៃ ៦ ៧ ៨ ៩កើតរាល់ខែ ក្នុងពេលមេឃស្រឡះ។ រូបនិមិត្តសម្ដេចនេះ មានយូរលុងណាស់មកហើយក្នុងវង់ព្រះច័ន្ទ គ្រាន់តែពុំទាន់ដល់ពេលវេលា យើងពុំបានចាប់អារម្មណ៍តែប៉ុណ្ណោះ អ្វីដែលនិពន្ធនិទានបានពោលទុកក្នុងរឿង ហាក់បីដូចជាទំនាយរស់ គ្រាន់តែយើងពុំបានយកកាកគំនិតដូនតា មកពិចារណាឆ្លុះមើល ទើបយើងឈប់យល់ច្រឡំ រឿងនិទានធនជ័យពុំមែនជារឿងសាមញ្ញធម្មតា គឺវាជាការព្យាករណ៍របស់អ្នកប្រាជ្ញក្មែរជំនាន់មុន។ ឆ្នាំរោងតាមចំណាំតែងមានទឹកជំនន់ធំ តែឆ្នាំរោងដែលកន្លងទៅ ពុំមានទឹកជំនន់ធម្មជាតិធំឡើយ តែមានទឹកជំនន់មួយដែលកើតឡើង ហើយប្រជាជនក្មែរទូទាំងប្រទេសពុំបានដឹង ដោយទឹកជំនន់នោះ លិចទាំងទីក្រុង ជនបទ ទីទាប ទីខ្ពស់ លិចទាំងបុរស ស្ត្រី គ្រហស្ថ បព្វជិត ក្មេង ចាស់ ប្រុស ស្រី តើជាទឹកជំនន់អ្វី ដែលធំយ៉ាងនេះ? គឺជាជំនន់ទឹកភ្នែក ដែលហូរចេញពីទឹកចិត្តប្រជារាស្ត្រក្មែរ ដែលបានបាត់បង់នូវអតីតព្រះមហាក្សត្រខ្លួន ធ្វើឲ្យជំនន់ទឹកចិត្តនេះហូរលិច៤ដង ជំនន់ទី១ ថ្ងៃដែលព្រះអង្គយាងចូលទីវង្គត់ ជំនន់ទី២ ថ្ងៃដឹកព្រះសពមកដល់ប្រលានយន្តហោះ ជំនន់ទី៣ ថ្ងៃដង្ហែព្រះសពព្រះអង្គទៅតំកល់នៅវាលមេរុ(មេន) ជំនន់ទី៤ ថ្ងៃបូជាព្រះសពព្រះអង្គ ជំនន់ទឹកចិត្តធំទាំង៤ដងនេះ គឺជាទឹកជំនន់ប្រចាំឆ្នាំរោង ដែលកន្លងទៅ។

ក្រោយពេលដែលស្ដេចចិន ដឹងថាអ្នកដែលយកទៅដាក់គុកនោះ ជាអ្នកប្រាជ្ញក្មែរឈ្មោះធនជ័យ ក៏ឲ្យរាជអាមាត្យដោះលែង រួចសុំអភ័យទោសពីធនជ័យ ហើយបញ្ជូនគាត់មកកាន់មាតុភូមិវិញ ដោយបានឲ្យទ្រព្យសម្បត្តិរបស់របរ ខ្ញុំកំដរប្រុសស្រី ជាជំនូនលើកទឹកចិត្ត ធនជ័យក៏ចុះសំពៅត្រឡប់មកស្រុកកំណើតវិញ។ ពេលសំពៅមកដល់ស្រុកក្មែរ ស្ដេចនាម៉ឺនមន្ត្រី ដែលពីមុនមានបំណាងចង់ខ្ចីដៃចិន ឲ្យជួយសម្លាប់អ្នកប្រាជ្ញរូបនេះ បែរជានាំគ្នាខ្លាចប្រាជ្ញាបារមីរបស់ធនជ័យគ្រប់គ្នា លែងហ៊ានទៅបៀតបៀនគាត់ទៀត។ ចំណែកឯស្ដេចវិញ ចេះតែមានការភ័យព្រួយបារម្ភក្នុងចិត្ត ខ្លាចក្រែងធនជ័យដណ្ដើមរាជ្យ ព្រោះធនជ័យមានប្រាជ្ញា អាចធ្វើឲ្យស្ដេចចិនចុះចាញ់បាន ក៏ប៉ុន្តែនិពន្ធនិទានពុំធ្វើដូច្នេះឡើយ ព្រោះ

ហេតុអ្វី? យើងក្រឡេកមើលមករឿងរបស់ព្រះមហោសថ ពេលដែលព្រះមហោសថ បាន បកស្រាយពីគំនិតអាក្រក់របស់ស្ដេចចុល្លនី និងអាចារ្យកេវដ្តព្រាហ្មណ៍ ដែលចង់បំផុតពូជ ស្ដេចក្នុងសកលជម្ពូទ្វីប បានរៀបចំពិធីជប់លៀងមួយឡើង ហើយបានដាក់ថ្នាំបំពុលក្នុងកែវ ស្រារបស់ស្ដេចទាំងនោះ(១១០នគរ) ដើម្បីបំពុលស្ដេចទាំងនោះឲ្យស្លាប់ផុតពូជ។ ព្រះ មហោសថបានដឹងពីឧបាយកលរបស់អាចារ្យកេវដ្តព្រាហ្មណ៍ និងស្ដេចចុល្លនី ក៏បានធ្វើកិច្ច ឲ្យបក្សពួករបស់ព្រះអង្គ បន្លំខ្លួនចូលទៅក្នុងពិធីនោះ បង្កើតជាចលាចលឆាឆៅ ធ្វើឲ្យថ្នាំ បំពុលទាំងនោះកំពុបអស់ មិនអាចសម្រេចបំណងរបស់អាចារ្យនិងស្ដេចនោះបាន។ ពេល ដែលស្ដេចចុល្លនីបានដឹងពីប្រាជ្ញាបារមីរបស់ព្រះមហោសថ ព្រះអង្គក៏មានព្រះរាជឱង្ការថា បើលោកមានប្រាជ្ញាអានុភាពដល់ម្លឹងហើយ ម្ដេចក៏លោកមិនដណ្ដើមរាជ្យក្នុងសកលជម្ពូទ្វីប សោយរាជ្យខ្លួនឯងទៅ? ព្រះមហោសថបានឆ្លើយតបទៅវិញថា «គេធ្លាប់ហៅខ្ញុំថាជាបណ្ឌិត ជាអ្នកប្រាជ្ញ ខ្ញុំចង់ទុកឈ្មោះនេះ ទើបខ្ញុំមិនដណ្ដើមគេ ការដណ្ដើមគេបណ្ឌិតទាំងឡាយពុំ ដែលសរសើរឡើយ ព្រោះវាពុំមែនជាករណីកិច្ចរបស់អ្នកប្រាជ្ញ ខ្ញុំធ្វើការដើម្បីប្រយោជន៍ផ្ដល់ នូវសេចក្ដីសុខដល់សព្វសត្វ ទើបគួរទទួលឈ្មោះថាជាអ្នកប្រាជ្ញ»។ យ៉ាងណាមិញនិពន្ធ និទានរឿងធនជ័យ ក៏យល់ស្របយ៉ាងដូច្នោះដែរ ទោះបីគាត់មានប្រាជ្ញាអាចឈ្នះសេដ្ឋី នាម៉ឺនមន្ត្រី ស្ដេចក្មេរ អ្នកប្រាជ្ញចិន ស្ដេចចិន ក៏និពន្ធនិទានពុំបាននិទាន ឲ្យធនជ័យមាន មហិច្ឆតាដណ្ដើមរាជ្យបល្ល័ង្កឡើយ ដោយលោកបានប្រាវព្ធយកភាសិតក្នុងរឿងព្រះ មហោសថ ដែលបានពោលឆ្លើយតបស្ដេចចុល្លនី នេះជាភស្ដុតាង។ ព្រោះភាគច្រើនក្នុង សាច់រឿងធនជ័យ បានដកគំនិតចេញមកពីរឿងព្រះមហោសថ ក្នុងចំណុចជាច្រើន ដែលខ្ញុំ បាទបានពន្យល់ពីខាងដើមហើយ ដូច្នេះយើងគ្មានអ្វីដែលធ្វើឲ្យឆ្ងល់ឬសង្ស័យ ចំពោះគំនិត និពន្ធនិទានជូនតាឡើយ។

## VIII.<u>**បណ្ដាំអ្នកប្រាជ្ញជ័យមុនពេលស្លាប់**</u>

ពេលដែលដឹងថា មរណៈភ័យជិតចូលមកដល់ ធនជ័យបានហៅភរិយាមកផ្ដាំ បើខ្ញុំ ស្លាប់ទៅ ចូរអ្នកយកសាកសពខ្ញុំទៅបញ្ចុះ ហើយនៅជុំវិញផ្នូរ អ្នកត្រូវដោតរាយបង្កប់ចម្រូង ជុំវិញផ្នូរ ហើយដាំដើមវល្លិខ្ញែរបន្ថែមទៀត ហេតុអ្វីគាត់ត្រូវផ្ដាំផ្ញើរភរិយាឲ្យធ្វើយ៉ាងនេះ? ព្រោះគាត់ដឹងថា កូនក្មេរភាគច្រើន ពុំបានយល់ដឹងពីគុណធម៌របស់គាត់ ហេតុដូចនេះគាត់

ត្រូវតែធ្វើដូច្នេះ ដើម្បីការពារនូវសេចក្ដីប្រមាថមាក់ងាយ។ ព្រោះខ្លាចកូនក្មេរទាំងនោះ គ្នាមានបាបដោយពុំដឹងខ្លួន ដោយការប្រមាថអ្នកមានគុណធម៌ដូចគាត់ ព្រោះមួយជីវិតរបស់គាត់ បានធ្វើពលិកម្មដើម្បីសង្គ្រោះនិងថែរក្សាទឹកដីនេះ ពីសម្នាក់ប្រទេសឈ្លានពាន។ ចុងក្រោយគាត់បានប្រើកិរិយាទៅយាងព្រះករុណា ខ្ញុំចង់ផ្ដាំផ្ញើរពាក្យជាសុភាសិតទុកឲ្យស្ដេច ជាគំនិតសម្រាប់គ្រប់គ្រងថែរក្សាព្រះនគរ មុនពេលខ្ញុំស្លាប់។ ពេលស្ដេចយាងមកដល់ ក៏បានចូលទៅជួបធនជ័យដើម្បីសួរសុខទុក្ខ ធនជ័យបានប្រើព្រះអង្គឲ្យឱនមកជិត រួចក៏និយាយផ្ដាំថា «បើព្រះអង្គសោយត្រីព្រួលកុំចោលស្រកា សោយត្រីប្រាកុំចោលស្រកី បើស្មោរត្រីកុំចោលម្ទូរសណ្ដាន់។ ក្រោយមកពុំយូរ ពេលដែលគាត់បានធ្វើកិច្ចការចប់សព្វគ្រប់ហើយ ធនជ័យក៏បានធ្វើមរណៈកាលទៅយ៉ាងស្ងប់ស្ងាត់ ដោយពុំអាចយកអ្វីពីក្នុងលោកនេះទៅបានឡើយ។ ចំណែកឯស្ដេចវិញ ក្រោយពេលបានស្ដាប់ពាក្យបណ្ដាំធនជ័យហើយ ពួកនាម៉ឺនមន្ត្រីដែលចង់ដឹង បានពោលសួរព្រះអង្គ តើធនជ័យបានផ្ដាំផ្ញើរពាក្យពេចន៍អ្វីដល់ព្រះអង្គខ្លះ? ព្រះករុណាបានតបទៅនាម៉ឺនមន្ត្រីទាំងនោះថា វាផ្ដាំអញពីរឿងស៊ីត្រីហ្នឹង ជិតស្លាប់ទៅហើយវានៅនិយាយលេងនឹងអញទៀត តើធនជ័យដែលជាអ្នកប្រាជ្ញប្រចាំនគរទាំងមូលរៀបនឹងស្លាប់ទៅហើយ នៅមានពេលនិយាយលេងសើចទៀតឬ? ហេតុអ្វីនិពន្ធនិទានមិនបាន និទានឲ្យស្ដេចឆ្ងល់ ថាអ្នកប្រាជ្ញក្មេរមួយទាំងមូល រៀបនឹងស្លាប់បែរជាផ្ដាំពីរឿងស៊ីត្រី? តើស៊ីត្រីមានបង្កប់អត្ថន័យអ្វី ក្នុងបណ្ដាំប្រស្នាធនជ័យ?

ក.សោយត្រីព្រួលកុំចោលស្រកា តើមានន័យអាថ៌កំបាំងដូចម្ដេច? ពាក្យនិយាយព្រួលមានសូរពីរយ៉ាង គឺព្រួល ឬប្រួល ពន្យល់ពាក្យ

ព្រួល ( ន. ) កម្រងបន្ទោះធំៗ ឬរនាបតូចៗ សម្រាប់ទប់ខាំងមច្ឆជាតិឬសម្រាប់អបស្អូបដៃជើងបាក់ជាដើម ។ ឈ្មោះស្វាយមួយប្រភេទ ហៅថា ស្វាយមីងព្រួល ។ ឈ្មោះត្រីស្រកាមួយប្រភេទ មានសម្បុរស : ត្រីព្រួល, ព្រួលកន្លង់, ព្រួលខ្មៅមុខ ឬ ព្រួលកោង ។ (ដកចេញពីវចនានុក្រមសម្ដេច)

ព្រួល ( កិ. វិ. ឬ គុ. ) ទ្រួសៗ, លំៗ ដុំៗ; ស្មើរៗ, ព្រាងៗ : ចាំព្រួលៗ; ឆ្អិនព្រួលៗ ។ក្រហមព្រួល ឬ ក្រហមព្រួលៗ ក្រហមស្មើរ ។ ព្រួលៗ (ដកចេញពីវចនានុក្រមសម្ដេច)

ប្រួល ( ប. ) ពាក្យសម្រាប់និយាយផ្សំនឹងពាក្យ ប្រែ ថា : ប្រែប្រួល គឺប្រែត្រឡប់, ប្រែចុះប្រែឡើង; ប្រែឃ្លាតចាកប្រក្រតីដើម ។ (ដកចេញពីវចនានុក្រមសម្ដេច)

ចម្លើយរបស់អ្នកប្រាជ្ញធនជ័យ ក្នុងការសោយត្រីព្រួល គឺអាចបកបានន័យបីយ៉ាង ដូចជាការឆ្លើយរបស់គាត់ ក្នុងពេលដែលអ្នកប្រាជ្ញចិនមកភ្ជាល់យកនគរដូច្នោះ ចម្លើយទីមួយគាត់ឆ្លើយប្រាប់ព្រះចៅអធិការពីរឿងរុតត្រី និងស៊ីត្រី ចម្លើយទីពីរគាត់ឆ្លើយប្រាប់ស្ដេចចៅហ្វាវាំង(ឧបរាជ) ថាចិនគេមកឈ្លានពានដណ្ដើមយកព្រះនគរ ចំណែកចម្លើយទីបី គាត់បានទូលប្រាប់ស្ដេចផែនដី ពីឈ្មោះស្ត្រីដែលជាម៉ែ គឺជាស្ដេចភ្នំព្រះសុមេរុ ហើយត្រូវជាប់ឃុំ លុះត្រាតែមានកូនណាមួយ បំពេញបារមីជាព្រះពោធិសត្វ ទើបអាចជួយស្ត្រីដែលជាស្ដេចភ្នំព្រះសុមេរុនោះរួច។ បើយើងមើលទៅលើការឆ្លើយបកស្រាយ ក្នុងចម្លើយទាំងបីនោះ យើងពុំដឹងថាចម្លើយមួយណាពិតត្រឹមត្រូវនោះឡើយ តែតាមការពិតចម្លើយទាំងបីនោះពិតត្រឹមត្រូវទាំងបី តែគាត់ពោលទៅតាមភាសានិស្ស័យរបស់មនុស្សខ្ពស់ កណ្ដាល ទាប។ យ៉ាងណាមិញ បណ្ដាំចុងក្រោយរបស់គាត់ ដែលគាត់បានផ្ដាំផ្ញើរទុកនឹងស្ដេច ចម្លើយក៏ត្រូវបានចែកចេញជាបី គឺភាសាបណ្ឌិត ភាសាអ្នកប្រាជ្ញ ភាសាមនុស្សធម្មតា តើសត្វត្រីមានអត្ថន័យដូចម្ដេច?

សត្វត្រី(ស្ត្រី) ជាផ្កាយមួយដួង ក្នុងដំណើរសុរិយគតិ គឺខែមីនា មីន សំ. បា. ( ន. ) (មីន) ត្រី; ឈ្មោះខែទី ១២ នៃសុរិយគតិ, មាន ៣១ ថ្ងៃ, ត្រូវគ្នានឹងខែម៉ារ្ស (ខែទី ៣) បារាំងសែស : ខែមីន (ហៅថា មីនរាសី ក៏បាន) ។ សព្វថ្ងៃប្រើជា មីនា ជាខែទី ៣ ដែរ ។ (តាមសំឡេងអក្សរខ្មែរត្រូវអានថា មីនា, ប៉ុន្តែទម្លាប់ទាញឲ្យថា មីន៉ា ក៏ក្លាយទៅជា អញ្ញត្រសព្ទ) ។ មីនៈ (ដកចេញពីវចនានុក្រមសម្ដេច)

នេះជាហេតុបណ្ដាំដែលអ្នកប្រាជ្ញធនជ័យ លោកផ្ដាំដល់អ្នកសោយរាជសម្បត្តិ ជាកេរតំណែលមរតកមនុស្សពូជផ្កាយ(សោយត្រី = មីនា = ផ្កាយរូបសត្វត្រី) ដោយលោកចង់ផ្ដាំស្ដេចអ្នកដឹកនាំប្រទេស ដែលកំពុងសោយរាជសម្បត្តិរបស់ស្ត្រី(មាតុភូមិ)។ ព្រោះលោកចង់ឲ្យស្ដេចដឹកនាំនគរ ស្គាល់សាវតាខ្លួនឯងជាមនុស្សពូជផ្កាយ សោមវង្ស(វង្សខាងម្ដាយគឺព្រះច័ន្ទ គឺទិព្វសេតាច័ន្ទ វិមានច័ន្ទ) និងសុរិយវង្ស(វង្សខាងឪពុកគឺព្រះអាទិត្យ) ដែលវង្សទាំងពីនេះត្រូវបានកាត់ផ្ដាច់ ដោយបរទេសចូលមកឈ្លានពានលុកលុយកាលពីអតីត ហើយពួកគេ

បានលុបដាន សាដានព្រះនាងនាគ ដោយសព្វថ្ងៃនេះ រឿងសាវតារបស់អ្នកនគរនេះ ត្រូវបានក្រុមហ៊ុនភាពយន្តក្នុងពិភពលោក បានយកប្រវត្តិរឿងបិសាចពស់ឬនាគ ទៅតែងនិពន្ធទោះបីជាគេតែងបែបបុរាណឬសម័យ បញ្ចប់សាច់រឿងពួកគេមានបំណងចង់បំផ្លាញបិសាចពស់ឬនាគ ដែលជាអតីតដូនតាខ្មែរ មិនឲ្យកើតមានក្នុងលោកសារជាថ្មី។ តើន័យទាំងបីក្នុងការសោយត្រីព្រួល មានអត្ថន័យដូចម្ដេច?

ន័យទី១ សត្វត្រីព្រួលគឺឆ្មាញ់នៅត្រង់ស្រកា ព្រោះស្រកាត្រីនេះម៉ត់ល្អិត គេពុំដែលច្រាស់ស្រកាត្រីនេះឡើយ គឺគេច្រើនស្ងោរឬចំហុយត្រីព្រួលនេះទាំងស្រកា ព្រោះស្រកាត្រីនេះមានភាពទន់ហើយច្រុប។ ស្រកាត្រីគឺជាគ្រឿងក្រោះ សម្រាប់ការពាររាងកាយត្រីទាំងមូល ហើយស្រកានេះក៏ជាគ្រឿងអលង្ការ ឬសំលៀកបំពាក់របស់សត្វត្រីគ្រប់ប្រភេទ ទោះបីជាសត្វត្រីមិនមានស្រកា ក៏គង់មានរម្អិល សម្រាប់ការពាររាងកាយរបស់ខ្លួនវាដែរ។ ដូច្នេះសត្វត្រីអាចរស់នៅបានសុខនៅក្នុងទឹក គឺពឹងផ្អែកទាំងស្រុងទៅលើស្រកា ព្រោះស្រកាគឺជាសំលៀកបំពាក់របស់សត្វត្រី។

ន័យទី២ និពន្ធនិទានលោកចង់ផ្ដែផ្ដាំ ចំពោះអ្នកដែលបានសោយសម្បត្តិមរតកស្ត្រីដែលជាកេរតំណែលរបស់មាតុភូមិនេះ បើមិនចង់ឲ្យការសោយមរតកនេះ មានការប្រែប្រួលអ្នកដឹកនាំទាំងនោះ ត្រូវគិតប្រយោជន៍ប្រជារាស្ត្រជាធំ តើព្រោះហេតុអ្វី? ប្រជារាស្ត្រប្រៀបបីដូចជាស្រកាត្រី ដែលជួយបិទបាំងរារាំង ការពារគ្រប់ឧបសគ្គដែលកើតពីខាងក្រៅ ទើបធ្វើឲ្យអ្នកសោយរាជ្យ ឬគ្រប់គ្រងផែនដី ដែលជាមរតករបស់សត្វត្រី(ស្ត្រី) ឋិតថេរមិនប្រែប្រួល។ ប្រជារាស្ត្រជាគ្រឹះ ជាឬសគល់នៃជាតិ គួខំខ្មីឃ្មាតគ្រងថែរក្សា ប្រៀបដូចសត្វត្រីតែងពឹងស្រកា បក្សីបក្សាពឹងរោមពឹងស្លាប។

ន័យទី៣ និពន្ធនិទានលោកចង់ផ្ដាំអ្នកដឹកនាំគ្រប់ជំនាន់ ដែលកំពុងសោយសុខក្នុងមរតកសម្បត្តិរបស់ពូជផ្កាយស្ត្រី(មីនា)នេះ បើបានសោយផលបុណ្យចាស់ហើយ ត្រូវខំស្វះស្វែងសន្សំបុណ្យថ្មី ព្រោះឆាកជីវិតរបស់សត្វលោកមិនទៀងឡើយ ដូចជាជីវិតរបស់ធនជ័យទោះបីជាមានបញ្ញាអាចផ្ចាញ់បរទេសបាន ក៏គង់តែមិនអាចផ្ចាញ់មរណៈបានឡើយ។ ស្រកាត្រីប្រៀបបីដូចជាសីល ព្រោះសីលគឺជាគ្រឿងអលង្ការរបស់បណ្ឌិតអ្នកប្រាជ្ញ យើងអាចមានកំណើតក្នុងជាតិនេះជាមនុស្សបាន ក៏អាស្រ័យការរក្សានូវសីលពីជាតិមុន។ ដូចនេះបើ

មិនចង់ឲ្យកំណើតនេះប្រែប្រួល គ្រប់អ្នកដឹកនាំកំពុងសោយត្រី ឬកំពុងសោយសម្បត្តិរបស់ស្ត្រី គឺមាតុភូមិនេះ គួរតាំងចេតនាផ្ទាក់សីលឲ្យកើតឡើង ដើម្បីធ្វើជាសំលៀកបំពាក់ ឬគ្រឿងអលង្ការ សម្រាប់កំណើតជាតិមុខ កុំឲ្យប្រែប្រួល(ព្រួល) ធ្លាក់ទៅរងទុក្ខក្នុងអបាយភូមិ។ ការសោយត្រីព្រួលកុំចោលស្រកា និពន្ធនិទានលោកឲ្យអ្នកដែលកំពុងតែសោយសត្វត្រីព្រួល ត្រូវចេះមើលកាលទាំងបី អតីត បច្ចុប្បន្ន និងអនាគត បើធ្វេសប្រហែស អ្វីដែលមាននៅក្នុងកាលទាំងបី ដែលកំពុងសោយ នឹងត្រូវប្រែប្រួលជាពុំខាន។ ធនជ័យលោកផ្ដាំស្ដេច បើព្រះអង្គសោយសុខក្នុងសម្បត្តិ របស់មនុស្សផ្កាយហើយ គួរកុំភ្លេចរៀបចំសម្អាតចិត្ត ឲ្យមានបេះដូងជាទេវតាឬផ្កាយ(គុណធម៌) ដែលអាចធ្វើឲ្យចិត្តនេះទៅបដិសន្ធិក្នុងឋានផ្កាយបាន លុះត្រាតែកុំចោលស្រកាគឺសីល។ យើងតែងឮសមណសក្យបុត្រ ឬលោកអាចារ្យឲ្យពរថា សូមឲ្យជួបតែសម្បត្តិទាំងឡាយបី គឺសម្បត្តិមនុស្សមួយ សម្បត្តិទេវតាមួយ សម្បត្តិព្រះនិព្វានមួយ តើអ្វីជាសម្បត្តិមនុស្ស សម្បត្តិទេវតា សម្បត្តិព្រះនិព្វាន?

- សម្បត្តិមនុស្ស គឺការឲ្យទាននិងរក្សាសីល សីលគឺជាក្បាល ជាគុណធម៌របស់មនុស្ស ជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ ហើយសីលនេះចែកចេញជាពីរ គឺលោកិយសីល និងលោកុត្តរសីល។ លោកិយសីល គឺជាសីលដែលនៅមានសភាពញាប់ញ័រ គឺជាសីលដែលនៅប្រកបដោយទិដ្ឋិ ថាមានសត្វបុគ្គលជាអ្នកថែរក្សាសីល ប្រកាន់ថាអាត្មាអញជាអ្នករក្សាសីល ន័យពិតសត្វបុគ្គលជាអ្នករក្សាសីលគឺពុំមានឡើយ គ្រាន់តែជាចេតសិក(ចេតនា) មួយបែបវៀរចាកនៅពៀរតែប៉ុណ្ណោះ។ លោកុត្តរសីល ជាសីលដែលលែងមានការញាប់ញ័រ គឺជាសីលរបស់ព្រះអរិយបុគ្គល ចាប់ពីថ្នាក់សោតាឡើងទៅ គឺជាសីលលែងមានការប្រកាន់។

- សម្បត្តិទេវតា គឺជាសម្បត្តិដែលកើតឡើង ពីបុណ្យថ្នាក់ទាន សីល សមាធិ ទោះបីជាស្ថិតនៅក្នុងឧបចារសមាធិ ឬអប្បនាសមាធិ ក៏សុទ្ធតែឲ្យបុគ្គលនោះ ទៅបដិសន្ធិក្នុងទេវលោក ទៅតាមថ្នាក់នៃកម្លាំងបុណ្យរបស់សមាធិ ហើយសមាធិនេះក៏ចែកជាពីរដូចសីលដែរ គឺលោកិយសមាធិ និងលោកុត្តរសមាធិ។

- សម្បត្តិព្រះនិព្វាន គឺជាសម្បត្តិថ្នាក់បញ្ញាជាលោកិយ នឹងឆ្លងគោត្រភូតញ្ញាណ ទៅរកលោកុត្តរ កាប់ឆ្ការនូវកិលេស តាំងពីថ្នាក់សោតា រហូតដល់ថ្នាក់អរហត្តផលជាទីបញ្ចប់នូវកិច្ចក្នុងការសិក្សា។

ខ.សោយត្រីប្រាកុំចោលស្រកី តើមានអត្ថន័យកំបាំងយ៉ាងណាខ្លះ

ន័យទី១ ធម្មតាត្រីប្រាវាឆ្លាញ់បែបម្យ៉ាងនៅត្រង់ស្រកីរបស់វា ព្រោះស្រកីត្រីប្រាពេលយកទៅស្ងោរស្ល វាមានភាពច្រុបៗ មិនធ្វើឲ្យទ្រលាន់ដូចសាច់ ហេតុដូច្នេះអ្នកបរិភោគត្រីប្រាចូលចិត្តទិញក្បាលត្រីប្រា យកទៅស្ងោរម្ជូរត្រកួនឬព្រលិត...។ ទើបបានមានពាក្យទំនៀមតាមធនជ័យថា បើសោយត្រីប្រា ឬស្ងោរក្បាលត្រីប្រា កុំចោលស្រកី ព្រោះស្រកីត្រីប្រាធំច្រុបៗមិនទ្រលាន់។

ន័យទី២ ស្រកីជាសួត ជាកន្លែងផ្ទុកខ្យល់ដង្ហើមរបស់ត្រី យ៉ាងណាមិញ តួត្រីទាំងមូលអាចរស់នៅបាន គឺដោយសារការដកដង្ហើម ព្រោះខ្យល់គឺជាចំណីមួយយ៉ាងសំខាន់ សម្រាប់មនុស្សសត្វក្នុងលោក ព្រោះហេតុអ្វី? យើងអាចអត់អាហារបានយូរថ្ងៃ ពេលមានជំងឺ ឬកើតទុរ្ភិក្ស ចំណែកឯទឹកវិញ អត់បានរយៈពេលតិចជាងអាហារ ដែលរឹតតែសំខាន់ជាងគេទៅទៀតគឺខ្យល់ ព្រោះខ្យល់វាបង្ខំញត្រឹមរយៈពេល ម៉ោង ឬនាទីប៉ុណ្ណោះ បើអត់វាគឺស្លាប់ពុំខាន។ ខ្យល់ជាអាហារដ៏សំខាន់របស់មនុស្សសត្វ គេពុំដែលធ្វើជំនួញខ្យល់ធម្មជាតិ អ្នកមានសួតធំដកខ្យល់បានច្រើន អ្នកមានសួតតូចដកខ្យល់បានតិច (អ្នកលេងកីឡា និងអ្នកមិនលេង) ស្ដេច នាម៉ឺន មន្ត្រី សេដ្ឋី រាស្ត្រ បុរស ស្ត្រី គ្រហស្ថ បព្វជិត មានសិទ្ធដកយកខ្យល់ស្មើគ្នា គ្មានរើសអើងវណ្ណៈទ្រព្យសម្បត្តិឡើយ គឺដកទៅតាមទំហំនៃសួត។ ខ្យល់ជាអាហារងាយរកបាន ងាយទទួល ងាយធ្វើឲ្យប៉ះពាល់ដល់សុខភាព នៅពេលដែលខ្យល់មិនបរិសុទ្ធ សព្វថ្ងៃមនុស្សលោកដែលពុំបានយល់ដឹងអំពីអាហារខ្យល់ នាំគ្នាធ្វើខ្យល់លែងឲ្យមានភាពបរិសុទ្ធ ដោយបំពុលបរិស្ថានជុំវិញខ្លួន ធ្វើឲ្យខ្យល់ពោរពេញទៅដោយជាតិពុល។ សព្វថ្ងៃប្រជារាស្ត្រមានធនធានទ្រព្យសម្បត្តិច្រើន ធ្វើគេហដ្ឋានជាបន្ទប់៤ជ្រុងរួចបិទជិត ដោយប្រើប្រាស់ឧបករណ៍ម៉ាស៊ីនត្រជាក់ជំនួសដើម្បីបំភ័ន្ត តែបន្ទប់នោះពោរពេញទៅដោយខ្យល់ចាស់ពុំបរិសុទ្ធ ដែលដកចេញចូល ធ្វើឲ្យវិលវល់ក្នុងបន្ទប់នោះ គ្មានខ្យល់ថ្មីផ្លាស់ប្ដូរ ធ្វើឲ្យងាយមានជំងឺផ្លូវដង្ហើម។ ខុសពីជំនាន់មុន ដូនតាយើងគាត់សង់គេហដ្ឋានដំបូលជារាងសាជី ហើយបន្ទប់មានបង្អួចជុំវិញ ដោយគាត់បានសិក្សារពីបន្ទុកខ្យល់អុកស៊ីសែនដែលត្រូវផ្លាស់ប្ដូរ ហើយទំហំសាជីខាងលើដំបូល ដែលពុំបានបិទពិដាន ក្នុងពេលយប់សមាជិកគ្រួសារទាំងនោះ ពេលសំរាកត្រូវស្រូបយកនៅបន្ទុកខ្យល់ដែលមាននៅក្នុងទំហំសាជីទាំងនោះ បូកផ្សំ

នឹងបង្កួចព្រិល ដែលធ្វើឲ្យខ្យល់ចាស់ងាយផ្លាស់ប្ដូរមកខ្យល់ថ្មី ដែលជាខ្យល់បរិសុទ្ធ។ ម្យ៉ាងទៀតសម័យពីដើម បរិស្ថានខ្យល់នៅបរិសុទ្ធ ពុំសំបូរទៅដោយជាតិពុលដូចសព្វថ្ងៃ ទើបមនុស្សជំនាន់ដើមមានសុខភាពល្អដោយអាហារខ្យល់មានភាពបរិសុទ្ធនឹងគ្រប់គ្រាន់។ ពាក្យថាស្រកី ក្លាយមកពាក្យត្រឡប់ថា ស្រីក មានន័យថា គ្រួសារមួយ ប្រទេសមួយ បានសុខឬទុក្ខគឺអាស្រ័យស្ត្រីជាម្ដាយ ជាភរិយារបស់គ្រួសារ ឬអ្នកដឹកនាំនោះ ព្រោះទឹកដីនេះជាទឹកដី ស្រីអ្នកកកើតឡើង គឺព្រះមាតានាគ ឬព្រះនាងនាគ។ ពាក្យប្រា គឺធនជ័យគាត់ចង់ផ្ដាំអ្នកដឹកនាំទាំងឡាយ ឲ្យចេះប្រាស្រ័យទាក់ទង ពីទាបទៅខ្ពស់ ពីតូចទៅធំ ពីក្នុងប្រទេសទៅក្រៅប្រទេស ដើម្បីបានដឹងពីសុខទុក្ខ ការរីកចំរើន ឬមិនរីកចំរើន និងយល់ពីបំណងចង់បានរបស់រាស្ត្រ។ ដូច្នេះការសោយត្រីប្រា គឺការសោយរាជ្យគ្រប់គ្រងក្នុងនគរស្ត្រី ដែលជាពូជផ្កាយ ត្រូវមានការគ្រប់គ្រងថែរក្សា នឹងប្រាស្រ័យទាក់ទងប្រកបទៅដោយគុណធម៌ ហើយគុណធម៌ដឹកនាំនេះគឺស្ថិតនៅលើក្បាល។ នគរមួយអាចរីកចំរើនទៅបាន គឺអាស្រ័យសេដ្ឋកិច្ចជាតិដែលជាក្បាល ជាដង្ហើមរស់របស់ជាតិ ពេលណាសេដ្ឋកិច្ចរុងរឿង ឯករាជ្យនឹងមានពិត ព្រោះសេដ្ឋកិច្ចរីកចំរើន វាជាភាពឈ្នះរបស់សង្គមជាតិ ឬគ្រួសារ សេដ្ឋកិច្ចអាចរុងរឿងបាន វាអាស្រ័យការប្រាស្រ័យទាក់ទងគ្នាក្នុងលោក។

ន័យទី៣ បើសោយត្រីប្រាកុំចោលស្រកី ព្រោះនិពន្ធនិទានលោកចង់ឲ្យយើងសិក្សាពីខ្យល់ ព្រោះមានពាក្យទំនៀមដូនតាពីមុន ធ្លាប់ដាស់តឿន ឬដេរកូនចៅថា អាមិនដឹងខ្យល់ តើពាក្យមិនដឹងខ្យល់នេះមានបង្កប់ន័យអ្វីខ្លះ?

- មិនដឹងខ្យល់ទី១ គឺមិនដឹងខ្យល់ធម្មជាតិ ដែលត្រូវបក់មកពីទិសណាមួយ ពេលដែលមិនដឹងទិសខ្យល់បក់មក យើងដើរបញ្ច្រាស់ទិសខ្យល់ ធ្វើឲ្យខ្យល់បក់បំប៉ើងឬក៏ធូលីសំរាមហុយចូលក្នុងភ្នែក។
- មិនដឹងខ្យល់ទី២ គឺមិនដឹងខ្យល់សង្គមនយោបាយ ថាតើរបបនយោបាយ មានទំនោរទៅខាងណាខ្លាំង បើយើងដើរបញ្ច្រាស់នៅខ្យល់ទំនោរនយោបាយនោះ ធ្វើឲ្យសេចក្ដីសុខមានតិច តែទុក្ខមានច្រើន។
- មិនដឹងខ្យល់ទី៣ គឺមិនដឹងខ្យល់ដែលបក់នៅក្នុងរាងកាយ ដែលមានខ្យល់ដកដង្ហើមចូលវែងចេញវែង ដកដង្ហើមចូលខ្លីចេញខ្លី ខ្យល់ទាំងពួងបក់ក្នុងរាងកាយ

និងខ្យល់ល្អិតឬស្ងប់ ដែលជាខ្យល់ចុងក្រោយ ធ្វើចិត្តឲ្យស្ងប់ ចូលកាន់អង្គឈាន ជាពិសេសទៅទៀតនោះ គឺសិក្សាពីការអស់ខ្យល់ ឬដាច់ខ្យល់មុនពេលស្លាប់។

ដូច្នេះធនជ័យបានផ្ដាំឲ្យស្ដេច នាម៉ឺន មន្ត្រី រាស្ត្រ សោយត្រីប្រាកុំចោលស្រកី ព្រោះលោកចង់ពន្យល់ប្រាប់ពូជជ័យខាងក្រោយ ឲ្យបានយល់ថា បើបានសោយសុខក្នុងមរតកសម្បត្តិស្ត្រី(សត្វត្រី = ផ្កាយ)ហើយ កុំឲ្យភ្លេចខ្លួន ត្រូវចេះធ្វើទីពឹងឲ្យខ្លួនឯង គឺការអប់រំចិត្ត។ ហើយការអប់រំចិត្តនេះ លោកឲ្យយកកម្មដ្ឋានដែលងាយរក ដែលមានជាប់ក្នុងកាយនេះ គឺដង្ហើមដកខ្យល់ចេញចូល ដែលកើតចេញពីស្រកីឬសួត សម្រាប់អប់រំចិត្តឲ្យមានចិត្តស្ងប់ គឺសមាធិចិត្ត នេះជាហេតុក្នុងការចុតិចិត្តចុងក្រោយរបស់ចិត្ត ដែលត្រូវទៅបដិសន្ធិក្នុងពិភពផ្កាយវិញ ព្រោះក្មេរយើងជាពូជផ្កាយ(ពូជទេវតា) ហើយទីបំផុតនៃជាតិ និងបានសម្រេចធម៌ជាន់ខ្ពស់ លះទុក្ខទាំងពួងរួចបរិនិព្វាន។

គ.បើព្រះអង្គបានសោ្ករក្បាលត្រី កុំចោលម្ហូរសណ្ដាន់ តើឃ្លានេះ មានអត្ថន័យដូចម្ដេច?

ន័យទី១ ការធ្វើម្ហូបដោយប្រើត្រីឬសាច់ យើងត្រូវប្រើម្ហូរជាជំនួយ ក្នុងការកាត់ចម្អាបហើយម្ហូរនោះទៀត នៅក្នុងប្រទេសយើងមានច្រើន ដូចជាម្ហូរក្រសាំង អំពិល ក្រូច អង្កាំពពួកស្លឹកមានស្លឹកថ្នឹង ទម្ងង ក្រឡាញ់ ម្កាក់....។ល។ ហេតុអ្វីក៏បណ្ដាំធនជ័យ ឲ្យប្រើតែម្ហូរសណ្ដាន់ទៅវិញ? តើគាត់ចង់ឲ្យយើងមើលឃើញពាក្យអ្វី ដែលស្រដៀងនឹងសណ្ដាន់? ពាក្យនិយាយសណ្ដាន់ និងសន្ដាន គឺស្រដៀងគ្នា នេះជាហេតុដែលលោកយកម្ហូរសណ្ដាន់មកដាក់ក្នុងពាក្យបណ្ដាំចុងក្រោយនេះ ដើម្បីកាត់ចម្អាបដែលមាននៅក្នុងត្រី។

ន័យទី២ បើព្រះអង្គបានសោ្ករត្រីសោយហើយ មានន័យថា បើព្រះអង្គបានសោយរាជ្យគ្រប់គ្រងនគរស្ត្រី(សត្វត្រី = មីនា = ផ្កាយ) ព្រះអង្គត្រូវត្រួតមើលនាម៉ឺនមន្ត្រី គ្រប់លំដាប់ថ្នាក់របស់ព្រះអង្គ ដែលបានទទួលអំណាចពីព្រះអង្គ យកទៅប្រតិបត្តិ។ ពួកគេសុទ្ធតែជាញាតិសន្ដាន ជាខ្សែបណ្ដោយ ជាដៃជើង ចូរព្រះអង្គកុំធ្វេសប្រហែស ត្រូវប្រើម្ហូរគឺច្បាប់ទៅកាត់ចំអាប គឺសេចក្ដីលោភលន់(ពុករលួយ) របស់នាម៉ឺនមន្ត្រី និងសាច់សាលោហិត ដែលជាញាតិសន្ដានរបស់ព្រះអង្គ។ បើពុំដូច្នោះទេ ពួកគេនឹងយកឥទ្ធិពលអំណាចរបស់ព្រះអង្គ ឬរបស់អ្នកដឹកនាំមានអំណាច ទៅរំលោភបំពានជិះជាន់គៀបសង្កត់ថ្នាក់ក្រោម ដែលមាន

ប្រជារាស្ត្រជាអាទិ ធ្វើឲ្យប្រជារាស្ត្រទាំងអស់ក្ដៅក្រហាយ ងើបឈរឡើងបះបោរប្រឆាំងតបនឹងញាតិ ដែលលួចប្រើអំណាចផ្ដាក់លើខុសទំនង។ នេះជាហេតុដែលអ្នកប្រាជ្ញធនជ័យលោកពុំយកឈ្មោះម្ហូបដទៃមកប្រើ ដោយជ្រើសយកតែម្ហូបសណ្ដាន់នោះ ព្រោះលោកចង់ឲ្យយើងមើលឃើញពាក្យសន្តាន និងសណ្ដាន់។

ន័យទី៣ និពន្ធនិទានលោកផ្ដាំ ឲ្យអ្នកដឹកនាំគ្រប់គ្រងអំណាចគ្រប់ជំនាន់ ឲ្យចេះគិតពីខ្លួន ដោយកុំធ្វេសប្រហែស គឺប្រើម្ហូបដែលជាសីល ឬក្បាល សម្អាតសន្តានចិត្តខ្លួនឯង ធម្មតាចិត្តរបស់បុថុជ្ជន គឺប្រកបទៅដោយលោភៈ ទោសៈ មោហៈ ងងឹតទៅដោយអវិជ្ជា ហ៊ុមព័ទ្ធទៅដោយកិលេស និងតណ្ហាគ្របសង្កត់។ ដូច្នេះចង់កាត់នូវចម្អាប គឺបាបអកុសលទាំងឡាយចេញពីក្នុងសន្តាន ទីមួយត្រូវមានម្ហូបគឺសីល ទីពីរត្រូវមានសមាធិ ទីបីត្រូវមានបញ្ញា ដែលបញ្ញានេះ បានមកពីការអប់រំដោយសីលនិងសមាធិ នេះជាន័យសោយស្ងោរត្រីប្រាកុំចោលម្ហូបសណ្ដាន់ ឬសន្តាន។ ការស្ងោរគឺជាការរំងាស់ដោយភ្លើង គឺតបធម៌ ដោយម្ហូបគឺសីលគ្រឿងផ្សំគឺសមាធិ ធ្វើឲ្យបាត់អ្ឆាបគឺបញ្ញា ព្រោះកិលេសវាគឺជាក្បាលនៃបាបធម៌ទាំងពួង។

ការបកស្រាយន័យទាំងបី ក្នុងបណ្ដាំចុងក្រោយ របស់និពន្ធនិទានធនជ័យនេះ ខ្ញុំបាទធ្លាប់បានបកស្រាយរួចខ្លះហើយ នៅក្នុងបណ្ដាំមាតាមហានគរខ្មែរ ប៉ុន្តែខ្ញុំបាទបកបានតែត្រឹមន័យទី២ ពុំបានបកស្រាយក្នុងន័យទី៣ ដែលមានក្នុងបណ្ដាំមេនាគទី៣ឡើយ។ ការបកស្រាយដោយសង្ខេបក្នុងរឿងធនជ័យនេះ ចាត់ទុកដូចជាការចូលរួម ក្នុងការគាស់កកាយមរតកកាកគំនិតរបស់ដូនតាយើង ដែលលោកខំពុះពារគ្រប់ឧបសគ្គ ដោយពុំខ្លាចនឿយហត់ទុកនៅរឿងនិទានប្រស្នា ដែលមានអត្ថន័យដ៏មានជម្រៅនេះ សម្រាប់ដាស់ពញាក់ពូជជ័យជំនាន់ក្រោយ ឲ្យភ្ញាក់ក្រោកឡើងមកវិញ។

ខ្ញុំព្រះករុណាខ្ញុំបាទ សូមអភ័យទោសទុកជាមុន នូវរាល់កំហុសឆ្គង និងកង្វះខាតទាំងឡាយ ដែលកើតមានឡើង ដោយពាក្យពេចន៍ ឬការបកស្រាយនេះ ពុំបានចាក់ចូលឲ្យជ្រៅទៅក្នុងមរតកគំនិតដូនតា ខ្ញុំបាទសង្ឃឹមទុកជាមុនថា នឹងមានអ្នកប្រាជ្ញឬបណ្ឌិត ជាពូជជ័យ លោកនឹងជួយបំពេញនូវកង្វះខាតទាំងនោះជាពុំខាន។

ចុងបញ្ចប់ខ្ញុំព្រះករុណាខ្ញុំបាទ សូមប្រគេនបុណ្យ ជូនបុណ្យ ឧទ្ទិសបុណ្យ ក្នុងការខិតខំស្រាវជ្រាវនិងបកស្រាយ មរតកកាកគំនិតដូនតានេះ ជូនចំពោះលោកអ្នកមានគុណ មាតា

*បិតា គ្រូឧបជ្ឈាយាចារ្យ ញាតិធម៌ និងសព្វសត្វក្នុងទិសទាំង១០ គ្រប់កាលទាំងបី សូមឲ្យជួបប្រទះតែនឹងពរទាំងឡាយប្រាំប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ និងជួបប្រសព្វតែសម្បត្តិទាំងឡាយបី គឺសម្បត្តិមនុស្ស ទេវតា និងព្រះនិព្វាន កុំបីក្លាយទៅជាប្រការដ៏ទៃឡើយ។*

*ខេត្តព្រះសីហនុថ្ងៃព្រហស្បតិ៍***៦***កើត ខែអស្សុជ ឆ្នាំម្សាញ់ បញ្ចស័ក ពស.***២៥៥៧** *ត្រូវនឹងថ្ងៃទី***១០** *ខែតុលា ឆ្នាំ***២០១៣**

*ការខិតខំស្រាវជ្រាវនេះ សូមរក្សាសិទ្ធិទាំងស្រុង*
*ពីខ្ញុំករុណាខ្ញុំបាទឧបាសក* **គៀត ចាន់ធុន**
*អតីតសិស្សសាលាវិចិត្រសិល្បៈ* **គៀត ចាន់ធុន**